ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត




- យុត្តិធម៌ជាមួយកន្លងសម្លឹងប៉ុណ្ណោះ
- អនុស្សាវរីយ៍ក្រោមរបបខ្មែរក្រហម : ការចងចាំរបស់កុមារីកម្ពុជាម្នាក់ (ឈ្មោះ អ៊ីង)

លេខ១០៥ ខែកញ្ញា ឆ្នាំ២០០៨

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៣៣ ខែកញ្ញា ឆ្នាំ ២០០២

# មាតិកា


- សំបុត្រៈ យុត្តិធម៌នាំមកនូវស្បៀងអាហារ ....... ១

**ផ្នែកឯកសារ**

- ទេព សំអាន ....... ២
- ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម ....... ៥
- ទួន សុខផល្លា ....... ៩
- បញ្ជីឈ្មោះជនរងគ្រោះបរទេស ....... ១៣
- ក្បួនទ័ពព្រៃខ្មែរក្រហម ....... ១៤
- ការដណ្តើមមកវិញនូវព្រលឹងជាតិកម្ពុជា ....... ១៨
- បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ....... ២២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

- មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ ....... ២៣
- អ្នកជំងឺភេទស្រ្តី ....... ៣០

**ផ្នែកច្បាប់**

- ករណីយកិច្ចក្នុងការចោទប្រកាន់អំពើរំលោភសិទ្ធិមនុស្ស ....... ៣៦

**វេទិកាពិភាក្សាសាធារណៈ**

- បទសម្ភាសន៍ជាមួយព្រះភិក្ខុ យស ហ៊ុត ខេមចារោ ....... ៣៩
- ភ្នាក់ងារផ្តាច់ព្រលឹង ....... ៤៥
- ហេតុអ្វីនៅតែពុំមានការកាត់ទោសខ្មែរក្រហម? ....... ៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

- មិនអាចកាត់ផ្តាច់ក្តីនឹករឭក ....... ៥៥
- កូនស្រីដែលបាត់បង់ទៅក្នុងបដិវត្តន៍ខ្មែរក្រហម ....... ៥៩

**សិល្បៈខ្មែរក្រហម**

- រូបថតយុទ្ធជនខ្មែរក្រហម ....... គ្របក្រោយ




លឿង អ៊ីង

# រក្សាសិទ្ធិ


មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាដៃលេខនេះ**៖ លឿង អ៊ីង, ឡុង ដានី, គឹម កែវកន្និដ្ឋា, ប៉ាង ពីរីន, អែម សុខឃឹម, យិន នាន, វ៉ាន់ថាន់ ពៅដារ៉ា, អាឡិច ហ៊ីនតុន, អេលីហ្សាប៊ែត វ៉ាន់ស្កាក់ **អ្នកនិពន្ធនិងស្រាវជ្រាវ**ៈ លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយក**ៈ សាន់ កល្យាណ **និពន្ធនាយករងទី១** ៖ ស៊ូ ប៊ុនស៊ូ **និពន្ធនាយករងទី២**ៈ សឹម សុរិយ៉ា **អ្នកបកប្រែ** ៖ អេង កុកថាយ **និពន្ធនាយកទូទៅ**ៈ ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ** ៖ ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ** ៖ សុខ វណ្ណៈ

***សំបុត្រៈ***

# យុត្តិធម៌នាំមកនូវស្បៀងអាហារ

មានការទាញហេតុផលតាមរយៈពត៌មានអន្តរជាតិថា “បច្ចុប្បន្ន ប្រសិនបើយើងសួរទៅប្រជាជនកម្ពុជាថា តើអ្វីដែលជាបញ្ហាសំខាន់ ប្រជាជនកម្ពុជានឹងឆ្លើយថាបញ្ហាទឹកជំនន់ (មិនមែនការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ)” ។ ចម្លើយនេះមិនពិតទាំងស្រុងឡើយ ។ នៅក្នុងរបបខ្មែរក្រហមខណៈដែលប្រជាជនកម្ពុជារាប់ម៉ឺនរាប់សែននាក់កំពុងទទួលរងការកាប់សម្លាប់និងការបង្អត់អាហារ ក៏គ្មាននរណាម្នាក់និយាយថាបញ្ហាយុត្តិធម៌គឺជាការសំខាន់ដែរ ។ សង្គមដែលគ្មានយុត្តិធម៌ ប្រជាជននឹងទទួលរងនូវការអត់ឃ្លាននិងការរំលោភសិទ្ធិ ហើយសង្គមបែបនេះនឹងមិនអាចជឿនលឿនទៅមុខបានឡើយ ។ របបខ្មែរក្រហមបានដួលរលំទាំងស្រុងក៏ដោយសារតែបញ្ហាខាងលើ ។

ដើម្បីចាប់ផ្តើមកំណែទម្រង់ផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងដើម្បីទប់ស្កាត់ការអត់ឃ្លាននិងការប្រមាថដល់ជីវិតមនុស្ស កំណែទម្រង់នយោបាយគឺជាការចាំបាច់ណាស់ដែលខានមិនបាន ។ កំណែទម្រង់នយោបាយនៅកម្ពុជាអាចធ្វើទៅបាន ត្រូវតែផ្សារភ្ជាប់ជាមួយនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែក្នុងករណីដែលភាគីទាំងពីរ (រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ) គិតតែអំពីកំហុស ហើយដាក់កំហុសឲ្យគ្នាទៅវិញទៅមកនោះ គឺមិនមែនជាការជួយដល់កម្ពុជាទេ ។

ភាគីទាំងពីរមិនគួរដោះស្រាយការខ្វែងគំនិតគ្នាឲ្យហួសពីរយៈពេល៣ខែឡើយ ។ ប្រសិនបើភាគីទាំងសងខាងពិតជាមានចិត្តស្មោះត្រង់នឹងគ្នា ហើយពិតជាចង់ដោះស្រាយបញ្ហាមែននោះ រយៈពេល៣ខែពិតជាច្រើនពេកដងក្នុងការបញ្ចប់នូវសេចក្តីព្រាងវិសោធនកម្មដែលអាចទទួលយកបានទៅលើច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប្រសិនបើគ្មានការកម្រិតពេលវេលាច្បាស់លាស់ទេនោះ បញ្ហានៅតែទៅមុខទៅក្រោយមិនចេះចប់មិនចេះហើយរហូតដល់ថ្ងៃដែលមេដឹកនាំខ្មែរក្រហមស្លាប់បាត់បង់ជីវិត ។ ប្រជាជនកម្ពុជាជាង១លាននាក់បានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមដោយការបង្អត់អាហារ ជំងឺ ធ្វើការបាក់កម្លាំង និងយកទៅសម្លាប់ចោល ។ របបខ្មែរក្រហមគឺជារដ្ឋាភិបាលតែមួយគត់នៅក្នុងសតវត្សរ៍ទី២០ ដែលបានរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបំផុត ។ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិត្រូវតែបញ្ចេញនូវសុឆន្ទៈរបស់ខ្លួន ដោយការផ្តោតការយកចិត្តទុកដាក់ខ្លាំងជាងនិងទូលំទូលាយជាងនេះ ក្នុងការចរចាប្រកបដោយន័យស្ថាបនា ប្រយោជន៍ដើម្បីដោះស្រាយបញ្ហា និងស្វែងរកយុត្តិធម៌សម្រាប់កម្ពុជានិងមនុស្សជាតិ ។ ប្រសិនបើមានសញ្ញាបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិមានចិត្តបើកទូលាយទៅរកគំនិតថ្មីៗ ហើយមានភាពប្រាកដប្រជាឈានទៅសម្រេចបាននូវដំណោះស្រាយមួយដែលធានានូវបទដ្ឋានអន្តរជាតិនោះ ពិតជាជំនួយមួយដ៏ប្រពៃសម្រាប់អនាគតកម្ពុជា ។ ទឹកនៅតែជន់ ប៉ុន្តែប្រជាជននឹងមិនអាចខ្វះស្បៀងអាហារបានទេ ប្រសិនបើសង្គមកម្ពុជាមានយុត្តិធម៌ពិតប្រាកដ ។

**ឆាំង យុ**

# ទេព សំអាន


ទេព សំអាន

ភ្លាមៗបន្ទាប់ពីក្រសោបបានអំណាចនៅក្នុងដៃនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហមចាប់ផ្តើមយុទ្ធនាការបោសសម្អាតប៉ូលិស និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ។ បន្ទាប់មកគឺមន្ត្រីរដ្ឋការស៊ីវិល ពាណិជ្ជករ សិស្សនិស្សិតនិងបញ្ញវន្ត ។ ក្រោយមកទៀតគឺអតីតអ្នកតស៊ូខ្មែរក្រហមដែលធ្លាប់ពួតដៃតស៊ូយូរអង្វែងជាមួយគ្នាតាំងពីសម័យសង្គ្រាមប្រឆាំងអាមេរិកទាំងក្នុងប្រទេសនិងក្រៅប្រទេស រួមមាន សោ ភឹម, ហ៊ូ នឹម, ហ៊ូ យន់, កោក ឆាយ, មាយ ទូច, ស៊ាន អាន, វ៉ាន់ ពីនី, អ៊ីស៊ុប គន្ធី, យុគ ចាន់ថា, ហួត សម្បត្តិ និងសារិន ឆាក ជាដើម ។ សកម្មជនទាំងអស់ត្រូវបានហៅត្រឡប់ចូលមកក្នុងប្រទេសវិញ ដើម្បីកសាងបដិវត្ត ។ នៅពេលមកដល់ប្រទេសកម្ពុជា ទាំងអស់គ្នាត្រូវបានបញ្ជូនឲ្យទៅឃុំឃាំងនៅក្នុងគុកទួលស្លែង ហើយបន្ទាប់មកគឺយកទៅ«សម្លាប់ចោល» ។

ទេព សំអាន គឺជាសកម្មជនម្នាក់ក្នុងចំណោមសកម្មជនជាច្រើនដែលបានរួមចំណែកតស៊ូនៅក្រៅប្រទេសដើម្បីបុព្វហេតុបដិវត្តន៍ខ្មែរក្រហម ។ សំអាន បានចូលរួមជាមួយរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជាតាំងពីឆ្នាំ១៩៧០ ក្នុងតួនាទីជាលេខាទី៣នៃស្ថានទូតរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំនៅប្រទេសអាល់ហ្សេរី ។ ឆ្លើយតបការអញ្ជើញរបស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ សំអាន បានវិលត្រឡប់មកប្រទេសកម្ពុជាវិញនាថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦ ។ នៅថ្ងៃទី២៣ ខែ-ឆ្នាំដដែល ក៏ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកឃុំឃាំងនៅមន្ទីរ ស-២១ ។

នៅក្នុងមន្ទីរឃុំឃាំង សំអាន បានទទួលសារភាពគ្រប់យ៉ាងតាមដែលអង្គការចោទប្រកាន់ថាខ្លួនជាភ្នាក់ងារ សេ.អ៊ី.អា និង កា.ហ្សេ.បេ ។

សេចក្តីសង្ខេបចម្លើយសារភាពរបស់ ទេព សំអាន មានដូចតទៅនេះ÷

ទេព សំអាន កើតនៅឆ្នាំ១៩៣៦ នៅទីក្រុងភ្នំពេញ ។ សំអាន ចាប់ផ្តើមធ្វើការងារក្នុងអាយុ២៣ឆ្នាំ គឺនៅឆ្នាំ១៩៥៩ ជាឆ្នាំដែលគាត់បញ្ចប់ការសិក្សាត្រឹមថ្នាក់មធ្យមសិក្សាប័ត្រភាគទី២ ។ ការងារដំបូងរបស់ សំអាន គឺជាបុគ្គលិកស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា ។ នៅឆ្នាំ១៩៥៩ សំអាន អះអាងថាខ្លួនបានចូលជាភ្នាក់ងារសេ.អ៊ី.អាតាមរយៈជនជាតិអាមេរិកាំងម្នាក់ឈ្មោះ ម៉រ ជាបុគ្គលិកបម្រើការនៅស្ថានទូតអាមេរិក ។ ការងារដែលទទួលខុសត្រូវគឺ ទីមួយ ស៊ើបអំពីសកម្មភាពរបស់ខ្មែរក្រហមនៅភ្នំពេញ និងទីពីរ បំផុសមហាជនឲ្យប្រឆាំងនឹងនយោបាយរបស់រដ្ឋាភិបាលដែលគាំទ្រវៀតណាមខាងជើង ។ ឆ្នាំ១៩៦០ សំអាន ផ្លាស់ទៅធ្វើការនៅក្រសួងការបរទេស ។ នៅក្រសួងការបរទេស សំអាន បានស្គាល់មនុស្សសំខាន់ៗដែល សំអាន អះអាងថាជាខ្សែរយៈសេ.អ៊ី.អាដែរ ដូចជា កែ ឈាង (កូនរបស់ កែ មាស) ចាងហ្វាងពិធីការនៅដំណាក់ប្រមុខរដ្ឋ, គឺ សុទ្ធ (កូនប្រសាររបស់សិរិមតៈ) ចាងហ្វាងនយោបាយនៅក្រសួងការបរទេស, ទឹម ណាំង ទាហានពាក់ស័ក្តិ៤ ប្រចាំការនៅខេត្តស្ទឹងត្រែង និង នុត ឈឿម ចាងហ្វាងកាសែតមាតុភូមិ ។

ទោះជាមិនបន្តការងារនៅស្ថានទូតអាមេរិក ក៏ សំអាន នៅតែមានឱកាសច្រើនដើម្បីជួបជាមួយ ម៉រ ។ ម៉រ ឧស្សាហ៍និយាយប្រាប់ សំអាន អំពីគម្រោងធ្វើរដ្ឋប្រហារនៅកម្ពុជា អំពីផែនការអាមេរិកចង់យកឥណ្ឌូចិនទាំងមូលធ្វើជារណប និងចង់យកឥណ្ឌូចិនធ្វើជាមូលដ្ឋានសឹកសម្រាប់ធ្វើសង្គ្រាមប្រឆាំងនឹង«លោកកុម្មុយនិស្ត» ជាអាទិ៍គឺចិន ។

ខែសីហា ឆ្នាំ១៩៦៦ សំអាន ផ្លាស់ទៅធ្វើជាអធិការបតី

នៅស្ថានទូតកម្ពុជាប្រចាំប្រទេសអេហ្ស៊ីប ។ សមាសភាពនៅក្នុងស្ថានទូតមាន សារិន ឆាក (ឯកអគ្គរដ្ឋទូត) , គី សុទ្ធ និង ប៉ែម ស្នួន (ទីប្រឹក្សា) , ងួន ពីតូវ៉ារុធ (លេខាធិការទី១) , គី ប៉េងហ៊ិន (លេខាធិការទី២) , ទេព សំអាន និង សំផុន ប៊ុនថា (អធិការបតី) , វ៉ាន់ លឿង និង មាស សារ៉េត (អធិការបតីរង) ។ បន្ទាប់ពីព្រឹត្តិការណ៍រដ្ឋប្រហារនៅក្នុងប្រទេសកម្ពុជានាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ កម្លាំងទាំងអស់នេះបានបែកខ្ញែកជាពីរក្រុម គឺ សារិន ឆាក, ប៉ែម ស្នួន, ទេព សំអាន, និង មាស សារ៉េត ចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ។ ចំណែកឯ គី សុទ្ធ, ងួន ពីតូវ៉ារុធ, គី ប៉េងហ៊ិន, សំផុន ប៊ុនថា និង វ៉ាន់ លឿង ចូលរួមខាងរដ្ឋាភិបាល លន់ ណុល ។ ក្រៅពីបុគ្គលទាំងប៉ុន្មានខាងលើ សំអាន បានទាក់ទងជាមួយមនុស្សមួយចំនួនទៀត ដូចជាជនជាតិលីបង់ឈ្មោះ អេដ្រង់ ជនជាតិបារាំងឈ្មោះ ត្រូប៉ែរ និង សង់ពីយ៉ែរ ជនជាតិអេហ្ស៊ីបឈ្មោះ សាឡហូ និស្សិតខ្មែរឥស្លាមដែលរៀននៅប្រទេសអេហ្ស៊ីបឈ្មោះ ហាន់ម៉ាត់ ភារធារីអាមេរិកាំងប្រចាំនៅប្រទេសអេហ្ស៊ីបឈ្មោះ គ្រីស្តូហ្វ ។ សំអាន អះអាងថាមនុស្សដែលរៀបរាប់ទាំងអស់នេះសុទ្ធសឹងជាភ្នាក់ងារសេអ៊ីអាដែលបានរួមចំណែកបង្កមហន្តរាយដល់រដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជា ។

## នៅប្រទេសកូរ៉េខាងជើង

នៅខែកញ្ញា ឆ្នាំ១៩៧០ សំអាន បានបញ្ចប់បេសកកម្មការងារនៅប្រទេសអេហ្ស៊ីប និងត្រូវផ្លាស់ចេញទៅប្រចាំការជាអធិការបតីនៅស្ថានទូតរណសិរ្សរួបរួមជាតិប្រចាំទីក្រុងព្យុងយ៉ាង ប្រទេសកូរ៉េខាងជើង ។ សំអាន បានទាក់ទងជាមួយតំណាងរបស់ប្រទេសចំនួន១៦ដែលប្រចាំការនៅប្រទេសកូរ៉េខាងជើង ដូចជា ឥណ្ឌា អេហ្ស៊ីប អ៊ីរ៉ាក់ គុយបា រ៉ូម៉ានី ឆេកូស្លូវ៉ាគី អាល្លឺម៉ង់ខាងកើត ឥណ្ឌូនេស៊ី សូវៀត បារាំង... ។ សំអាន ឆ្លៀតពេលណាដែលឱកាសល្អហុចឲ្យ និយាយប្រាប់អ្នកតំណាងប្រទេសទាំងអស់អំពីកម្ពុជាថា «សង្គ្រាមដែលខ្មែរក្រហមធ្វើ គ្មានវរជនឬកម្មាភិបាលឯណាទៀតដឹកនាំដូចពាក្យហៅថារណសិរ្សរួបរួមជាតិកម្ពុជានោះទេ» ។ សំអាន បានសុំឲ្យតំណាងប្រទេសទាំងអស់ចាត់ទុកសង្គ្រាមនៅប្រទេសកម្ពុជាជាសង្គ្រាមរវាងអាមេរិកនិងខ្មែរក្រហម ។ បើអាមេរិកចាញ់ ខ្មែរក្រហមនឹងឡើងកាន់អំណាច ហើយកម្ពុជានឹងក្លាយទៅជារបបកុម្មុយនិស្តជាក់ជាមិនខាន ។ ធ្វើដូច្នេះ សំអាន ជឿជាក់ថា តំណាងប្រទេសទាំងអស់នោះនឹងថមថយសមានចិត្តចំពោះខ្មែរក្រហម ហើយនឹងធ្វើរបាយការណ៍ទៅឲ្យរដ្ឋាភិបាលរបស់រៀងៗខ្លួន ដូច្នេះរដ្ឋាភិបាលទាំង១៦នឹងប្រកាន់គោលជំហរប្រឆាំងនឹងខ្មែរក្រហម ។

ទន្ទឹមនឹងនេះ សំអាន ក៏មានទំនាក់ទំនងជិតស្និទ្ធនឹងមនុស្សពីរនាក់ទៀត គឺ មីសែល តំណាងពាណិជ្ជកម្មបារាំងប្រចាំនៅប្រទេសកូរ៉េខាងជើង ។ មីសែល គឺជាភ្នាក់ងារសេ.អ៊ី.អាដែលចាំស៊ើបរាល់ផែនការរបស់កូរ៉េខាងជើង ហើយរាយការណ៍ឲ្យអគ្គការសេ.អ៊ី.អា ។ ចំណែកឯម្នាក់ទៀតគឺ អ៊ីហ៊្គ័រ ស័ក្តិ២ទាហានជើងទឹក ។ អ៊ីហ៊្គ័រ បានអូសទាញ សំអាន ឲ្យចូលជាភ្នាក់ងារកា.ហ្សេ.បេរបស់សូវៀត និងឲ្យ សំអាន ឃោសនាទាក់ទាញអ្នកតស៊ូក្នុងជួររណសិរ្សរួបរួមជាតិកម្ពុជានៅក្រៅប្រទេសឲ្យបញ្ឈប់ការតស៊ូ ពីព្រោះមិនសង្ឃឹមថានឹងបានទទួលជ័យជម្នះលើអាមេរិក ។

ខែមេសា ឆ្នាំ១៩៧២ សំអាន សុំផ្លាស់មកធ្វើការនៅទីក្រុងប៉េកាំងវិញ ។ សំអាន បានឲ្យដឹងថា នៅប៉េកាំង ក្រៅពីកិច្ចការរណសិរ្ស ខ្លួននៅមានភារកិច្ចពីរទៀត គឺសេ.អ៊ី.អា និងកា.ហ្សេ.បេ ។ សម្រាប់សេ.អ៊ី.អា សំអាន ត្រូវធ្វើសកម្មភាពទូទៅប្រឆាំងនឹងខ្មែរក្រហម ។ សម្រាប់កា.ហ្សេ.បេ សំអាន ត្រូវបំបែកបំបាក់ក្នុងជួររណសិរ្ស និង ឃោសនាខ្មែរនៅបរទេសឲ្យបញ្ឈប់ការតស៊ូ ។

## នៅទីក្រុងប៉េកាំងប្រទេសចិន

មកដល់ប៉េកាំងភ្លាម សំអាន បានស្គាល់ជួប កែ ឈាង, ទឹម ណាំង, នុត ឈឿម និង គាំ លាង ហាក់ ។ កែ ឈាង ជាប្រធានពិធីការនៅដំណាក់ប្រមុខរដ្ឋ ចំណែក ទឹម ណាំង ជាអគ្គរក្សរបស់ប្រមុខរដ្ឋ ។ ទាំងពីរនាក់នេះបង្កប់នៅក្នុងដំណាក់ប្រមុខរដ្ឋ ចាំយកព័ត៌មានអំពីផែនការនយោបាយរបស់ប្រមុខរដ្ឋ ហើយរាយការណ៍ទៅឲ្យស្ថានទូតបារាំងនៅប៉េកាំង និង បង្កវិទ្ធង្សនាផ្សេងៗទៀត ។ ចំណែក នុត ឈឿម និង សំអាន បង្កប់ក្នុងចំណោមមហាជន ។ រីឯ គាំ លាងហាក់ ជាភ្នាក់ងារ

កា.ហ្សេ.បេ ។

ខែមិថុនា ឆ្នាំ១៩៧៣ ក្រសួងការបរទេសនៃរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជាបានតែងតាំង សំអាន ជាលេខាធិការទី៣នៃស្ថានទូតរណសិរ្សប្រចាំនៅប្រទេសអាល់ហ្សេរី ដែលមាន ថែម ស្ងួន ជាឯកអគ្គរដ្ឋទូត ។

ក្រោយថ្ងៃជ័យជំនះរបស់ខ្មែរក្រហម សំអាន ប្រើវិធីសាស្ត្រថ្មីទាក់ទាញអន្តទូតនានានិងខ្មែរដទៃទៀតឲ្យសួប់របបកម្ពុជាប្រជាធិបតេយ្យ ដោយប្រើពាក្យឃោសនាបំផ្លើសថាប្រទេសកម្ពុជាជាប្រទេសរណបចិននិងគ្មានឯករាជ្យទេ ហើយថាកម្ពុជាប្រជាធិបតេយ្យជារដ្ឋអំណាចផ្តាច់ការ ។ ប្រជាជនឥតសេរីភាព ជួបគ្រោះទុរ្ភិក្ស គ្មានសម្លៀកបំពាក់ គ្មានថ្នាំសង្កូវ គ្មានទីជម្រក បែកបាក់គ្រួសារ ឪពុកម្តាយ បងប្អូន។ អង្គការបដិវត្តន៍ប្រកាន់បក្ខពួកនិយម គ្រួសារនិយម ។ សំអាន សង្ឃឹមថាធ្វើដូច្នេះគាត់នឹងអាចធ្វើឲ្យខ្មែរក្រហមឯកោលើសកលលោក ។

## ជោគវាសនារបស់ ទេព សំអាន និងមិត្តភក្តិ

ដើមឆ្នាំ១៩៧៣ កែ ឃាង ដែលជាប្រធានពិធីការនៅជំណាក់ប្រមុខរដ្ឋ ត្រូវរដ្ឋាភិបាលរណសិរ្សចាប់ភ័ស្តុតាងបានថាជាភ្នាក់ងារសម្ងាត់សេ.អ៊ី.អា ហើយក៏ត្រូវចាប់ឃុំឃាំងមួយរយៈទើបដោះលែងមកវិញ ។ ខែកុម្ភៈ ឆ្នាំ១៩៧៣ កែ ឃាង បានភៀសខ្លួនទៅរស់នៅប្រទេសថៃ ។ ឆ្នាំ១៩៧៤ ដោយឃើញថា លន់ ណុល បរាជ័យស្ទារលែងរួច ទីម ណាំង ក៏នាំក្រុមគ្រួសារទៅរស់នៅប្រទេសបារាំងរហូត ។ ខែកញ្ញា ឆ្នាំ១៩៧៥ នុត ឈឿម ដឹងខ្លួនថាត្រឡប់មកស្រុកខ្មែរវិញមិនបាន ក៏ភៀសខ្លួនទៅរស់នៅហុងកុង ។ ចំណែក គាំ លាង ហាក់ ត្រូវអង្គការចាប់ខ្លួននិងសួរចម្លើយនៅខែមករា ឆ្នាំ១៩៧៣ ប៉ុន្តែត្រូវបានដោះលែងឲ្យចេញពីប៉េកាំងនៅខែកក្កដា ឆ្នាំដដែល ។ គាំ លាង ហាក់ ក៏នាំក្រុមគ្រួសារទៅរស់នៅទីក្រុងមូស្គូ ប្រទេសសូវៀត ។ សំអាន ម្នាក់ឯងគត់ដែលត្រូវអង្គការចាប់ខ្លួនបញ្ជូនចូលមន្ទីរ ស-២១(គុកទួលស្លែង) ដើម្បីសួរចម្លើយដដីករកខ្សែរយៈនិងកម្ទេចចោល ។

ខែកុម្ភៈ ឆ្នាំ១៩៧៦ សំអាន បានទទួលទូរលេខពីក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ហៅបុគ្គលិកនិងគ្រួសារខ្មែរទាំងអស់នៅគ្រប់ស្ថានទូតខ្មែរនៅបរទេស ឲ្យចូលមកកម្ពុជា "ដើម្បីរៀនសូត្រ" ។ ខ្លឹមសារទូរលេខបញ្ជាក់ថាមិនឲ្យគ្រួសារជាជនជាតិបរទេសមកជាមួយ ដូច្នេះ សំអាន ក៏វិលត្រឡប់មកប្រទេសកម្ពុជាតែម្នាក់ឯង ចំណែកប្រពន្ធដែលជាជនជាតិអេហ្ស៊ីបនិងកូន៣នាក់ ត្រូវបន្តរស់នៅប្រទេសអេហ្ស៊ីបដដែល ។

សំអាន មកដល់ប្រទេសកម្ពុជានៅវេលាម៉ោង១១ថ្ងៃត្រង់ ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦ ហើយស្នាក់នៅក្នុងមន្ទីរ ក-១៥ រហូតដល់ថ្ងៃទី២៣ ខែឆ្នាំដដែល ក៏ត្រូវអង្គការចាប់ខ្លួន ។

នៅក្នុងមន្ទីរឃុំឃាំង សំអាន ត្រូវបានសួរចម្លើយដោយកម្មាភិបាលឈ្មោះ ថុង នៅពួកទី៨ ។ បច្ចុប្បន្ន មជ្ឈមណ្ឌលកម្ពុជាមានឯកសារចម្លើយសារភាពរបស់ សំអាន ចំនួនបីដុំ ដែលបង្ហាញកាលបរិច្ឆេទសួរចម្លើយចំនួនបីខុសៗគ្នា ។ ដុំឯកសារទីមួយមានចំនួន១៦ទំព័រ មានកាលបរិច្ឆេទពីថ្ងៃទី៤ ដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ និយាយអំពី "សភាពការណ៍អន្តរជាតិជុំវិញកម្ពុជា" ។ ដុំឯកសារទីពីរមានចំនួន៧៤ទំព័រ មានកាលបរិច្ឆេទថ្ងៃទី១៥និង១៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ និយាយអំពី "ផែនការរបស់ចក្រពត្តិអាមេរិកនិងសូវៀតមកលើកម្ពុជា" ។ ឯកសារមួយដុំទៀតមានចំនួន៦៦ទំព័រ មានកាលបរិច្ឆេទពីថ្ងៃទី២៣ដល់ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ និយាយអំពី "ប្រវត្តិការងារនិងសកម្មភាពក្បត់របស់សាមីខ្លួន ទេព សំអាន" ។

ទេព សំអាន មានឪពុកឈ្មោះ ទេព ជឿន និងម្តាយឈ្មោះ សោម សឺ ។ ប្រពន្ធឈ្មោះ ហូដាហាសប៊្រាន់ ជាជនជាតិអេហ្ស៊ីប ។ សំអាន ត្រូវចោទសម្លាប់ក្រោមបទចោទប្រកាន់ថាជាភ្នាក់ងារ សេ.អ៊ី.អា និង កា.ហ្សេ.បេ ក្បត់បដិវត្តន៍ ។ **សាន់ កល្យាណ**

## ពាក្យស្លោកខ្មែរក្រហម

- **កម្ចាត់ជាដាច់ខាតភ្នាក់ងារ សេ.អ៊ី.អា ឱ្យអស់រលីងពីអង្គភាព និងពីទឹកដីកម្ពុជាជារៀងរហូត។**

(កំណត់ហេតុលេខ១០ ៧៦)

- **បន្តវាយកម្ទេចគោលជំហរកម្មសិទ្ធិសួនតួឱ្យអស់រលីងខាងសំភារៈ ខាងសិទ្ធិអំណាច និងសីលធម៌រស់នៅ ជាដាច់ខាត។**

(ទង់បដិវត្ត ឆ្នាំ១៩៧៦)

# ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម

***ថ្ងៃទី ១៧-១៨ មេសា ១៩៧២:***

យើងបានទទួលដំណេកនៅក្នុងខ្ទមចំការដែលគេបោះបង់ចោល ។ មេកងឈ្លប "រណសិរ្ស" ជាអ្នកទទួលខុសត្រូវលើសន្តិសុខនិងដំណើរយើងខ្ញុំ បានយកសំពត់តង់កៅស៊ូពីរផ្ទាំងមកឲ្យយើងក្រាលលើដីធ្វើជាកន្ទេល ។ រាត្រីស្ងាត់ជ្រងំ អំពិលអំពែកហើរព្រោងព្រាតឃើញកូនពន្លឺភ្លឹបភ្លែតៗ ។ មេកងឈ្លបសុំឆែកកាបូបយើងខ្ញុំក្រែងមានអាវុធឬវិទ្យុនៅក្នុងនោះ ។ គេស្នើសុំកុំឲ្យជក់បារី ក្រែង "ខ្មាំង" មើលឃើញ ។ នៅជុំវិញយើង កងឈ្លប ៦ឬ៧នាក់ផ្លាស់វេនគ្នាយាម ។

ព្រឹកឡើង ថ្ងៃ ១៨ មេសា វេលាម៉ោង៥ កងឈ្លបជូនដំណើរយើងទៅកាន់ភូមិមួយទៀតនៅចម្ងាយប្រមាណ៧ឬ៨គីឡូម៉ែត្រពីផ្សារកន្ទួតក្នុងខេត្តកណ្តាល ។ ភ្លៀងដើមឆ្នាំជោកជាំដី ។ មកដល់ភូមិ យើងជួបប្រទះកងឈ្លបមួយក្រុមទៀតមានគ្នាប្រមាណ២០នាក់ កំពុងរៀបចំចម្អិនម្ហូបអាហារ ។ យើងស្ទុះទៅចាប់ដៃសម្តែង "ភាតរភាពបដិវត្តន៍" ជាមួយកងឈ្លបទាំងអស់ ។ "មិត្ត" កងឈ្លបបានហៅយើងឲ្យចូលរួមអាហារជាមួយគេ ។ គេសម្លឹងមើលយើងដោយយកចិត្តទុកដាក់ មានខ្លះសម្តែងអាការៈមិនពេញចិត្តនឹងអ្វីម្យ៉ាងៗនៅក្នុងខ្លួនយើង ប្រហែលជាគេមិនពេញចិត្តនឹងរបៀបស្លៀកពាក់ឬអាកប្បកិរិយារបស់យើងក៏មិនដឹង ។ គេមិនសួរដេញដោលយើងទេ ។ ចំណែកយើងវិញយើងក៏រក្សា "លក្ខណ៍ការសម្ងាត់" មិនហ៊ានស្នើសួរ ព្រោះ "ស្នងការនយោបាយ" ធ្វើការបង្កប់ខ្លួននៅក្រុងភ្នំពេញម្នាក់ដែលជូនដំណើរយើង បានក្រើនរំឭកកុំឲ្យយើងបង្ហើបប្រាប់ឈ្មោះពិតប្រាកដឬមុខងាររបស់យើងឲ្យនរណាម្នាក់ដឹងឲ្យសោះ ។ យើងបានជួបស្នងការនយោបាយក្រុងនេះនៅរាត្រីថ្ងៃទី១៧ មេសា ១៩៧២ តែយើងពុំស្គាល់ឈ្មោះឬមុខងារដើមរបស់ "មិត្ត" នេះទេ ។ រឿងរក្សាការសម្ងាត់គ្រប់ទីកន្លែងនិងគ្រប់កាលៈទេសៈជាវិន័យមួយរបស់អង្គការខ្មែរក្រហមដែលយើងបានទទួលតាមផ្លូវ ។

នៅវេលាម៉ោង៥ល្ងាច យើងរៀបចំខ្លួនបន្តដំណើរទៅមុខទៀត ។ កងឈ្លបមួយក្រុមទៀតទទួលភារៈជូនដំណើររបស់យើងបន្តជាមួយនឹងប្រធានរណសិរ្សភូមិ ។ អ្នកយកការណ៍ម្នាក់ជិះកង់មកប្រាប់ស្នងការនយោបាយថា គេរៀបចំផ្លូវមធ្យ័តហើយ យើងក៏ចាប់ចេញដំណើរជាមួយមិត្តស្នងការដដែល ។ នៅចប់តាមផ្លូវ កងឈ្លបឲ្យសញ្ញាថាគ្មានគ្រោះថ្នាក់អ្វីទេ ។ នៅវេលាម៉ោង៧ល្ងាច យើងបានដើរឆ្លងកាត់ផ្លូវជាតិលេខ២ម្តុំខាងកើតផ្សារកន្ទួត តែយើងពុំដឹងជានៅតំបន់ត្រង់ណា ព្រោះយើងពុំដែលស្គាល់តំបន់នេះសោះ ។ កងឈ្លបប្រមាណ៦ឬ៧នាក់បានជូនដំណើរយើងឆ្លងកាត់ផ្លូវជាតិ រួចហើយគេក៏លាយើងត្រឡប់បកក្រោយវិញ ។

នៅម៉ោង៨កន្លះយប់ យើងបានចូលមកដល់ភូមិមួយទៀតដោយដើរតាមភ្លឺស្រែខ្ពស់ៗសម្បូណ៌ទៅដោយដើមត្នោតនិងដើមសង្កែ ។ អ្នកស្រុកម្នាក់នៅក្នុងភូមិនេះ បានជូនដំណើរយើងបន្តទៅមុខទៀត ។ ក្រុមរួមដំណើររបស់យើងកើនបានគ្នា៧នាក់ ។ យើងពុំដឹងថាគេមានបំណងនាំយើងទៅដល់ទីណា? ទំព័រផ្សងព្រេងមួយបែបថ្មីរបស់យើងបានបើកឡើង មិនខុសពីពាក្យគេពោលថា "ដើរទៅចូលរូងខ្លា" ទេ តែយើងមានជំនឿខ្លះៗទៅលើសមត្ថភាពដោះកុនរបស់យើង និងទៅលើសន្តានចិត្តជ្រះថ្លាផ្ទាល់ខ្លួនក្នុងបញ្ហាជាតិ ។

បន្ទាប់ពីយើងមានការឈឺចាប់និងអំពើឈ្លានពានរបស់យៀកកុងនិងយៀកណាមខាងជើងមកលើទឹកដីខ្មែរមក យើងរឹតតែមានការឈឺចាប់ពើតខ្លាំងណាស់ទៅទៀតក្នុងរឿងឃុបឃិតរបស់ខ្មែរក្រហមជាមួយយៀកកុង-យៀកណាមខាងជើង ។

ដល់ពាក់កណ្តាលអធ្រាត្រ យើងបានមកដល់ផ្សារស្គន់ទន្លេបាទី ហេវហត់រសេះរសោះដៃជើង ព្រោះគឺជាលើកទីមួយ

ដែលយើងធ្វើដំណើរដោយជើងចំនួន៦ឬ៧ម៉ោង ។ ប្រធានរណសិរ្សនៅផ្សារស្គន់រៀបចំឲ្យយើងសំរាកនៅផ្ទះតៀមចិនមួយដែលម្ចាស់បានបោះបង់ចោល ។ យប់នោះយើងបានទទួលទានដំណេកលក់ស្កប់ស្កល់ ។

### ថ្ងៃទី ១៩-២០ មេសា ១៩៧២

ព្រឹកឡើង ការចាប់អារម្មណ៍ដំបូងរបស់យើងគឺសភាពស្ងាត់ជ្រងំរបស់ទីប្រជុំជននេះ ។ ផ្ទះធំៗ តៀមចិនជាច្រើនត្រូវបិទទ្វារចោល ។ មានគ្រួសារ៧ឬ៨គ្រួសារប៉ុណ្ណោះដែលក្រាញនៅទីនេះ ។ ប្រធានរណសិរ្សជាកូនចៅចិន មាឌធំជំបង រូបរាងស្អាតបុកពាសផ្កា បឺតបារីស្លឹកសង្កែធ្វើវាហ៊ី ។ យើងឆ្ងល់ថា ហេតុអ្វីក៏មិត្តនេះមិនរត់ទៅនៅរកស៊ីឯផ្សារកន្ទួតឬភ្នំពេញ បែរជានៅយុបឃិតនឹងខ្មែរក្រហមវៀតកុង-វៀតណាមខាងជើងឯណោះទៅវិញ? ឬមួយក៏ក្រាញចាំឆ្មៀតធ្វើឈ្មួញកណ្តាលរកស៊ីជាមួយ «អង្គការ» ទេដឹង?

ម៉ោងប្រមាណ៦កន្លះព្រឹក គេហៅយើងទៅបរិភោគបាយនៅលើផ្ទះធំមួយដែលម្ចាស់ផ្ទះបោះបង់ចោល ។ នៅទីនោះយើងបានជួបប្រទះនិងសម្តែងការគួរសមជាមួយមិត្តមេបញ្ជាការ «កងវរយ» (កងអនុសេនាធំ) មេបញ្ជាការកងវរសេនាតូចនិងមិត្តស្នងការនយោបាយពីរនាក់ទៀត ។ មិត្តទាំងអស់នោះសម្តែងទឹកចិត្តសោមនស្សរីករាយចំពោះវត្តមានរបស់យើងនៅក្នុងជួររបស់គេ ។ មានស្នងការនយោបាយម្នាក់ជាអតីតគ្រូបង្រៀន បានហុចបារីកញ្ចប់សញ្ញាស្លឹកមាសមកខ្ញុំមួយ ហើយសួរសុខទុក្ខរបស់យើងនៅតាមផ្លូវ ។ ខ្ញុំក៏សម្តែងអំណរគុណតបទៅគេវិញ ហើយរង់ចាំសំណួរដទៃទៀត តែមិត្តនោះបែរជានិយាយពីជីវប្រវត្តិខ្លះៗរបស់គេប្រាប់ខ្ញុំទៅវិញ គឺគេជាអតីតគ្រូបង្រៀនធ្លាប់«ជាប់នឹងចលនាបដិវត្តន៍» នេះជាយូរមកហើយ ។ ក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ គេក៏រត់មករួមកម្លាំងនៅក្នុងព្រៃ ព្រោះមិត្តនោះធ្លាប់«បែកមុខបែកមាត់» (ភាសារបស់គេមានន័យថាៈ បែកការណ៍សម្ងាត់) ម្តងរួចមកហើយ ។ មិត្តនោះបានប្រាប់មកយើងទៀតថា ប្អូនប្រុសរបស់គេម្នាក់ទៀតជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិឈ្មោះ ស.គ.ឆ. បានរត់មករួមកម្លាំងបដិវត្តន៍របស់គេចំនួន៤ខែមុននេះដែរ ។

មិត្តម្នាក់ទៀតប្រហែលជាស្នងការនយោបាយ«កងវរយ» បានពិភាក្សាជាមួយយើងពីបញ្ហា «ស្តេចសីហនុ» ។ មិត្តនោះប្រហែលជាយល់ថាយើងខ្ញុំពិតជា «ស្លូល» ខ្មែរក្រហម ធ្វើការនៅក្រុងភ្នំពេញ ធ្លាប់ «ជាប់ចលនាតស៊ូ»របស់គេតាំងពីជំនាន់ស្តេចសីហនុ បានជាមិត្តនោះឆ្លោយសម្តីថាៈ អង្គការមិនឲ្យសីហនុមកស្រុកខ្មែរក្នុងពេលឥឡូវនេះទេ ព្រោះបើឲ្យសីហនុមក ច្បាស់ជាប្រជាជនរត់ទៅរកសីហនុហើយ ចំណែកយើងវិញយើង មុខជា


ខៀវ សំផន នៅតំបន់រំដោះ ឆ្នាំ១៩៧២

បោសគូទទេ ។

ឮសំដីនេះភ្លាម ខ្ញុំភ្ញាក់ព្រើត ព្រោះដំបូងខ្ញុំគ្រាន់តែសង្ស័យថា ខ្មែរក្រហមនិងស្តេច សីហនុ ម្តេចទៅជាត្រូវរ៉ូវនឹងគ្នាទៅរួច បើម្ខាងជាកុម្មុយនិស្ត ម្ខាងទៀតជាស្តេច ជាសក្តិភូមិ ។ នៅមានចំណុចជាច្រើនទៀតដែលយើងនៅស្រពេចស្រពិល តែយើងមិនហ៊ានបង្ហើបសួរ គឺចំណុចទាក់ទងនឹងរណសិរ្សនិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានិងវៀតកុង-វៀតណាមខាងជើង ។

ព្រោះតែយើងចង់ដឹងការពិតនៅក្នុងបញ្ហាខ្មែរ និងព្រោះតែយើងធ្លាប់ឈឺចាប់នឹងរឿងខ្មែរក្រហមចូលហ៊ុននឹងយៀកកុង-យៀកណាមខាងជើងក្នុងការកាប់សម្លាប់ខ្មែរគ្នាឯង ទើបយើងប្រថុយខ្លួនធ្វើមមាចដើរចូលភ្លើងដោយមានអាវុធតែម្យ៉ាងគឺឆន្ទៈសម្របសម្រួលខ្លួនឯងទៅតាមស្ថានភាព និង ឆន្ទៈស្រឡាញ់អ្វីដែលជាខ្មែរ ដូចដែលលោក ឈូក ម៉េងម៉ៅ វរជន «ខ្មែរកណ្តាល» ស្អាតស្អំមួយរូប ធ្លាប់សម្រក់ទឹកភ្នែកពេលណាលោករំឭកពី



«ព្រលឹងខ្មែរ» ម្តងៗ ។

កាលបើឃើញមិត្តម្នាក់នោះធ្លោយហ៊ាននិយាយពី «បញ្ហាសីហនុ» នៅចំពោះមុខខ្ញុំ មិត្តស្នងការក្រុងភ្នំពេញក៏ហៅមិត្តនោះទៅខ្សឹបស្ងាត់ៗ ប្រហែលជាគេហាមប្រាមមិនឲ្យនិយាយរឿងនេះតទៅទៀត ឬគេខ្សឹបប្រាប់គ្នាគេថាខ្ញុំមិនមែន «ស្លូល» ខ្មែរក្រហមក៏មិនដឹង ។

នៅម៉ោង៤រសៀល មានមនុស្សពីរនាក់យកកង់មកបញ្ជិះយើងទៅកាន់ភូមិខ្នារត្បែង ចម្ងាយប្រមាណ១គីឡូម៉ែត្រកន្លះពីផ្សារស្គន់ ។ នៅតាមផ្លូវ យន្តហោះ តេ២៨ ពីរគ្រឿងទើបតែវិលត្រឡប់ពីទម្លាក់គ្រាប់បែក ។

ភូមិខ្នារត្បែងក៏មានសភាពស្ងាត់ជ្រងំ យូរៗគេជួបប្រទះអ្នកស្រុកម្នាក់ ។ ផ្ទះក្បឿងជាច្រើនត្រូវបោះបង់ចោលនិងត្រូវគ្រាប់បែកធ្លុះធ្លាយដំបូលជញ្ជាំង ។ នៅក្រោមផ្ទះក្បឿងពីរខ្នងកងទ័ពខ្មែរក្រហមមួយក្រុមមានគ្នាប្រមាណ៥០នាក់កំពុងរៀបចំបរិភោគបាយជាមួយនិងយុវនារី៤នាក់ដែលយើងសន្និដ្ឋានថាជាពេទ្យសម្រាប់កងទ័ព ។ កងទ័ពនេះជាកងទ័ពប្រចាំតំបន់១៥ ។

មិត្តមេបញ្ជាការទទួលយើងដោយរាក់ទាក់ គេយកនំនិងឪឡឹកទុំមកឲ្យយើងបរិភោគ រួចក៏សាកសួរយើងពីស្ថានភាពនៅទីក្រុងភ្នំពេញ ពីទាហានសាធារណរដ្ឋ ពីអាមេរិកាំង ។ ចម្លើយរបស់យើងថាគ្មានទ័ពអាមេរិកាំងនៅភ្នំពេញទេ ហាក់ដូចធ្វើឲ្យគេមិនជឿនិងមិនពេញចិត្តសោះ ។ គេឆ្លៀតឱកាសកំពុងសន្ទនាគ្នាដើម្បីបំផុសកំហឹងរបស់គេ កំហឹងបដិវត្តន៍ចំពោះរបបសាធារណរដ្ឋយើង ។ គេចោទថា «ឆ្កែបំរើអាមេរិកាំងជាចក្រពត្រ ជាពួកមូលធននិយម យោធានិយមហ្វាស៊ីស ជិះជាន់សង្កត់សង្កិន» ឃើញយើងនៅស្ងៀមធ្វើមុខស្មើ មិត្តនោះក៏ផ្អាកធម៌ទេសនារបស់គេ ។

## ថ្ងៃ២០ មេសា ១៩៧២

ព្រឹកឡើង មិត្ត «នីរសា» ម្នាក់ទៀតទទួលភារៈជូនដំណើរយើងតទៅទៀត ។ យើងភ្លេចជំរាបថា មិត្តស្នងការនយោបាយក្រុងភ្នំពេញដែលជូនដំណើរយើងរហូតមកដល់ស្គន់ទន្លេបាទីត្រូវបានវិលត្រឡប់ចូលក្រុងភ្នំពេញវិញ ។ ពីខ្នារត្បែងតទៅយើងមានភ័ព្វវាសនាបានជិះម៉ូតូហុងដាម្តង ។ យើងបានឆ្លងកាត់ភូមិតូចៗជាច្រើន ហើយសសៀរតាមផ្លូវរថភ្លើងភ្នំពេញ-កំពតមិត្តនីរសាបានប្រាប់យើងថា យើងចូលក្នុងដែនដីខេត្តតាកែវហើយ ។ ភូមិនានាចាប់មានជីវិតអ៊ូអរជាធម្មតា ។ នៅតាមផ្លូវយើងជួបប្រទះលេណដ្ឋានជាហូរហែ ប្រជាកសិករប្រកបការងារដូចប្រក្រតី ការលក់ដូរនំចំណីបន្តិចបន្តួចមានចប់តាមផ្លូវ ។ នៅម៉ោង១១ យើងបានឆ្លងផ្លូវជាតិលេខ៣ក្បែរផ្លូវលំឆ្ពោះទៅស្រុកបរសែត ។ **(នៅមានត)**

**អ៊ិត សារិន**



ជនរងគ្រោះនៅមន្ទីរ ស-២១

*សង្ខេបចេញពីឯកសារចម្លើយសារភាព:*

# ទួន សុខផល្លា

*(តចប់)*

***ការរៀបចំមូលដ្ឋានប្រឆាំងនឹងបដិវត្តន៍នៅមន្ទីរស-៨ និងខ្សែទាក់ទងផ្សេងៗទៀត***

ចាប់តាំងពីខែកក្កដាឆ្នាំ១៩៧៥មក ទួន សុខផល្លា បានមកនៅធ្វើការនៅក្នុងក្រសួងសាធារណការ ក្រោមការគ្រប់គ្រងរបស់ ភិន។ ដំបូង ភិន បានចាត់តាំងឲ្យ ផល្លា គ្រប់គ្រងសាលមហោស្រពទន្លេបាសាក់។ ផល្លា គ្រប់គ្រងជាងឈើនិងជាងកំបោរប្រមាណម្ភៃនាក់។ ភារកិច្ចរបស់ ផល្លា គឺជួសជុលផ្ទះនិងអគាររដ្ឋផ្សេងៗតាមទិសរបស់អង្គការ។ នៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៥ ភិន បានហៅ ផល្លា ឲ្យត្រឡប់មកនៅមន្ទីរស-៨ ដើម្បីគិតគូរអំពីបញ្ហាជួសជុលស្ពានជ្រោយចង្វារឡើងវិញ។ ក្រោយមកមួយខែ ភិន បានហៅ ភុក គី មកជួយធ្វើការងារជាមួយ ផល្លា។

នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦ ភិន បានចាត់តាំងឲ្យ ផល្លា ទៅបំពេញភារកិច្ចនៅការដ្ឋានវារីអគ្គិសនីគិរីរម្យ។ នៅក្នុងមន្ទីរស-៨នាពេលនេះ នៅសល់តែ ម៉ៃ សាខន, ម៉ែន និថូ និង ភុក គី។ ផល្លា ទៅធ្វើការនៅការដ្ឋានវារីអគ្គិសនីគិរីរម្យរហូតដល់ខែឧសភា ឆ្នាំ១៩៧៦ ទើបត្រឡប់មកមន្ទីរស-៨វិញ។

ចាប់តាំងពីពេលនោះមក ផល្លា បានរួមសកម្មភាពជាមួយ ម៉ៃ សាខន ក្នុងការរៀបចំពង្រីកកម្លាំងប្រឆាំងបដិវត្តន៍ ដោយឯកភាពគ្នាថា យកចិត្តទុកដាក់ខិតខំឃោសនាអប់រំឲ្យខ្លាំងក្នុងចំណោមកម្មករដែលមិនទាន់ជ្រះស្រឡះនឹងបដិវត្តន៍ ហើយដែលនៅមិនទាន់យល់ខ្លឹមសារនៃបដិវត្តន៍។ ធ្វើយ៉ាងនេះជាឱកាសមួយជួយដល់ការតាមដានពិនិត្យមើលក្នុងចំណោមកម្មករនិងអ្នកបច្ចេកទេស តើអ្នកណាខ្លះដែលអាចអូសទាញបានដើម្បីកសាងកម្លាំងឲ្យបានច្រើនសម្រាប់ធ្វើជាមូលដ្ឋានមួយប្រឆាំងបដិវត្តន៍នៅទីក្រុងភ្នំពេញ។ ក្នុងផែនការនេះ ភិន ជាអ្នកក្ដាប់រួមនៅមន្ទីរស-៨ ទាក់ទងផ្ទាល់តាមរយៈ ម៉ៃ សាខន ដូចដែល ម៉ៃ សាខន បានបញ្ជាក់ថា "ជាចំហស្របច្បាប់ បងភិន ជាប្រធានក្រសួង ហេតុនេះមហាជនយកចិត្តទុកដាក់ចំពោះពាក្យសម្ដីនិងសកម្មភាពរបស់គាត់"។

ភិន មិនអាចចុះមកប្រឡូកផ្ទាល់ក្នុងសកម្មភាពកសាងកម្លាំងប្រចាំថ្ងៃបានទេ ប៉ុន្តែ ភិន បានផ្ដល់លទ្ធភាពឲ្យសមាសភាពប្រឆាំងបដិវត្តន៍ធ្វើសកម្មភាពបាន ហើយ ភិន ក៏បានពង្រាយកម្លាំងស្នូលដាក់តាមកន្លែងជាប់ពីគ្នា ដើម្បីក្ដាប់មហាជននៅកន្លែងនោះៗ។ ភិន បានតែងតាំង ផល្លា ឲ្យគ្រប់គ្រងមន្ទីរបច្ចេកទេសស-៨, ភុក គី នៅក្នុងគណៈរោងជាងដែក, ម៉ែន និថូ នៅក្នុងគណៈសាលាបច្ចេកទេសអគ្គិសនីទឹកថ្លា ម៉ៃ សាខន គ្រប់គ្រងកម្មករទាំងអស់នៅមន្ទីរស-៨។

ផល្លា បានជ្រើសរើសសមាជិកចំនួន៤នាក់ពីក្នុងចំណោមបុគ្គលិកបច្ចេកទេស គឺ ផាត់ ស៊ីផូ, សំបាត់, សុខុន និង វរៈឆ្នូតកសាងបានជាកម្លាំង ហើយត្រូវបាន ភិន យកមកឲ្យធ្វើជាជំនួយការនៅមន្ទីរបច្ចេកទេសស-៨។ ក្នុងរយៈកាលដែល ផល្លា កំពុងយកចិត្តទុកដាក់ខិតខំពង្រីកកម្លាំង ស្រាប់តែក្នុងអំឡុងខែតុលា ឆ្នាំ១៩៧៧ ម៉ៃ សាខន ត្រូវបាត់ខ្លួនដោយគ្មានមូលហេតុ។ ការណ៍នេះធ្វើឲ្យ ផល្លា មានការព្រួយបារម្ភមិនហ៊ានធ្វើសកម្មភាពអ្វីទៀតទេ។ ពេលនោះ ភិន ក៏សញ្ជប់សញ្ជឹងអស់រយៈពេល២-៣ថ្ងៃ នៅតែក្នុងបន្ទប់ មិនចេញដើរទៅណា។ ជាច្រើនថ្ងៃក្រោយមក ភិន បានហៅ ផល្លា ទៅជួបហើយប្រាប់ថា "សភាពការណ៍នៅក្នុងមន្ទីរមានការវិវត្តមិនល្អទេ

ម៉ៃ សាខន ត្រូវអង្គការដកខ្លួនយកចេញពីមន្ទីរហើយ ហេតុនេះនៅក្នុងការធ្វើការងារបន្តទៀត ទាមទារឲ្យមានការប្រុងប្រយ័ត្នកាន់តែខ្លាំងក្លាមែនទែននិងឈ្លាសវៃថែមទៀត ។ បើពុំដូច្នោះទេ យើងសម្រេចការអ្វីក៏មិនបាន ហើយស្លាប់ខ្លួនទាំងអស់គ្នាទៀត» ។ នេះជាសកម្មភាពប្រឆាំងនឹងបដិវត្តការងារក្នុងមន្ទីរ ស-២១ ។

ចំពោះការងារក្រៅក្រសួងវិញ ភិន គឺជាអ្នកទាក់ទងផ្ទាល់ ។ តាំងពីក្រោយរំដោះទូទាំងប្រទេសក្នុងឆ្នាំ១៩៧៥ ភិន មានការទាក់ទងស្និទ្ធស្នាលជាមួយ កុយ ធួន ហៅ ឃួន (កុយ ធួន ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ) ។ ក្នុងការដោះស្រាយតាមក្រសួងនីមួយៗ ឃួន បានខិតខំដោះស្រាយបញ្ហាចាំបាច់ជាច្រើនសម្រាប់ការងារក្នុងក្រសួងរបស់ ភិន និងផ្តល់សម្ភារសព្វគ្រប់បែបយ៉ាង រួមទាំងផ្នែកជីវភាពមន្ទីរ ស-២១ និងគ្រួសាររបស់ ភិន លើសពីរបបដែលអង្គការបានកំណត់ ។ នៅចុងឆ្នាំ១៩៧៥ ភិន បានចាត់តាំង ម៉ែន និថូ ទៅក្នុងគណៈប្រមូលជ័យភ័ណ្ឌក្នុងឋានៈជាតំណាងក្រសួងសាធារណការ ។ គណៈប្រមូលជ័យភ័ណ្ឌពេលនោះនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម ដែល ឃួន ទទួលខុសត្រូវ ។ ក្នុងនាទីជាគណៈប្រមូលជ័យភ័ណ្ឌ ម៉ែន និថូ មានលទ្ធភាពធ្វើសកម្មភាពក្នុងទីក្រុងភ្នំពេញទាំងមូល មានសិទ្ធិដើររើគ្រប់ផ្ទះ និងដើរទាក់ទងបានយ៉ាងទូលាយ ។ ភិន ឆ្លៀតបញ្ចូល ម៉ែន និថូ ដើម្បីឲ្យធ្វើជានីរសាទាក់ទងជាមួយ ឃួន ។ ចំពោះការងារផ្សេងៗទៀតដែលមានលក្ខណៈស្ងាត់ ភិន បានណែនាំ ទូច ជាគ្រួសាររបស់ខ្លួន ឲ្យទៅមកឡើងចុះក្នុងឋានៈជានីរសា ។

ចំណែក ឃួន វិញ បានប្រើ ទិន គិមហុង ជានីរសាក្នុងការទាក់ទងជាមួយ ភិន ។ ទិន គិមហុង ត្រូវជាសិស្សរបស់ ឃួន កាលនៅរៀនក្នុងវិទ្យាល័យសីហនុកំពង់ចាម ជាមនុស្សដែល ឃួន ស្រលាញ់ទុកចិត្តតាំងពីដើមរៀងមក ។ ក្រោយពីបានរំដោះទូទាំងប្រទេស ឃួន បានស្នើយក ទិន គិមហុង ឲ្យមកជួយការងារគាត់ក្នុងក្រសួងពាណិជ្ជកម្ម ។ នៅក្នុងការទាក់ទងគ្នានេះ ភិន និង ឃួន ចៀសវាងមិនជួបគ្នាដោយផ្ទាល់ទេ ដើម្បីកុំឲ្យមានការសង្ស័យ ឬឃើញមានខ្សែទាក់ទងគ្នា លើកលែងតែការជួបគ្នាក្នុងពិធីផ្សេងៗជាផ្លូវការតែប៉ុណ្ណោះ ។


ទូច សុខផល្លា មុនឆ្នាំ១៩៧៥

ឆ្នាំ១៩៧៥ ភិន បានចាត់តាំង ផល្លា ទៅជួប ចក្រី (ចាន់ ចក្រី ហៅ មាន លេខាកងពល ១៧០) ចំនួន២ដង ។ម្តងក្នុងខែកញ្ញា ឆ្នាំ១៩៧៥ គឺជួបគ្នាធ្វើការងារធម្មតា មិនទាន់មានអាថ៌កំបាំងអ្វីទេ ។ ម្តងទៀតក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៥ គឺជួបគ្នាក្នុងឱកាសដែល ផល្លា យកសំបុត្ររបស់ ខៀវ (សុន សេន) ស្នើកម្លាំងរបស់ ចក្រី ឲ្យមកសម្អាតសាលមហោស្រពទន្លេបាសាក់ ដើម្បីរៀបចំរាត្រីសិល្បៈទទួលសម្តេច សីហនុ វិលត្រឡប់មកប្រទេសវិញ ។ ក្នុងការជួបគ្នាលើកទីពីរនេះ ផល្លា បានកាន់សំបុត្រចំនួនពីរច្បាប់ ។ សំបុត្រទី១ជាសំបុត្រស្នើសុំសម្ភារសំណង់ដែលសេសសល់នៅសណ្ឋាគារកាំបូឌីយ៉ាណា ។ សំបុត្រទី២សរសេរថា “សម្ងាត់” ហើយបិទស្រោមជិត ។ ភិន បានបញ្ជាក់ប្រាប់ ផល្លា ថា សំបុត្រនេះត្រូវប្រគល់ឲ្យ ចក្រី ផ្ទាល់ដៃ បើមិនជួបផ្ទាល់ទេ ត្រូវយកសំបុត្រនេះមកឲ្យខ្លួនវិញ ។ ភិន និង ចក្រី រួមដៃគ្នារៀបគម្រោងផ្តួលរំលំបដិវត្តន៍ ។ កងពលរបស់ ចក្រី ជាអ្នករៀបចំផែនការរដ្ឋប្រហារដែលគ្រោងនឹងធ្វើឡើងក្នុងឱកាសបុណ្យខួបបក្សនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ។

គម្រោងការធ្វើរដ្ឋប្រហារត្រូវបានកំណត់ថា ក្នុងពេលកំពុងប្រារព្ធពិធីបុណ្យ យោធាក្បត់ក្នុងកងពលរបស់ ចក្រី នឹងគប់គ្រាប់បែកបង្កឲ្យមានចលាចលនៅក្បែរកន្លែងប្រារព្ធពិធីបុណ្យ (ជិតពហុកីឡដ្ឋាន) ។ កម្លាំងរបស់ ចក្រី ដែលត្រៀមរួចស្រេចនៅច្បារអំពៅ និងកម្លាំងដែលបង្កប់ខ្លួននៅក្នុងកងពល១៧នៅជិតព្រៃស ត្រូវសម្រុកចូលមកក្រុងភ្នំពេញដោយយកលេសថាមកការពារអង្គការ ប៉ុន្តែតាមពិតគឺវាយលុកចូលក្នុងពហុកីឡដ្ឋាន ហើយកម្ទេចគណៈដឹកនាំបក្ស និងប្រកាសរបបគ្រប់គ្រងមួយថ្មីនៅកម្ពុជា ។ ប៉ុន្តែគម្រោងការក្បត់នេះត្រូវបរាជ័យ ។

ការធ្វើសកម្មភាពក្បត់របស់ ភិន ត្រូវបែកការណ៍ ។ អង្គការបានដឹងជាមុន ហើយ ចក្រី ក៏ត្រូវអង្គការចាប់ខ្លួន ។

នៅខែតុលា ឆ្នាំ១៩៧៦ ម៉ៃ សាខន ក៏ត្រូវចាប់ខ្លួនដែរ ។ ភិន ក៏ប្តូរផែនការក្បត់ ដោយបានចាត់តាំង ពៅ វ៉ា និងបក្ខពួក ត្រៀមប្លន់យន្តហោះរត់ទៅប្រទេសថៃក្នុងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ១៩៧៦ ។ ប៉ុន្តែគម្រោងការនេះក៏បរាជ័យទៀត ។ ពៅ វ៉ា និងបក្ខពួក ត្រូវបានអង្គការចាប់ខ្លួន ។

### ការចាប់ខ្លួននិងការកម្ទេចខ្សែទាក់ទងសកម្មភាពក្បត់បដិវត្តន៍

ក្នុងចំណោមឯកសារ ចម្លើយសារភាពរបស់ផល្លា ដែលនៅសេសសល់ពីរបប កម្ពុជាប្រជាធិបតេយ្យ រួមមានៈ ប្រវត្តិក្បត់, សំបុត្រ គោរពជូនអង្គការ, អំពី សកម្មភាពចូលសេ.អ៊ី.អា, អំពីការចូលសេ.អ៊ី.អារបស់ ប្រពន្ធ ទូន សុខផល្លា, ការរៀបចំមូលដ្ឋានប្រឆាំង បដិវត្តនៅមន្ទីស-៨, អំពី សកម្មភាពក្បត់របស់ ភិន, ការទាក់ទងរវាងទូនសុខផល្លា និង យួន, ការទាក់ទងរវាង យួន និង ភោគ ឆាយ, ការទាក់ទងរវាង ភិន និង សុត និងការទាក់ទងរវាង ភិន, សែត, មួន ក្នុងបញ្ហា ពៅ វ៉ា បម្រុងដណ្តើម យន្តហោះទៅថៃនៅថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៧៦ ។ ការសួរចម្លើយ ផល្លា យ៉ាង ហោចណាស់ក៏ធ្វើឡើង៦លើកដែរ ព្រោះក្នុងចំណោមឯកសារ ខាងលើមានសរសេរចំណងជើងថា «ចម្លើយ ទូន សុខផល្លា ហៅ ភឿន លើកទី៦» ។



មនុស្សមួយចំនួនដែលពាក់ព័ន្ធក្នុងចម្លើយរបស់ ផល្លា ត្រូវអង្គការចាប់ខ្លួននិងយកទៅកម្ទេចចោល រាប់បញ្ចូលទាំង ផល្លា និងប្រពន្ធ ។ ទូន សុខផល្លា ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ និងកម្ទេចនៅថ្ងៃទី៨ ខែមីនា ឆ្នាំ ១៩៧៧ ។ ប្រពន្ធរបស់ ផល្លា ឈ្មោះ ទូន ចាន់ដារ៉ា ត្រូវ ចាប់ខ្លួននៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៧ និងកម្ទេចនៅ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ ម៉ែន និថូ ត្រូវចាប់ខ្លួននៅថ្ងៃ ទី១ ខែមករា ឆ្នាំ១៩៧៧ ដូចគ្នានឹង ផល្លា ដែរ ប៉ុន្តែ ត្រូវកម្ទេចនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ ។ ឈឹម សុផន ហៅ ទូច ប្រពន្ធរបស់ តូច ភឿន ត្រូវចាប់ខ្លួននៅថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៧ និង ត្រូវកម្ទេចនៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ១៩៧៧ ។ ភោគ ឆាយ ត្រូវចាប់ខ្លួន នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ ១៩៧៧ និងត្រូវកម្ទេច នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ ១៩៧៧ ។

ចំណែកអ្នកទោស ដែលត្រូវចាប់ខ្លួនរួចហើយ ប៉ុន្តែពុំបានបញ្ជាក់អំពី កាលបរិច្ឆេទកម្ទេចរួមមានៈ យួន (កុយ ធួន) ត្រូវចាប់ ខ្លួននៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ ។ ភិន (តូច ភឿន) ត្រូវចាប់ខ្លួននៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៧ ។ ម៉ៃ សាខន ហៅ សំ ត្រូវចាប់ខ្លួននៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៧ ។ ចាន់ ចក្រី ហៅ មាន ត្រូវចាប់ខ្លួននៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦ ។ មិនដឹងថាតើមនុស្សប៉ុន្មាននាក់ទៀតដែលមាន ឈ្មោះនៅក្នុងចម្លើយសារភាពនេះ ក៏ត្រូវបានចាប់ខ្លួននិងកម្ទេច ដែរ ហើយមិនដឹងថាសមាជិកគ្រួសារទាំងមូលរបស់ ផល្លា

ត្រូវបានកម្ទេចចោលទាំងអស់ប៉ុយ៉ាងណា ។

គិតរហូតមកដល់ពេលដែល ផល្លា ត្រូវចាប់ខ្លួននៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ ការងាររមិនទាន់ទទួលបានលទ្ធផលអ្វីនៅឡើយទេ។ នៅពេលដែល ផល្លា ត្រូវបានចាប់ខ្លួនយកមកឃុំឃាំងនៅមន្ទីរស-២១ (ប្តុកទួលស្លែង) ផល្លា ពុំមានភាពស្រពិចស្រពិលអំពីជីវិតនិងអនាគតរបស់ខ្លួនឡើយ ។ ផល្លា មានជំនឿថា អង្គការមានហេតុផលគ្រប់គ្រាន់ក្នុងការចាប់ខ្លួនគាត់យកមកមន្ទីរសន្តិបាលនេះ ។ ប៉ុន្តែការដែល ផល្លា មិនជ្រះស្រឡះក្នុងអារម្មណ៍ គឺតាំងពីដើមរៀងរហូតមក ផល្លា មិនដែលនឹកស្មានសោះថាគាត់ត្រូវមកបញ្ចប់ជីវិតក្នុងមន្ទីរសន្តិបាលនេះ ។ នៅពេលសួរចម្លើយ សំណួរជាច្រើនធ្វើឲ្យ ផល្លា ស្រឡាំងកាំង ។ ចម្លើយរបស់ ផល្លា លើកដំបូងមានសភាពច្របូកច្របល់ ។ មានចំណុចជាច្រើនដែល ផល្លា មិនយល់រហូតថ្ងៃដែលអង្គការកម្ទេច ។ ផល្លា បានជំរាបអង្គការដោយស្មោះត្រង់ថា “ការដែលខ្ញុំស្តាយបំផុត គឺខ្ញុំលែងបានរួមធ្វើបដិវត្តន៍សង្គមនិយមទៀតហើយ ។ ខ្ញុំបានរួមធ្វើបដិវត្តន៍ដើម្បីសម្រេចសំណូមពរនេះក្នុងពេលមុន” ។

មានចំណាររមួយសរសេរលើខ្នងរូបថតមួយសន្លឹកជារូបថតរបស់ ទូន សុខផល្លា និង នួន ឃឿន ថា “ស្នើអ,ក (អង្គការ) ពិនិត្យ, ២១-១១-៧៦ ។ ១៩៧១ នៅសាលមហោស្រព ។ ១) ស្គាល់ ផល្លា នៅចុងឆ្នាំ១៩៧០ ២) មូលហេតុស្គាល់ ប៉ុក ផន នាំឲ្យស្គាល់ ។ ៣) ជិតស្និទ្ធនឹង ផល្លា តាំងពីចុង១៩៧១ ។” ឌុច ប្រធានមន្ទីរស-២១ ក៏បានចាររលើខ្នងរូបថតដដែលថា “បងជាទីគោរព! ដោយឃើញរូបនេះកាលនៅក្មេង ។ ចោទបញ្ហាថាតើពីរនាក់នេះស្គាល់គ្នាពីអង្កាល់ បើមួយនៅសៀមរាប មួយនៅកំពង់ចាម មួយគ្រូ មួយអ្នកបច្ចេកទេស ។ ឲ្យគេបញ្ជាក់ នួន ឃឿន វាឆ្លើយដូចចំណារខាងលើ ។ ដោយគោរព! ឌុច ១៨-១១-៧៦” ។ នៅលើចម្លើយសារភាពរបស់ ទូន សុខផល្លា មានចំណារថា “១) សុំថតឲ្យ១ច្បាប់ ២) សុំសួរវាតាមចំណារដែលខ្ញុំចាររខាងក្នុង, ២៦-២-៧៧” ។ ចំណារខាងក្នុងសរសេរថា “សួរអាឃួនពីរឿង កោក ឆាយ ថែម សួរអាសុខផល្លា ម៉េចវាដឹង កោក ឆាយ ចូលសេ.អ៊ី.អា? ភស្តុតាង?” ។

ក្រៅពីចំណារខាងលើនេះ នៅមានចំណារខ្លីៗជាច្រើនទៀតលើចម្លើយស្តីអំពីការទាក់ទងរវាង ទូន សុខផល្លា និង ឃួន ។

ទូន សុខផល្លា ត្រូវបានសួរចម្លើយដោយពួក I អ្នកសួរឈ្មោះ អឿន ឡោត និង អ្នកថតចម្លងឈ្មោះ ថា ។ ឯកសារចម្លើយសារភាពមានស្នាមមេដៃរបស់សាមីខ្លួន ។

**ឌួង សុភារិទ្ធិ**

## ពន្យល់ពាក្យខ្មែរក្រហម

◆ ***អាជ្ញា:*** *ជាបន្តាប់បញ្ញើរបៀបម្ចាស់ដីនិងកសិករ នាយទុននិងកម្មករ ។*

◆ ***នាម៉ឺន:*** *ធ្វើការគ្មានផែនការ ជួបអីធ្វើហ្នឹងមិនជិតស្និទ្ធ ប្រកបរបៀបរាជការសង្គមចាស់ ។*

◆ ***ការិយាល័យ:*** *មិនដាក់ស្តែង ដាច់ពីមូលដ្ឋាន ដាច់ពីមហាជន ។ ជួនកាលចុះជាប់មហាជនជារូបភាពហើយតែមិនដាក់ស្តែង មិនជិតស្និទ្ធជាខ្លឹមសារ ។*

◆ ***រាបសា:*** *ជឿជាក់លើកម្លាំងប្រជាជនមូលដ្ឋាន ពឹងផ្អែកលើប្រជាជនមូលដ្ឋាន ហើយដាក់កាយចិត្តឃោសនាអប់រំនិងកសាងកម្លាំងសម្ព័ន្ធភាពកម្មករ-កសិករ ។ គឺរាបសាជាមួយប្រជាជនមូលដ្ឋាន រាបសាជំហរជាសំខាន់មិនមែនត្រឹមតែជារូបភាព ។*

◆ ***នឹងនះ:*** *ក្នុងន័យចាស់ទុំខាងនយោបាយ និងក្នុងន័យទទួលខុសត្រូវចំពោះការចំណេញខាតរបស់បក្ស បដិវត្ត និងវណ្ណៈ និងចំពោះវាសនាប្រជាជន ។*

◆ ***ម៉ត់ចត់:*** *គឺខ្លួនឯងត្រូវម៉ត់ចត់ តឹងរ៉ឹង តែអាធ្យាស្រ័យឲ្យអ្នកដទៃ ។ ម្យ៉ាងទៀត ត្រូវគិតគូរដោះស្រាយគ្រប់បញ្ហាតាមសមូហភាពតាមខ្សែចាត់តាំងនឹងដោយថ្លឹងថ្លែងក្នុងស្មារតីទទួលសត្រូវចំពោះប្រជាជនមូលដ្ឋាន ។*

*(ទង់បដិវត្តន៍ លេខពិសេស)*

# បញ្ជីឈ្មោះជនបរទេសដែលបានកម្ទេចនៅមន្ទីរ ស-២១

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| លរ | នាម-គោត្តនាម | សញ្ជាតិ | មុខងារ | ចាប់មកពី | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ១២៧ | ង្វៀង ធូធៀង | យួន | ចោរព្រៃបីញញី | កំពង់សោម | ១៨-៤-៧៨ | ២៨-៤-៧៨ |
| ១២៨ | ង្វៀង ធីប៊ីប (ស្រី) | យួន | ប្រជាជន | បាជុក | ១៩-៤-៧៨ | ២៨-៤-៧៨ |
| ១២៩ | ដាម យ៉ាំងយ៍ | យួន | ប្រជាជន | បាជុក | ២២-៤-៧៨ | ២៨-៤-៧៨ |
| ១៣០ | ដូ យ៉ាំងកូ | យួន | ប្រជាជន | បាជុក | ២២-៤-៧៨ | ២៨-៤-៧៨ |
| ១៣១ | ង្វៀង យ៉ាំងវ៉ា | យួន | ប្រជាជន | បាជុក | ២២-៤-៧៨ | ២៨-៤-៧៨ |
| ១៣២ | ដូ យ៉ាំងគុង | យួន | ប្រជាជន | បាជុក | ២២-៤-៧៦ | ២៨-៤-៧៨ |
| ១៣៣ | ភូ វ៉ុកទីម | យួន | ប្រជាជន | កំពង់សោម | ១៨-៤-៧៨ | ២៨-៤-៧៨ |
| ១៣៤ | ង្វៀង យ៉ាំងញឹក | យួន | អតីតធីវគី | ឌឹកវ៉េ | ២៦-៤-៧៨ | ២៨-៤-៧៨ |
| ១៣៥ | ត្រឹង យ៉ាំងស៊ន់ | យួន | ស័ក្តិ២ | ម៉ុកវ៉ា | ៤-៣-៧៨ | ២៨-៤-៧៨ |
| ១៣៦ | ង្វៀន ធីជឺយ (ស្រី) | យួន | ប្រជាជន | ? | ?-១-៧៨ | ២៨-៤-៧៨ |
| ១៣៧ | ង្វៀង ធីសាង (ស្រី) | ? | ? | ? | ? | ២៨-៤-៧៨ |
| ១៣៨ | ង្វៀន ធីបាក់វ៉េ (ស្រី) | យួន | អ្នកចម្រៀង | កំពង់សោម | ១-៤-៧៨ | ៣០-៤-៧៨ |
| ១៣៩ | ង្វៀន ធីឡាន់ | យួន | ប្រពន្ធង្វៀងយ៉ាំងញឹក | ស្វាយរៀង | ២៧-៤-៧៨ | ៣០-៤-៧៨ |
| ១៤០ | ង្វៀង ធីញៀង | យួន | នៅរៀន | ស្វាយរៀង | ២៨-៤-៧៨ | ៣០-៤-៧៨ |
| ១៤១ | ង្វៀង ធីមុម | យួន | កងទ័ពយៀកកុង | និរតី | ? | ៣០-៤-៧៨ |
| ១៤២ | ង្វៀង ធីវ៉ាង (ស្រី) | យួន | ចារកម្មយួន | ស្វាយរៀង | ? | ២១-៤-៧៨ |
| ១៤៣ | ដាង ធីនី (ស្រី) | យួន | ចារកម្មយួន | ស្វាយរៀង | ? | ២១-៤-៧៨ |
| ១៤៤ | វ៉ី ធីឌុយ (ស្រី) | យួន | ចារកម្មយួន | កំពត | ? | ២១-៤-៧៨ |
| ១៤៥ | ត្រិន ធីឡេស៊ុន (ស្រី) | យួន | ចារកម្មយួន | កំពត | ? | ២១-៤-៧៨ |
| ១៤៦ | ណាំ ស៊ីវម៉េង (ស្រី) | យួន | ចារកម្មយួន | កំពត | ? | ២១-៤-៧៨ |
| ១៤៧ | ដាម ធីឡាង (ស្រី) | យួន | ចារកម្មយួន | កំពត | ? | ២១-៤-៧៨ |
| ១៤៨ | ដាញ់ ហេង | យួន | លោកសង្ឃ | ? | ១១-១១-៧៦ | ១២-៥-៧៧ |
| ១៤៩ | ដាច់ សូវ៉េ | យួន | ប្រជាជន | ? | ១០-១២-៧៦ | ១២-៥-៧៧ |
| ១៥០ | ចៅ វៀ | យួន | ? | ? | ៦-៥-៧៧ | ៧-៥-៧៧ |
| ១៥១ | ង្វៀង ចិនប៊ីន | យួន | គិញយួន | ស្រុកយួន | ៣១-៥-៧៧ | ២០-១០-៧៧ |
| ១៥២ | ចិន លី | យួន | គិញយួន | ស្រុកយួន | ៣១-៥-៧៧ | ២០-១០-៧៧ |

**(នៅមានត)**

# ក្បួនទ័ពព្រៃខ្មែរក្រហម

**(តចប់)**

### ៥៣) ធ្វើដំណើរទៅប្រយុទ្ធ

មុននឹងចេញទៅប្រយុទ្ធ មេពួកត្រូវស្តាប់បង្គាប់ដល់មេក្រុម ឬមេក្រុមរង តើគេចាត់ឲ្យចូលចេញបែបណាក្នុងវេលាប្រយុទ្ធនោះ មេពួកត្រូវត្រួតមើលកូនទាហានចំនួន៦នាក់ មេពួករងត្រូវត្រួតបាន៦នាក់ តែត្រូវនៅក្រោមបង្គាប់មេពួក ព្រមទាំងឲ្យដឹងអាវុធមានប៉ុន្មាន? អាវុធអ្វីខ្លះ? គ្រាប់កាំភ្លើង គ្រាប់បែកដៃមានប៉ុន្មាន? គ្រាប់អ្វីខ្លះ? ត្រូវឲ្យដឹងសព្វគ្រប់ ។

### ៥៤) វិធីចូលទៅរកខ្មាំង

ក្រុមត្រូវមើលទៅមុខឆ្វេងស្តាំ បើប្រទះខ្មាំងហើយ អ្នកបំភ្លឺផ្លូវធ្វើសញ្ញាឲ្យឡើងទៅ សឹមឡើង ។ ក្រុមនិងពួកឡើងស្មើអ្នកបំភ្លឺផ្លូវសឹមបាញ់ របៀបត្រូវឡើងទៅនោះគឺ២ពួកឡើងទៅមុខ ១ពួកទៀតបាញ់ផ្លាស់ប្តូរគ្នាទៅវិញទៅមក ។

### ៥៥) ផ្លាស់ប្តូរទីកន្លែង

ក្នុងសង្គ្រាមនីមួយៗត្រូវមានការផ្លាស់ប្តូរទីកន្លែងជាដរាប ព្រោះយើងមានជយដៃ ជួនកាលយើងមានជយដៃ ជួនកាលយើងរត់ដេញខ្មាំងឬបាញ់ជិតខ្មាំង មុននឹងផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយ គោងគិតជាមុនសិន ។

សេចក្តីគិតមាន៤យ៉ាង÷

១) ឯណា?

២) តាមណា?

៣) កាលណា?

៤) យ៉ាងដូចម្តេច?

សេចក្តីអធិប្បាយ÷

១) ពាក្យដែលថា «ឯណា»នោះ គឺយើងគិតថាឯណាមានដំបូកធំល្មមបិទបាំងខ្លួនបាន ។

២) «តាមណា» នោះគឺយើងមើលឃើញដើមឈើធំ ដំបូកធំ ហើយត្រូវចេញទៅតាមណា? ចេញផ្លូវវាលឬព្រៃដើម្បីកុំឲ្យខ្មាំងវាមើលឃើញ ។

៣) «កាលណា»? គឺយើងមើលផ្លូវឃើញហើយ តែពេលនោះខ្មាំងបាញ់ខ្លាំងណាស់ ចាំខ្មាំងស្រាកបាញ់សិនទើបទៅបាន ។

៤) «យ៉ាងដូចម្តេច» គឺយើងមើលផ្លូវចេញបានហើយ យើងត្រូវធ្វើដូចម្តេច ត្រូវលូន វារ បើឆ្ងាយពីខ្មាំងត្រូវរត់៤ឬ៥ជំហានក្រាបម្តង បើជិតខ្មាំងត្រូវដើរទាបឬលូនទើបផុតគ្រាប់ ។... ទៅពីកន្លែងមួយ គោងគិតជាមុន ។

សេចក្តីគិតមាន៤យ៉ាងគឺ÷

១) ឯណា?

២) តាមណា?

៣) កាលណា?

៤) យ៉ាងដូចម្តេច?

### ៥៦) លាក់ខ្លួនបំពួនអាត្មា

វិធីលាក់ខ្លួនបំពួនអាត្មានេះគឺជាមេចម្បាំងយ៉ាងធំដើម្បីបិទបាំងភ្នែកខ្មាំងនិងភ្នែកអាកាសយាន ហើយមើលខ្មាំងបានស្រួលផង ។

វិធីលាក់ខ្លួនមាន៥យ៉ាងគឺ÷

១) ត្រូវដឹងកន្លែងនាយចៅហ្វាយឬមេ

២) ត្រូវដឹងទិសបាញ់ទៅរកខ្មាំង

៣) ត្រូវបិទបាំងគ្រាប់ខ្មាំង

៤) ត្រូវបិទបាំងភ្នែកអាកាសយាន

៥) ត្រូវដឹងផ្លូវជយក្រោយនិងផ្លូវចូល បើត្រូវជយមិនត្រូវក្រោករត់តែម្តងទេ ត្រូវមើលឆ្វេង-ស្តាំ ១ពួកជយ ២ពួកបាញ់ ។

### ៥៧) វេលាចូលនិងជយ

គោងដាក់ទាហានយាមមុននឹងចូលក្តីចេញក្តី ត្រូវចាត់ពីរនាក់ឲ្យឈរយាមបែរមុខទៅឆ្វេង-ស្តាំ ទៅក្រោយ ចម្ងាយឃ្លាត

ពីគ្នា៥០ម៉ែត្រទៅ១០០ម៉ែត្រ ។

## ៥៨) ថយពីប្រយុទ្ធ

បើថយពីប្រយុទ្ធមកហើយ មេត្រូវផ្ដឹកពៃ្រប្រមូលទាហានតាមពួករបស់ខ្លួន ត្រួតមើលសេចក្ដីសុខទុក្ខ នឹងត្រួតមើលប្រដាប់អាវុធបាត់បង់ប៉ុចម្រើន គោងរាយការណ៍ឲ្យសព្វគ្រប់ឡើងទៅមេក្រុម ។ ការប្រជុំគ្នាត្រូវឲ្យឃ្លាតគ្នាពីមួយពួកទៅមួយពួកចម្ងាយ១០០ម៉ែត្រ ។ មុននឹងចូលទៅតស៊ូ មេត្រូវប្រាប់ទាហានទាំងអស់ឲ្យដឹងទីដែលត្រូវថយ បើថយពីនេះទៅ ទៅជួបគ្នាត្រង់ណា គោងរកទីណាដែលស្ងាត់ឆ្ងាយពីសត្រូវ ។

## ៥៩) រាយការណ៍ពួកយើងថយ

១) ពេលថ្ងៃណា?

២) ដោយហេតុអ្វី?

៣) ពួកយើងខូចខាតប៉ុន្មាននាក់?

៤) របួសប៉ុន្មាននាក់?

៥) អាវុធខូចខាតប៉ុន្មានដើម អ្វីខ្លះ?

៦) គ្រាប់បាញ់អស់ប៉ុន្មាន អ្វីខ្លះ?

៧) គ្រាប់បែកដៃចោលទៅប៉ុន្មាន អ្វីខ្លះ?

៨) នៅសល់ប៉ុន្មាន?

៩) ប្រដាប់ផ្សេងៗអ្វីខ្លះ?

មេក្រុមត្រូវបញ្ជូនរាយការណ៍ឡើងដល់មេប្រចាំកងទ័ពភាគ ។

## ៦០) របៀបរាយការណ៍ខ្មាំងថយ

១) បានចូលទៅប្រយុទ្ធនឹងខ្មាំងនៅនៅទីណា?

២) នៅថ្ងៃណា?

៣) ពេលម៉ោងប៉ុន្មាន?

៤) វាថយទៅវិញពេលថ្ងៃណា?

៥) ដោយហេតុអ្វី?

៦) ពួកវាស្លាប់ប៉ុន្មាននាក់?

៧) អាវុធបានពីវាប៉ុន្មានដើម? អាវុធអ្វីខ្លះ?

៨) គ្រាប់បែកដៃប៉ុន្មាន? គ្រាប់អ្វីខ្លះ?

៩) គ្រាប់កាំភ្លើងប៉ុន្មាន? គ្រាប់អ្វីខ្លះ?

១០) គ្រឿងប្រដាប់ផ្សេងៗអ្វីខ្លះ?

## ៦១) ធ្វើដំណើរ

ពេលធ្វើដំណើរទៅណាមកណាត្រូវធ្វើឲ្យមានរបៀប មិនត្រូវខ្លះទៅមុខខ្លះទៅក្រោយទេ ទាហានត្រូវស្ដាប់បង្គាប់ដល់មេ មេត្រូវប្រាប់កិច្ចការដល់កូន ÷

១) បើចេញដើរទៅហើយត្រូវមើលទៅមុខ ឆ្វេង ស្ដាំឲ្យសព្វគ្រប់ មិនត្រូវនិយាយគ្នា បើវេលាយប់មិនត្រូវជក់បារីប្ញុជុតភ្លើង ។

២) បើដើរផ្លូវឆ្ងាយត្រូវដើរចម្ងាយ៤គីឡូម៉ែត្រឈប់ម្ដងសម្រាក១៥មីនុតធ្វើដំណើរតទៅទៀត បើត្រូវការជក់ស៊ី ត្រូវចាត់ទាហានឲ្យទៅយាមចម្ងាយ១ប្ញុ២គីឡូម៉ែត្រ ទើបស៊ីជក់បាន ។

## ៦២) ឆ្លងព្រែក អូរ ស្ទឹង

ក្នុងមួយក្រុមត្រូវមានកាំបិតផ្គាក់៣ប្ញុ៤សម្រាប់កាប់ដើមឈើប្ញុរបស់អ្វីតាមត្រូវការ ព្រមទាំងមានចបកាប់ ចបប៉ែលសម្រាប់ដាក់កាំភ្លើងយន្ត ។

១) បើធ្វើដំណើរទៅប្រទះព្រែក អូរ ស្ទឹងណាដែលជ្រៅហើយគ្មានស្ពាន គ្រឿងប្រដាប់យើងក៏ធ្ងន់និងហែលឆ្លងពុំរួចត្រូវរកប្ញស្សីប្ញុឈើធ្វើក្បូន ។ បើគ្មាន យកវល្លិមកត្រកួញធ្វើខ្សែពួរធំៗចងទន្ទឹមគ្នាទទឹង១ហត្ថ ហើយយកឈើធ្វើរនាប៤ជ្រុងប៉ុនទទឹងនោះ ហើយចាត់ទាហានម្នាក់ឲ្យហែលនាំកន្ទុយពួរម្ខាងពីលើទឹកទៅត្រើយម្ខាង ហើយយកទៅព័ទ្ធនឹងដើមឈើធំ ។

២) បើកំពុងតស៊ូនៅត្រើយម្ខាងម្នាក់ ហើយចង់ដណ្ដើមយកទីពីខ្មាំងក៏ត្រូវធ្វើដូច្នេះដែរ តែគោងទុក២ពួកឲ្យនៅតស៊ូនឹងខ្មាំង ១ពួកទៀតត្រូវរត់ទៅពីលើទឹកយកកន្ទុយពួរទៅព័ទ្ធត្រើយម្ខាងដូចពោលខាងលើនេះ ហើយហែលឆ្លងទៅម្ដងម្នាក់ៗ ។ បើឆ្លងរួចហើយត្រូវបាញ់តស៊ូ ដើម្បីឲ្យពួកទី២ហែលឆ្លងទៅទៀត បើឆ្លងទៅហើយ ត្រូវរាយគ្នាឡោមតស៊ូតាមរបៀប ។

## ៦៣) តាំងទីលំនៅ

មេត្រូវតាំងទីកន្លែងនៅឈប់អាស្រ័យនៅពេលយប់ថ្ងៃក្ដីប្ញុនៅពេលឈប់សម្រាកក្ដី ពេលដណ្ដើមទីពីខ្មាំងបានក្ដី មេត្រូវជ្រើសរើសរកព្រៃសំងៀត មុននឹងតាំងកន្លែងនៅត្រង់ណាឲ្យមានផ្លូវចេញចូល មានចាត់ការយាមល្បាតគ្រប់ច្រកល្ហក ទីនោះត្រូវឲ្យឃ្លាតពីសមរភូមិ៤ប្ញុ៥គីឡូម៉ែត្រ មិនត្រូវឲ្យអ្នកស្រុកដឹង

ច្រើនគ្នា ការពារក្រែងខ្មាំងចាប់បាននឹងសួរយកការណ៍ពីក្រុម ។ យើងត្រូវហាមកុំឲ្យចូលទៅក្នុងភូមិស្រុក ឬដេកនៅបាយទឹកឲ្យសោះ ។ មុននឹងតាំងកន្លែងនីមួយៗត្រូវសាកសួរដេញដោលអ្នកស្រុកឲ្យច្បាស់លាស់ ÷

១) ចម្ងាយនាទីខ្មាំងប៉ុន្មានគីឡូម៉ែត្រ?

២) ទឹកមានច្រើនឬតិច?

៣) ត្រូវកាត់តម្រង់ទៅតាមផ្លូវណា? ផ្លូវរទេះភ្លើង ឬផ្លូវដើង ត្រូវឈប់កន្លែងនៅណាមានទឹកនិងព្រៃសំនៀត ។ ម្យ៉ាងទៀតបើវាយយកកន្លែងពីខ្មាំង គោងត្រួតត្រាមើលឲ្យសព្វគ្រប់ ហើយចាត់ទាហានយាមគ្រប់ច្រកទាំងអស់ រួចត្រួតមើលឆែកឆេរឲ្យគ្រប់ទីកន្លែងក្រែងមានអាវុធនៅសល់ គន់មើលសព្វគ្រប់តាមច្រកល្ហក ក្រែងខ្មាំងវាពួនចាំចាប់យើងឬចាប់មេ ត្រូវយកកាំភ្លើងយន្តដាក់ចំផ្លូវដែលខ្មាំងវារត់ចេញទៅ ចាត់ទាហានពីរនាក់ឲ្យយាមបែរមុខទៅក្រោយ ឆ្វេង ស្តាំ បើតាំងរួចហើយត្រូវរាយការណ៍បញ្ជូនពាក្យមកមេប្រចាំការកងទ័ព ដើម្បីឲ្យគេបានជ្រាបពីការតស៊ូរបស់ខ្លួន ។

## ៦៤) រាយការណ៍តស៊ូ

១) យកកាំភ្លើងពីខ្មាំងបាន ២) ដាក់កាំភ្លើងយន្តតម្រង់ទៅផ្លូវខ្មាំងចេញ ៣) ខ្មាំងស្លាប់... ៤) ចាប់ខ្មាំងបាន... ៥) បានអាវុធពីខ្មាំង... ៦) បានគ្រាប់ពីខ្មាំង... ៧) ប្រដាប់ប្រដាយកបានពីខ្មាំង... ៨) ពួកយើងស្លាប់... ៩) សុំគ្រាប់ថែម...១០) សុំទាហានជំនួយ... ១១) សុំគ្រាប់បែកថែម... ១២) សុំអាវុធជំនួយថែម... ។

## ៦៥) ឡើងភ្នំ ចុះភ្នំ

កាលបើយើងកំពុងតស៊ូនឹងខ្មាំង ហើយវានៅលើភ្នំ យើងនៅក្រោមភ្នំ តែយើងចង់ដណ្តើមយកទីរបស់វា ត្រូវបំបែកគ្នាជាពួកភ្លាមៗ ហើយចាត់ឲ្យមួយពួកគឺពួកទី១ បាញ់តស៊ូនឹងវាពីរពួកទៀតត្រូវរត់ទៅឆ្វេងឬស្តាំ ហើយរកផ្លូវឡើងទៅដោយស្រួល បើគ្មានផ្លូវឡើងទេ គោងរកវល្លិ៍ត្រកួញធ្វើជាខ្សែពួរធំ ហើយចាត់ឲ្យទាហានម្នាក់នាំកន្ទុយពួរម្ខាងឡើងទៅលើ កាលបើភ្នំនោះមានថ្មខ្ពស់ គោងឡើងជាន់បន្តៗគ្នាដើម្បីឲ្យទាហានម្នាក់



ឡើងគោងចាប់វល្លិ៍ឬឈើខាងលើបាន ។ កាលបើឡើងទៅដល់ខាងលើហើយ គោងយកកន្ទុយពួរនោះទៅចងនៅគល់ឈើធំឲ្យជាប់ ហើយទាហានឯទៀតប្រគោងឡើងម្នាក់ម្តងៗ លុះត្រាឡើងអស់ហើយត្រូវរាយគ្នាជាខ្សែបាញ់តស៊ូភ្លាម ដើម្បីឲ្យពួកនៅឯក្រោយឡើងតាមទៅជួយគ្នាទៀត ។

បើឡើងរួចទាំងអស់គ្នាហើយ គោងចាត់ការរាយគ្នាឡោមព័ទ្ធតាមរបៀប ។

## ៦៦) ដោះខ្លួនពីចំណោមខ្មាំង

កងទ័ពកាលបើធ្វើដំណើរទៅណាមកណា លុះដល់ពេលដេកឬពេលបរិភោគបាយ ត្រូវពួកខ្មាំងព័ទ្ធចាប់ មេត្រូវមានស្មារតីរឹងស្រែកឲ្យទាហានបំបែកគ្នាជាបីជ្រុងតស៊ូជាមួយខ្មាំង ។ កាលបើស៊ូពុំឈ្នះទេ ត្រូវណាត់គ្នាដោយសូរកញ្ចែឲ្យទាហានគ្រប់ពួកបុកសម្រុកចូល គឺពួកខាងជើងសម្រុកទៅខាងជើង ពួកខាងត្បូងសម្រុកទៅខាងត្បូង ឯពួកនៅឆ្វេងឬស្តាំត្រូវសម្រុកទៅឆ្វេងឬស្តាំឲ្យព្រមគ្នា ។

ឯកាំភ្លើងត្រូវប្រែកគ្រាប់ឲ្យស្រេច កាប៊ីនដាក់ចុងកាំភ្លើង អ្នកកាន់គ្រាប់បែកត្រូវដកកន្លះឲ្យស្រេច ហើយចោលគ្រាប់បែកទៅរកខ្មាំងជាមុន ទើបស្រែកទាំងសន្ធាប់ទាំងអស់គ្នាថា ចាក់! ចាក់! ឲ្យខ្លាំង រួចរត់ចាក់បាញ់សម្រុកទម្លុះខ្មាំងទើបរួចខ្លួន ។

បើទាហានយើងមានតែ៦នាក់ ក៏ត្រូវបំបែកម្ខាង២នាក់ៗ ធ្វើដូចខាងលើ ឬបើទាហានមានតែពីរនាក់វិញ ត្រូវពួតកម្លាំងគ្នារុញសម្រុកទៅមុខទំលាយខ្មាំង កុំតក់ស្លុតឲ្យសោះ ។

### កងឆ្មក់

កងឆ្មក់ត្រូវមានគ្នាយ៉ាងតិចត្រឹម៣នាក់ឡើងទៅដល់ ១៣នាក់ ក្នុងពួកនេះត្រូវមាន១នាក់ជាមេបង្គាប់បញ្ជា មើលការខុសត្រូវគ្រប់យ៉ាង ឯកាំភ្លើងត្រូវមានកាំភ្លើងល្អ និងកាំបិតស្នៀត គ្រាប់បែកគ្រប់ដៃ ព្រមនូវទៃអង្ករ-ឆ្នាំងបាយឲ្យស្រេចសម្រាប់ដាំបាយបរិភោគក្នុងព្រៃស្ងាត់ ហាមមិនឲ្យចូលក្នុងភូមិស្រុក មិនឲ្យអ្នកស្រុកដឹង ។

១) ត្រូវហាត់រៀនឲ្យចេះស្ទាក់ក្នុងវិធីកងឆ្មក់នេះ ចេះលុតក្រាប ចេះតម្រង់ឲ្យត្រង់ ចេះកាក់រយៈត្រឹមត្រូវ ព្រមនូវកាន់ច្បាប់ទម្លាប់សុចរិត យុត្តិធម៌ ។

២) កាលបើដឹងថាខ្មាំងវាចេញដើរតាមផ្លូវណាក្តី តិចឬច្រើន គោងរកព្រៃសំងៀតក្រាស់ក្រាបពួនកុំឲ្យខ្មាំងមើលឃើញ ត្រៀមតម្រង់ចាំបាញ់ឲ្យស្រេច លុះត្រាតែត្រង់ហើយទើបបាញ់សម្រុកទៅរកខ្មាំងសន្ធាប់ឲ្យវាតក់ស្លុត កាលបើវាដឹងខ្លួន ត្រូវភៀសគេចចេញ ហើយរត់ទៅចាំស្ទាក់ខាងមុខទៀត លុះត្រាតែវាខ្ចាត់ខ្ចាយ ឬបើវាត្រឡប់ទៅវិញក៏ត្រូវធ្វើដូចគ្នា បើធ្វើកងណាហើយ ត្រូវតាមឲ្យជាប់ កុំឲ្យគេចចោល ។

៣) បើសត្រូវវាឈប់សម្រាកដេកឬបាយទឹកនៅក្នុងទីណា ត្រូវព្យាយាមលបលូនឲ្យបានជិត ដើម្បីបាញ់ស្រួលឬចោលគ្រាប់បែកស្រួល បាញ់រត់សម្រុកចូលទៅរកវាកាលដែលវាពុំដឹងខ្លួនជាមុនដើម្បីយកអាវុធប្រដាប់ប្រដាវា កុំឲ្យខ្លាចស្លាប់ឲ្យសោះ ធ្វើយ៉ាងណាឲ្យតែវាអន្តរាយ ។

៤) កាលបើវាដឹងខ្លួនឬក៏វាប្រុងប្រយ័ត្ន យើងកុំធ្វើវាឲ្យសោះ រង់ចាំទុកឲ្យវាធ្វើដំណើរទៅមុខទៀតឡើយហត់អស់កម្លាំង ភ្លេចខ្លួនស្មានថាជាផុតពីសេចក្តីអន្តរាយហើយ សឹមយើងធ្វើវាទៀត ពុំនោះសោតកាលវាត្រូវរបួសឬសែងខ្មោចរបស់វាដែលយើងបាញ់ត្រូវនោះ ត្រូវព្យាយាមដើរតាមស្ទាក់បាញ់វាជាដរាប ។

៥) ព្យាយាមដឹកថ្នល់ កាត់ស្ពាន បណ្តាច់ខ្សែលួស បាញ់ស្ទាក់ឡានឬសេះដែលខ្មាំងវាជិះ ទោះបានក្តីមិនបានក្តីក៏ត្រូវតែធ្វើដើម្បីឲ្យវាវិនាសដោយសារយើង ។

៦) ត្រូវព្យាយាមរកផ្លូវត្រង់ ជីកត្រង់សេ ដាក់កាំភ្លើងយន្តចាំបាញ់ខ្មាំងដែលវាដើរជាជួរ នាទីមុខកាំភ្លើងយន្តនោះត្រូវដោតចម្រូងឲ្យពេញសង្ខាងផ្លូវបន្លំនឹងស្មៅឬដើមឈើ ចម្រូងនោះត្រូវលាបជ័រពិសនៅនោះឲ្យស្រេច លុះយើងបាញ់ទៅខ្មាំងគេចលូនក្រាបនឹងត្រូវស្លាប់ជាដាច់ខាត ឯរទេះឡានក៏ដូចគ្នា តែត្រូវដោតចម្រូងម្ខាងផ្លូវថ្នល់ ហើយត្រៀមបាញ់ម្ខាង និងពីមុខដើម្បីឲ្យខ្មាំងវាលោតទៅម្ខាងត្រូវចម្រូងស្លាប់ ។

៧) កងឆ្មក់ទាំងឡាយត្រូវខំព្យាយាមធ្វើតាមរបៀបនេះ ព្រោះសត្រូវខ្លាចយើងយ៉ាងអនេក ដោយសារពុំដឹងថាកន្លែងយើងនៅឯណាសោះ ស្រាប់តែដើរទៅត្រង់ណាក៏ជួបប្រទះនឹងយើងជាដរាប ។ **ចប់**

# ការដណ្ដើមមកវិញនូវព្រលឹងជាតិកម្ពុជា តាមរយៈមហាជ័យជំនះ ១៧ មេសា ១៩៧៥ ដ៏មហាអស្ចារ្យ

(សង្ខេបចេញពីឯកសារ D ២១៧/១១)

នាថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យបានប្រារព្ធពិធីបុណ្យខួបគម្រប់១ឆ្នាំនៃមហាជ័យជំនះរបស់ខ្លួន ។ ក្នុងឱកាសនោះ ថ្នាក់ដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យបានចេញផ្សាយបទខុទ្ទេសនាមមួយ ដើម្បីទទួលអំណរទិវាដ៏មហាអស្ចារ្យ ។ បទខុទ្ទេសនាមបានចាត់ទុកការដណ្ដើមជ័យជំនះនាថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ មិនត្រឹមតែជាជ័យជំនះតាមផ្លូវយោធាប៉ុណ្ណោះទេ តែក៏ជាការដណ្ដើមយកមកវិញនូវព្រលឹងជាតិកម្ពុជា ដែលបានបាត់បង់អស់តាំងពីរាប់ពាន់ឆ្នាំមកហើយ ដោយសារសក្ដិភូមិមូលធននិងចក្រពត្តិអាណានិគម ។ ខ្ញុំសូមដកស្រង់សង្ខេបខ្លឹមសារនៃបទខុទ្ទេសនាមមកជូនដូចខាងក្រោម ÷

"...តាមរយៈមហាជ័យជំនះ ១៧ មេសា ១៩៧៥ យើងដណ្ដើមបានមកវិញនូវព្រលឹងជាតិយើងដែលបាត់បង់ ដែលប្រែការឡែ រាប់ពាន់ឆ្នាំ រាប់រយឆ្នាំមកហើយ ។ ជាតិយើងគឺសំដៅជាតិកម្ពុជា ប្រជាជនកម្ពុជា ដែលមានទាំងជនជាតិខ្មែរទាំងជនជាតិផ្សេងៗដែលមាននៅតាមមូលដ្ឋាននានានៅទូទាំងប្រទេសយើង ពិសេសនៅខាងត្បូសាន ។ ទាំងអស់នេះហៅថា "ប្រជាជាតិកម្ពុជា" មានទឹកដីរបស់ខ្លួន មានសេដ្ឋកិច្ចរបស់ខ្លួន មានប្រពៃណីរបស់ខ្លួន មានវប្បធម៌ អក្សរសាស្ត្រ សិល្បៈរបស់ខ្លួន ។

ធាតុពិតនៃប្រជាជាតិកម្ពុជានេះត្រូវអន្តរាយខ្ទេចខ្ទីអស់ច្រើនណាស់ ។ ខ្លឹមសាររបស់វានេះក៏ត្រូវខ្ទេចខ្ទីរលំរលាយនៅតែសំបក ។ យើងម្នាក់ៗនៅថាជាកម្ពុជា ហៅថាជាខ្មែរ ហៅថាជាជនជាតិទំពួន ចារាយ កាចក់ លាវ ថៃ គួយ អីផ្សេងៗ នៅតាមជនបទនានានៅក្នុងក្របខណ្ឌនៃប្រជាជាតិកម្ពុជាយើង ។ យើងហៅថាជាខ្មែរតែសំបក ឯខ្លឹមសារអត្ថរសរបស់វាដែលយើងហៅថាព្រលឹងរបស់ជាតិយើង អត្តភាពរបស់ជាតិ វាត្រូវបាត់បង់អស់សឹងតែរលីងសូន្យនៅតែសំបក ។ សក្ដិភូមិម្ចាស់ដីព្រលឹងជាតិគ្មានទេ គ្មានស្មារតីស្រឡាញ់ជាតិស្រឡាញ់ប្រទេស ការពារទឹកដី ព្រៃព្រឹក្សា ពេញចិត្តពេញថ្លើមនឹងទឹកដីឯង គ្មានទេ ។ នឹកឃើញតែអ្វីដែលជារបស់បរទេសរបស់ចក្រពត្តិ ។ នេះហើយដែលហៅថាបាត់ព្រលឹងជាតិ ។ ព្រលឹងផ្សេងៗមិនជារបស់ជាតិកម្ពុជា វាចូលមកក្នុងខ្លួនវិញ ។


កងទ័ពខ្មែរក្រហមដណ្ដើមកាន់កាប់អគ្គសេនាធិការយោធារបស់ លន់ ណុល

ពាក់យីហោជាកម្ពុជា ។ ក៏ប៉ុន្តែខ្លឹមសារទស្សនៈគោលជំហរជាចក្រពត្តិ ជាប្រតិកិរិយា ។

វណ្ណៈអនុធនម្យ៉ាងថាមានស្មារតីស្នេហាជាតិដែរ ។ ក៏ប៉ុន្តែក្នុងឋានៈខ្លួនដែលស្ថិតនៅក្នុងសង្គមខ្ញុំគេក្នុងសង្គមអាណានិគម និងពាក់កណ្តាលអាណានិគម ចង់មិនចង់គឺព្រលឹងជាតិក៏ត្រូវបាត់បង់អស់ដែរ ។ ឯវណ្ណៈកម្មករ-កសិករនៅរក្សាធាតុជាតិច្រើនជាងគេ ពីព្រោះមិនសូវបានទទួលឥទ្ធិពលពីចក្រពត្តិ នៅឆ្ងាយវាទៅមិនសូវដល់ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏អស់ព្រលឹងជាតិមួយចំនួនដែរ ពីព្រោះចក្រពត្តិ តាមរយៈដៃជើងរបស់វា វាស្រូបជញ្ជក់ឈាមកសិករយើងនៅចុងកាត់មាត់ញកខាងសេដ្ឋកិច្ចអស់រលីង នាំឲ្យកសិករយើង ទោះជានៅចុងកាត់មាត់ញកក៏ដោយ អស់គិតគូរមិនសូវគិតគូរពីបញ្ហាស្រឡាញ់ទឹកដីស្អីទៀតទេ គិតគូរយ៉ាងម៉េចឲ្យតែបានអង្ករមួយឆ្អែត យ៉ាងម៉េចឲ្យតែបានលុយបង់ការ ។ តាមសភាពការណ៍ដែលគេជិះជាន់យ៉ាងនេះ ខ្លួនឯងជាកសិករនៅចុងកាត់មាត់ញកដែលខ្វះខាតដែលក្រីក្រក៏ពុំអាចគិតអំពីទឹកដីរបស់ខ្លួនដែរ ។

ដូច្នេះ វណ្ណៈណាក៏ដោយ ក្នុងក្របខ័ណ្ឌនៃប្រទេសដែលនៅខ្ញុំគេនឹងពាក់កណ្តាលខ្ញុំគេ សុទ្ធតែត្រូវខូចខាតនូវព្រលឹងជាតិរបស់ខ្លួន ទោះជាតិចក្តីច្រើនក្តី សុទ្ធតែត្រូវអន្តរាយតាមវណ្ណៈនីមួយៗ តាមប្រភេទនីមួយៗ ។ ព្រលឹងជាតិរបស់យើងត្រូវបាត់បង់ ត្រូវរលំរលាយ ត្រូវសាបសូន្យជាច្រើន ត្រូវប្រែកាឡៃជាច្រើន ។ ហើយបើទុក១០ឆ្នាំ ២០ឆ្នាំ ៣០ឆ្នាំទៀត ព្រលឹងជាតិនេះមុខជាបាត់ហើយ ។ បាត់ម្យ៉ាងគឺបាត់ទឹកដី ។ បាត់ម្យ៉ាងទៀតគឺបាត់ព្រលឹង បាត់ធាតុពិតរបស់យើង ។ យូរៗទៅវាទៅជាអាមេរិក ព្រលឹងជាតិរបស់ខ្លួនបាត់អស់រលីង ។ ដូច្នេះហើយបានជាគ្រប់ស្រទាប់វណ្ណៈ មិនឃើញទឹកដីរបស់ខ្លួនស្រស់ប្រិមប្រិយទេ ។ អស់ស្រស់ប្រិមប្រិយមកពីអ្វី? មកពីព្រលឹងជាតិវាខ្សោយខ្សែវទៅ វាកាន់តែអស់ទៅ ។ ដូច្នេះឃើញអ្វីៗផ្សេងៗក្រៅពីជាតិវាស្រស់ប្រិមប្រិយ ។ វប្បធម៌ក្រៅពីជាតិវាស្រស់ប្រិមប្រិយ ។ សិល្បៈក្រៅពីជាតិវាស្រស់ប្រិមប្រិយ ។ ទំនៀមទម្លាប់ក្រៅពីជាតិវាស្រស់ប្រិមប្រិយ ។ ឃើញអក្សរសាស្ត្រកវីនិពន្ធបរទេសរបស់ចក្រពត្តិវាស្រស់ប្រិមប្រិយ ។ ភ្នំព្រៃព្រឹក្សារបស់បរទេសវាស្រស់ប្រិមប្រិយ ។



ប្រែកាឡៃយ៉ាងនេះមិនមែនមកពីប្រជាជនយើងទេ ។ គឺមកពីសភាពការណ៍សត្រូវានុម័តិដែលខ្លាំងវាជិះជាន់ ចក្រពត្តិជិះជាន់រាប់ជំនាន់យ៉ាងនេះ នាំឲ្យប្រែក្លាយព្រលឹងជាតិយ៉ាងនេះ ។ បញ្ហានេះជាបញ្ហាធំ ជាបញ្ហាព្រលឹង ។ បាត់បង់ព្រលឹងជាតិ បាត់ធាតុពិតរបស់ជាតិវាគ្រោះថ្នាក់ណាស់ វាជាមូលដ្ឋាន ។

ប៉ុន្តែថ្ងៃ ១៧ មេសា ដែលជាលទ្ធផលនៃចលនាបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យរបស់យើង ទទួលបានមហាជ័យជំនះមហាអស្ចារ្យ ។ តាមរយៈមហាជ័យជំនះនេះ ព្រលឹងជាតិកម្ពុជាដែលបាត់បង់ទៅ ដែលរលុះរលាយទៅ ដែលប្រែកាឡៃទៅ ត្រូវបានដណ្តើមមកវិញទាំងស្រុង ក្នុងន័យព្រលឹងជាតិរបស់ប្រជាជននិងចម្រើន មិនមែនព្រលឹងជាតិរបស់វណ្ណៈជិះជាន់ចាស់គំរឹលនិងប្រតិកិរិយាទេ ។ ដូច្នេះយើងឃើញទឹកដីយើងស្រស់ប្រិមប្រិយវិញហើយ ។ ឥឡូវខែប្រាំងក៏ស្រស់ប្រិមប្រិយដែរ មិនបាច់ខែវស្សាទេ ។ មកពីគោលជំហរ មកពីព្រលឹងជាតិបានចូលទៅស្ថិតនៅវិញក្នុងសតិអារម្មណ៍ ចូលក្នុងទស្សនៈ ចូលទៅក្នុងសាច់ឈាមយើង ចូលទៅក្នុងសរសៃសរស្លូងយើងគ្រប់គ្នា បានជាយើងឃើញទឹក ឃើញដី ឃើញព្រៃព្រឹក្សា អូរបឹងបួ អ្វីៗទាំងអស់ សុទ្ធតែស្រស់ប្រិមប្រិយ ខែចេត្រក៏ដោយ ខែផល្គុនក៏ដោយ សុទ្ធតែស្រស់ប្រិមប្រិយ ។ យើងពេញចិត្តពេញថ្លើម យើងមានមោទនភាពចំពោះប្រជាជនខ្លួន ចំពោះប្រជាជាតិខ្លួន ចំពោះទឹកដីខ្លួន ។ អ្វីៗទាំងអស់ប្រែក្លាយក្រឡាប់ចាក់ជាទស្សនៈ ជាគោលជំហរ ជាមនោសញ្ចេតនា ។ ដូច្នេះយើងដណ្តើមព្រលឹងជាតិបានមកវិញហើយ ហើយយើងកំពុងពង្រីកកម្លាំងនេះឲ្យបានខ្លាំងក្លា ឲ្យបានមាំទាំថែមទៀត ។ អត្តភាពជាតិដែលពីដើមវារោគាត់រោគាយប្របូកប្របល់មិនដឹងស្អីជាស្អី ឥឡូវប្រមូលនិងប្រមុំផ្តុំមកទៅជាអត្តភាពរបស់ជាតិមួយ ទៅជាជាតិមួយឯកភាពរបស់ខ្លួន ។ ដូច្នេះយើងដណ្តើមបានជ័យជំនះប្រជាជាតិនេះមិនមែនដណ្តើមបានតែដីទេ ។ ដីក៏ដណ្តើមបាន ។ ទស្សនៈគោលជំហរព្រលឹងដែលជាដង្ហើមចេញចូលនៃប្រជាជាតិយើងក៏យើងដណ្តើមបាន ។ នេះជាជ័យជំនះដ៏មហិមាណាស់ ។ ទោះយើងមិនទាន់មានអី មិនទាន់មានកប៉ាល់ហោះ កប៉ាល់ទឹកក៏ដោយ ក៏យើងជឿជាក់លើទឹកដីរបស់យើង លើប្រជាជាតិយើង លើប្រជាជនយើង ។ សូម្បីតែក្តៅហែងក្នុងខែផល្គុន ក្នុងខែចេត្រក៏ដោយ ក៏ឃើញដុំដីដែលទើបនឹងកាប់គាស់ ឃើញអាចម៍បំណះរបស់ស្រែយើងដែលទើបនឹងភ្ជួរ ស្រស់ប្រិមប្រិយដែរ ពីព្រោះយើងជឿជាក់ថាដីនេះវាបានផលកែប្រែជីវភាពរបស់ប្រជាជនយើង ។ ដីនេះមុខជាកសាងប្រទេសយើងឲ្យបានសំបូរសប្បាយ ។ ដីនេះនឹងការពារប្រទេសយើងឲ្យខ្លាំងក្លា ។ ស្រស់ប្រិមប្រិយយ៉ាងនេះមិនមែនស្រស់ប្រិមប្រិយដោយតុបតែងយកបូក្រហមទៅចងនឹងដុំដីទេ ។ ស្រស់ប្រិមប្រិយជាគោលជំហរ ស្រស់ប្រិមប្រិយជាទស្សនៈ ដោយមានជំនឿជឿជាក់លើភោគផលដែលកប់នៅក្នុងដីនេះ ។

នេះហើយហៅថាព្រលឹង ព្រលឹងនេះវាកើតវិញហើយ ។ វាកើតតាមរយៈការតស៊ូបដិវត្តន៍យើង ។ ព្រលឹងនេះកើតឡើង ទស្សនៈគោលជំហរនេះកើតឡើងនៅក្នុងបក្ស នៅក្នុងកងទ័ព នៅក្នុងប្រជាជន នៅក្នុងជួរយើងទាំងអស់គ្នា ។ ជំនឿនេះវាទៅជាកម្លាំង ហើយកម្លាំងនេះខ្លាំងក្លាណាស់ ។ កម្លាំងប្រជាជនធ្វើអ្វីក៏បានដែរ ប្រែក្លាយទឹកដីកម្ពុជារបស់ខ្លួនឲ្យទៅជាស្អីក៏បាន ។

បើពិនិត្យពីប្រវត្តិសាស្ត្ររបស់យើងដល់ថ្ងៃនេះមានព្រឹត្តិការណ៍មហាអស្ចារ្យបីដែលសកលលោកស្ញប់ស្ញែងហើយនឹងស្ញប់ស្ញែងតទៅទៀត ÷

◆ជំនាន់មុនគេនិយមអំពីស្នាដៃមហាអស្ចារ្យនៃសម័យអង្គរ ។ ក៏ប៉ុន្តែយើងមិនសូវមានមោទនភាពប៉ុន្មានទេ ពីព្រោះប្រជាជនកាលណោះនៅក្នុងរបបទាសៈកសិកម្ម ។

◆រឿងមួយទៀតដែលមហាអស្ចារ្យជាងអង្គរទៅទៀតគឺមហាជ័យជំនះ ១៧ មេសា ១៩៧៥ ។ នេះជាព្រឹត្តិការណ៍ធំសម្បើមណាស់ សកលលោកស្ញប់ស្ញែង រៀនសូត្រ គោរពកោតសរសើរ ។ មិនមែនកោតសរសើរដោយបញ្ជោរបញ្ចើចបញ្ចើទេ ។ គេកោតសរសើរដោយរាបសា ដោយគោរព ហើយរៀនសូត្រពីវីរភាពរបស់ប្រជាជនយើង របស់កងទ័ពបដិវត្តយើង ។ គេរៀនសូត្រអំពីចលនាបដិវត្តយើង អំពីមហាជ័យជំនះ១៧មេសារបស់យើង ។

◆ ឥឡូវរឿងថ្មីមួយទៀតដែលយើងកំពុងធ្វើ ហើយដែលយើងជឿជាក់ថានឹងមានស្នាដៃល្អជាងអង្គរ និងអស្ចារ្យមិនចាញ់ ១៧មេសាទេ គឺមហាចលនាបដិវត្តន៍ប្រែក្លាយជនបទប្រទេសកម្ពុជាឲ្យទៅជាសួនច្បារ ។ គឺសួនច្បារដែលមានដំណាំយុទ្ធសាស្ត្រផ្សេងៗ ប្រែក្លាយតាមចលនាមហាលោតផ្លោះមហាអស្ចារ្យ ។

បញ្ហាមានពីរៈ មួយកម្លាំងមហាជនខ្លាំងក្លា ។ កម្លាំងដែលកប់រាប់ពាន់រាប់រយឆ្នាំមកហើយ ត្រូវគាស់ឡើងឲ្យផុលផុសទៅជាចលនាខ្លាំងក្លាណាស់ ។ បញ្ហាមួយទៀតគឺព្រលឹងដែលជឿជាក់លើជាតិខ្លួន ដែលជឿជាក់លើទឹកដីរបស់ខ្លួន ដែលជឿជាក់លើប្រជាជនខ្លួន បានកកើត បានពង្រឹង និងកំពុងពង្រីកនៅក្នុងជួរយើងទាំងអស់ នៅក្នុងជួរប្រជាជន នៅក្នុងបក្សយើង នៅក្នុងកងទ័ពយើងទាំងអស់ ។ ដូច្នេះ ធាតុទាំងពីរនេះ ធាតុកម្លាំងប្រជាជននឹងធាតុព្រលឹងជាតិនេះ ដែលប្រមូលនិងប្រមុំផ្តុំបានមកវិញនេះ វាទៅជាកម្លាំងខ្លាំងក្លាណាស់ ធ្វើអ្វីក៏បានទាំងអស់ ។

មិត្តកូរ៉េគាត់ថាស្រុកគាត់មានមហាចលនាមួយឈ្មោះថា "ឈីលីម៉ា" ។ ឈីលីម៉ាគឺសេះហោះ ល្បឿនកសាងប្រទេសដូចជាសេះហោះលឿនណាស់ ។ ប៉ុន្តែគាត់មកសួរយើង ហើយគាត់មកប្រាប់យើងថា មិត្តកម្ពុជាគ្មានឈីលីម៉ា គ្មានសេះហោះទេ ប៉ុន្តែលឿនជាងសេះហោះកូរ៉េទៅទៀត ។

ត្រង់នេះហើយហៅថាជំនឿ ជាជំនឿលើរបប ។ ខ្មាំងចង់ឃោសនាយ៉ាងម៉េចក៏ដោយ ក៏ប៉ុន្តែប្រជាជនមានជំនឿលើរបបហ្នឹងដែលត្រឹមត្រូវ ។ របបហ្នឹងដែលជួយដល់ការកសាងប្រទេស ដែលជួយដល់ការការពារប្រទេសបានស័ក្តិសិទ្ធិបំផុត និងល្អបំផុត ។ ទាំងអស់នេះហើយដែលខ្ញុំសូមជំរាបបញ្ជាក់ថា ព្រលឹងជាតិបានកកើតហើយ ។ ព្រលឹងជាតិដែលជឿជាក់លើជាតិរបស់ខ្លួន ដែលជឿជាក់លើប្រជាជនខ្លួន ជឿជាក់ដល់ចលនាជាក់ស្តែង ជឿជាក់ដោយឃើញសភាពការណ៍ជាក់ស្តែង ។ នេះជាជ័យជំនះរបស់ប្រជាជាតិយើងធំណាស់ ដែលយើងមានភារកិច្ចពង្រីងវាតទៅទៀត ។ យើងមានភារកិច្ចពង្រឹងនឹងពង្រីកដើម្បីប្រែក្លាយប្រជាជាតិយើង ទឹកដីយើងឱយសំបូរសប្បាយ ឱយស្រស់បំព្រងជាក់ស្តែងមែនទែន ។ ស្រស់បំព្រងជាទស្សនៈ ជាគោលជំហរ ។

ដូច្នេះយើងរៀនសូត្រអំពីជ័យជំនះនេះ រៀនសូត្រជ័យជំនះអំពីព្រលឹងជាតិ ។ នេះជាការរៀនសូត្រ ហើយជាពិសោធន៍មួយថ្មីក្នុងសកលលោក ។ ពីព្រោះមិត្តសកលលោកគេមករៀនសូត្រពីកម្ពុជា មិនមែនមករៀនសូត្រពីកប៉ាល់ហោះឬអ្វីៗដែលសំបូរបែបទេ ។ គេរៀនសូត្រពីគោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន កាន់កាប់វាសនាខ្លួនដោយខ្លួនឯង របស់បដិវត្តយើង ។ នេះក៏ជាខ្លឹមសារមួយនៃព្រលឹងជាតិយើង ។ មិនបាច់ពឹងពាក់បក្រពត្តិ មិនបាច់ពឹងពាក់នរណាទេ គឺធ្វើខ្លួនឯងបាន ។..."

តាមរយៈខ្លឹមសារសង្ខេបនៃបទខុទ្ទេសនាមខាងលើ យើងឃើញថា ខ្មែរក្រហមបានលើកតម្កើងរបបដែលខ្លួនគ្រប់គ្រងថាអស្ចារ្យលើសរបបណាៗទាំងអស់ តាមរយៈគោលនយោបាយមហាលោតផ្លោះមហាអស្ចារ្យដែលប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាសួនដំណាំយុទ្ធសាស្ត្រគ្រប់ប្រភេទ សូម្បីសម័យមហានគរដែលមានការរីកចម្រើនខាងវិស័យកសិកម្មដល់កំពូល ក៏នៅចាញ់របបកម្ពុជាប្រជាធិបតេយ្យដែរ ។ មិនតែប៉ុណ្ណោះសោតដោយការគោលនយោបាយមហាលោតផ្លោះមហាអស្ចារ្យបូករួមនឹងគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនធ្វើម្ចាស់លើជោគវាសនាខ្លួនឯង ធ្វើឲ្យខ្មែរក្រហមគិតថា កម្ពុជាប្រជាធិបតេយ្យអាចកសាងប្រទេសបានរីកចម្រើនឆាប់រហ័សជាងបណ្តាប្រទេសមួយចំនួន ហើយត្រូវបានសកលលោកកោតស្ងប់ស្ងែងនិងរៀនសូត្រតាមថែមទៀត ។

ព្រលឹងជាតិកម្ពុជាដែលខ្មែរក្រហមចាត់ទុកថាបានបាត់បង់តាំងពីយូរមកហើយនោះ តាមពិតត្រូវបាត់បង់អស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះឯង មិនតែប៉ុណ្ណោះថែមទាំងបាត់បង់ជីវិតប្រជាជនកម្ពុជាអស់ជាងពីរលាននាក់ទៀតផង ។

**សាន់ កល្យាណ**

## ពាក្យស្លោកខ្មែរក្រហម

◆ **ប្តេជ្ញាដើរតាមបក្សដោយឥតលក្ខខណ្ឌ។**

◆ **បក្សនេះហើយជាអ្នករំដោះប្រជាជនកម្ពុជាឱ្យរួចផុតពីការជិះជាន់នានា កសាងកម្ពុជាជាថ្មី។**

(កំណត់ហេតុលេខ១១៥)

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៥០០ | ដេត ដេន | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥០១ | សំ ឃីត | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥០២ | ថាំ ម៉ាឡាក | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥០៣ | ឈុត តា | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥០៤ | វី ឆៃ | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥០៥ | សា ហាត់ | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥០៦ | វិឆៃ | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥០៧ | ចាន សុំ | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥០៨ | ឡេក | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | ឈឺស្លាប់ |
| ៥០៩ | ចាន សុំ | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥១០ | ស្រ៊ីត ការ | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥១១ | ខឹម | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥១២ | ដេង | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥១៣ | យុតដុង | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥១៤ | ឆឹត | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥១៥ | ឡាក | ?? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | |
| ៥១៦ | ទា ហៅ តឹក | សាធារណការ | តំបន់២៥ | ២២-២-៧៦ | ២៥-៥-៧៦ | |
| ៥១៧ | សំ ស៊ិនថៃ | វិស្វករកសិកម្ម | តំបន់៣២ | ២២-២-៧៦ | ២៥-៥-៧៦ | |
| ៥១៨ | ពៅ យុន | គ្រូ | ពោធិសាត់ | ៥-៤-៧៦ | ២៥-៥-៧៦ | |
| ៥១៩ | ជា វ៉ាន់នី | កូនសិស្ស | ព្រះនេត្រព្រះ | ៩-៤-៧៦ | ២៥-៥-៧៦ | |
| ៥២០ | ជិន ហឿន | ?? | បាត់ដំបង | ៩-៤-៧៦ | ២៥-៥-៧៦ | |
| ៥២១ | ហៀង គឹមស្រេង | កម្មករ | រោងចក្រទឹកដោះគោ | ១១-៥-៧៦ | ២៦-៥-៧៦ | |
| ៥២២ | កុយ សារឿន ហៅ នីម៉ុងនៀវ | ពេទ្យ | រកាកោង | ២១-៥-៧៦ | ២៦-៥-៧៦ | |
| ៥២៣ | ប៊ិក ប្រាហ៊ីម | ទាហាន | កោះធំ | ២៤-១-៧៦ | ២៦-៥-៧៦ | |
| ៥២៤ | សំរិត ឡាំញៀង | ទាហាន | កណ្តាលស្ទឹង | ២៤-១-៧៦ | ២៦-៥-៧៦ | |
| ៥២៥ | ចាន់ សួន | ធ្មើបម្ការ | កំពង់សោម | ?? | ២៦-៥-៧៦ | ឈឺស្លាប់ |

(នៅមានត)



# មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ

## ការចងចាំរបស់កុមារីកម្ពុជាម្នាក់

ល្បឿង អ៊ឹង

**ភ្នំពេញ**

**ខែមេសា ឆ្នាំ១៩៧៥**

ជីវិតទីក្រុងភ្នំពេញបានចាប់ផ្តើមតាំងពីព្រលឹម ដើម្បីស្រូបយកដំនោរត្រជាក់មុនពេលដែលព្រះអាទិត្យចែងចាំងកម្តៅដ៏ក្តៅហែងមកលើផែនដី ។ នៅវេលាម៉ោងប្រាំមួយព្រឹក អ្នកនៅភ្នំពេញកំពុងតែដើរញាប់ដៃញាប់ជើងប៉ះគ្នាទៅវិញទៅមកនៅតាមបណ្តោយផ្លូវតូចៗដែលគ្របដណ្តប់ទៅដោយធូលី ។

អ្នកបម្រើតុប្រុសស្រីក្នុងសម្លៀកបំពាក់ខ្មៅ-ស ដើរបង់បោយចុះឡើងៗនៅខាងមុខហាង ក្នុងខណៈពេលដែលក្លិនឈ្ងុយនៃគុយទាវស្ងោគមន៍ភ្ញៀវដែលកំពុងរង់ចាំ ។ នៅលើចិញ្ចើមថ្នល់ អ្នកលក់អីវ៉ាន់កំពុងរុញរទេះចំណីចំណុកដែលផ្ទុកទៅដោយនំប៉ាវ សាច់គោអាំងដោតចង្កាក់ និងសណ្តែកដីលីង ។ កូនក្មេងពាក់អាវយឺតពណ៌ចម្រុះ និងស្លៀកខោជើងខ្លី កំពុងទាត់បាល់តាមចិញ្ចើមថ្នល់ដោយជើងទទេ គ្មានរវល់នឹងសម្រែកពពាយនាយរបស់អ្នករុញរទេះលក់ចំណីបន្តិចឡើយ ។ មហាវិថីដ៏ធំទូលាយពោរពេញទៅដោយសំឡេងងើងៗនៃម៉ាស៊ីនទោចក្រយានយន្ត សំឡេងង៉ឺតៗនៃទោចក្រយាន ហើយសម្រាប់អ្នកដែលមានទ្រព្យសម្បត្តិគ្រាន់បើ គឺគេជិះរថយន្តតូច ។ នៅវេលាថ្ងៃត្រង់ ដោយហេតុថាអាកាសធាតុឡើងរហូតដល់ជាង៣៧អង្សាសេ ផ្លូវថ្នល់បានចាប់ផ្តើមស្ងាត់ទៅវិញបន្តិចម្តងៗ ។ មនុស្សម្នាប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះដើម្បីគេចចេញពីកម្តៅថ្ងៃ ដើម្បីញ៉ាំបាយថ្ងៃត្រង់ ផ្ទូតទឹកត្រជាក់ និងដើម្បីគេងមួយស្រឡេតមុននឹងត្រឡប់ទៅធ្វើការវិញនៅម៉ោងពីររសៀល ។

គ្រួសាររបស់ខ្ញុំរស់នៅលើផ្ទះល្វែងជាន់ទីបីចំកណ្តាលទីក្រុងភ្នំពេញ ដូច្នេះខ្ញុំស៊ាំនឹងចរាចរណ៍និងសំឡេងទ្រហឹងអឺងកងទៅហើយ ។ យើងមិនមានភ្លើងសញ្ញាចរាចរណ៍នៅតាមដងផ្លូវទេ ប៉ុន្តែមានប៉ូលិសឈរធ្វើសញ្ញាបញ្ជាចរាចរណ៍នៅលើប្រអប់ដែកមួយចំកណ្តាលផ្លូវបំបែកជាបួន ។

ទោះជាយ៉ាងនេះក៏ដោយ ក៏មើលទៅទីក្រុងនៅតែមានស្ទះចរាចរណ៍ជានិច្ច ។ យានជំនិះដែលខ្ញុំចូលចិត្តជិះដើម្បីធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀតជាមួយម៉ាគឺស៊ីក្លូ ពីព្រោះអ្នកធាក់ស៊ីក្លូអាចបញ្ចៀសស៊ីក្លូរបស់គាត់ឲ្យចេញពីចរាចរណ៍ដ៏ចង្អៀតបាន ។ ស៊ីក្លូគឺជារទេះកង់ពីរដែលតភ្ជាប់ទៅកង់ខាងក្រោយមួយទៀត ។ អ្នកគ្រាន់តែអង្គុយលើវាហើយបង់លុយឲ្យអ្នកធាក់ អ្នកធាក់ស៊ីក្លូនឹងដឹកអ្នកទៅគ្រប់កន្លែងដែលអ្នកចង់ទៅ ។

ទោះបីជាយើងមានរថយន្តតូចពីរ និងរថយន្តដឹកទំនិញមួយទៀតក៏ដោយ ក៏ជារឿយៗពេលដែលម៉ាយកខ្ញុំទៅផ្សារជាមួយ យើងតែងតែជិះស៊ីក្លូជានិច្ច ពីព្រោះយើងអាចទៅកន្លែងដែលយើងចង់ទៅលឿនជាងយើងជិះរថយន្ត ។ ខ្ញុំអង្គុយញញាក់ញញ័រលើភ្លៅរបស់ម៉ា ហើយខ្ញុំសើចនៅពេលដែលអ្នកធាក់ធាក់ស៊ីក្លូតាមផ្លូវដ៏ចង្អៀតនៃទីក្រុង ។ នាពេលព្រឹកនេះ ខ្ញុំនៅអង្គុយជាប់ក្នុងកៅអីភ្ជាក់ដៃធំមួយក្នុងហាងគុយទាវមួយដែលនៅឆ្ងាយពីផ្ទះរបស់យើងមួយសង្កាត់ ។ ខ្ញុំគួរតែនៅលេងលោតមឹកជាមួយមិត្តភក្តិរបស់ខ្ញុំវិញ ជាជាងមកអង្គុយនៅកន្លែងនេះ ។

អង្គុយលើកៅអីភ្នាក់ដៃធំតែងតែធ្វើឲ្យខ្ញុំចង់លោតលេងលើវា ។ ខ្ញុំស្អប់វាពេលដែលជើងខ្ញុំផុតដីហើយសំយុងចុះក្រោម ។ ថ្ងៃនេះម៉ាព្រមានខ្ញុំពីរលើក មិនឲ្យខ្ញុំឡើងឈរលើកៅអីទេ ដូច្នេះខ្ញុំក៏អង្គុយចុះ យោលជើងទៅមុខទៅក្រោយនៅពីក្រោមតុ ។

នៅពេលព្រឹក ម៉ានិងប៉ាចូលចិត្តនាំពួកយើងទៅហាងគុយទាវដើម្បីស្រស់ស្រូបមុនពេលប៉ាចេញទៅធ្វើការ ។ ជាធម្មតា កន្លែងនេះមានមនុស្សមកញ៉ាំអាហារពេលព្រឹកយ៉ាងច្រើន ។ សំឡេងម៉ឺងៗនិងគ្រឹងៗរបស់ស្លាបព្រាទង្គិចនឹងគូទចានក្រឡូម សូរជីកតែនិងសូរហុតទឹកស៊ុប ក្លិនខ្ទឹម ខ្ទឹ និងក្លិនស៊ុបគោ ដែលសាយភាយនៅលើវេហាស៍ ធ្វើឲ្យខ្ញុំគួរពោះឃ្លានភ្លាមមួយរំពេច ។

នៅជ្រុងម្ខាងទៀតពីពួកយើង បុរសម្នាក់កំពុងយកចង្កឹះកាយគុយទាវញាត់ចូលក្នុងមាត់ ។ នៅជិតគាត់មានក្មេងស្រីម្នាក់កំពុងជ្រលក់សាច់មាន់នឹងទឹកជ្រលក់ នៅក្នុងខណៈពេលដែលម្តាយរបស់នាងកំពុងចាក់ជើងឆ្នេញ ។ គុយទាវគឺជាអាហារប្រពៃណីពេលព្រឹករបស់ជនជាតិខ្មែរនិងចិន ។

យើងតែងតែញ៉ាំគុយទាវសម្រាប់អាហារពេលព្រឹក ហើយសម្រាប់ពេលពិសេស យើងញ៉ាំនំប៉័ងបារាំងជាមួយកាហ្វេទឹកកក ។

«អង្គុយឲ្យស្ងៀម» ម៉ាប្រាប់ខ្ញុំ ដោយយកដៃគាត់មកទប់ជើងរបស់ខ្ញុំកុំឲ្យយោល ប៉ុន្តែខ្ញុំបែរជាធាក់ដៃគាត់ចេញ ។ ម៉ាសម្លឹងមុខខ្ញុំយ៉ាងមុតហើយទះជើងខ្ញុំយ៉ាងរហ័ស ។

«ហេតុអ្វីក៏ឯងមិនអង្គុយឲ្យស្ងៀម? ឯងអាយុប្រាំឆ្នាំហើយណា៎ ឯងនេះគឺជាកូនដែលនាំរឿងជាងគេ ។ ហេតុអ្វីបានឯងមិនធ្វើខ្លួនឲ្យដូចជាបងប្អូនស្រីរបស់ឯង? តើឯងនឹងធំដឹងក្តីជាស្ត្រីដ៏ល្អម្នាក់តាមរបៀបណា?» ម៉ាដកដង្ហើមធំៗ ។ ខ្ញុំធ្លាប់ឮពាក្យទាំងនេះរហូតដល់ស៊ាំត្រចៀកទៅហើយ គឺតាំងពីមុនមកម្ល៉េះ ។

វាពិតជាពិបាកណាស់សម្រាប់នារីស្អាតដូចម៉ាដែលមានកូនស្រីដូចខ្ញុំដែលមានចរិតមិនដូចក្មេងស្រីឯទៀតៗ ។ ក្នុងចំណោមមិត្តភក្តិជានារីរបស់ម៉ា ម៉ាត្រូវបានគេសរសើរមិនដាច់ពីមាត់ដោយសារតែកម្ពស់ រូបរាង និងសាច់សម្ព័ន្ធខែរបស់គាត់ ។ ខ្ញុំតែងតែឮមិត្តភក្តិរបស់ម៉ាជជែកគ្នាអំពីសម្ផស្សផ្ទៃមុខរបស់ម៉ាពេលដែលអ្នកទាំងអស់នោះគិតថាម៉ាមិនអាចឮសំឡេងពួកគេនិយាយគ្នា ។

ខ្ញុំគឺជាកូនក្មេង ពួកគាត់មានអារម្មណ៍ថា គាត់អាចនិយាយអ្វីបានទាំងអស់នៅមុខខ្ញុំ ព្រោះគាត់ជឿថាខ្ញុំមិនអាចយល់អ្វីដែលគាត់កំពុងតែនិយាយទេ ។ ដូច្នេះហើយ នៅពេលដែលគាត់ទាំងអស់គ្នាមិនយកចិត្តទុកដាក់មកលើរូបខ្ញុំ គាត់ក៏សរសើរពីទម្រង់មុខរបស់ម៉ាដែលមានចិញ្ចើមកោងដូចឥន្ទធនូ រង្វង់ភ្នែកដូចផ្លែអាល់ម៉ុន ច្រមុះស្រួចដូចពួកអឺរ៉ុប និងមានទម្រង់មុខពងក្រពើ ។

ក្នុងកម្ពស់ប្រហែល១,៦៨ម៉ែត្រ ម៉ាគឺជាស្ត្រីដ៏ខ្ពស់ម្នាក់ក្នុងចំណោមស្ត្រីខ្មែរទាំងឡាយ ។ ម៉ានិយាយថា គាត់ខ្ពស់ដោយសារគាត់ជាជនជាតិចិន ។ គាត់និយាយថា ថ្ងៃណាមួយ សញ្ជាតិចិនមួយផ្នែករបស់ខ្ញុំនឹងធ្វើឲ្យខ្ញុំខ្ពស់ដូចគាត់អ៊ីចឹង ។ ខ្ញុំក៏សង្ឃឹមដូច្នោះដែរ ពីព្រោះថាឥឡូវនេះ នៅពេលខ្ញុំឈរជិតម៉ា ខ្ញុំមានកម្ពស់ត្រឹមត្រគាករបស់គាត់ទៅហើយ ។

«បច្ចុប្បន្ន ព្រះអគ្គម្ចាស់ក្សត្រី មុនីនាថ សីហនុ នៃប្រទេសកម្ពុជា គឺជាម្ចាស់ក្សត្រីដែលមានព្រះកិត្តិនាមល្បីល្បាញដោយសារតែភាពសមរម្យត្រឹមត្រូវឥតខ្ចោះរបស់ម្ចាស់ក្សត្រី» ម៉ានិយាយបន្ត ។

«គេនិយាយថា ម្ចាស់ក្សត្រីយាងទៅណាមកណាយ៉ាងស្ងៀមស្ងាត់ ដែលគ្មាននរណាម្នាក់អាចឮសម្រឹបព្រះបាទរបស់ម្ចាស់ក្សត្រីយាងមកដល់ទេ ។ ម្ចាស់ក្សត្រីទ្រង់ព្រះសិតាការ (ញញឹម) មិនឲ្យឃើញព្រះទន្តឡើយ ។ ម្ចាស់ក្សត្រីមានបន្ទូលជាមួយនឹងបុរសៗដោយមិនសម្លឹងចំភ្នែករបស់បុរសៗទាំងនោះទេ ។ ហេតុអ្វីបានជាម្ចាស់ក្សត្រីជាមនុស្សល្អម្ល៉េះហ្ន៎!» ។ ម៉ាក្រឡេកមើលខ្ញុំហើយគ្រវីក្បាល ។

«ហ៊ឺ...» គឺការឆ្លើយតបរបស់ខ្ញុំ ហើយខ្ញុំក៏បឺតកូកាកូឡាមួយក្អឹកពីដបតូចមួយ ។

ម៉ានិយាយថា ខ្ញុំដើរទម្លាក់ជើងធ្ងន់ៗដូចគោស្រែកទឹកអ៊ីចឹង ។ គាត់ព្យាយាមបង្រៀនខ្ញុំជាច្រើនលើកច្រើនសាអំពីរបៀបដើរឲ្យបានត្រឹមត្រូវ ។ «ដំបូង កូនត្រូវដាក់កែងជើងចុះក្រោម បន្ទាប់មករំកិលចុងបាតជើងពេលដែលទ្រាមជើងកូន

ប្រើសន្លត់ដី ។ ចុងបញ្ចប់ ម្រាមជើងកូនក៏បង្កើបខ្នងកូនថ្មម១ផុតពីដី ។ ធ្វើរបៀបនេះត្រូវបានសន្មតថាជារបៀបដើរដ៏សមរម្យពីធម្មជាតិ ហើយកូនអាចដើរបានយ៉ាងស្ងៀមស្ងាត់ ។» ដើររបៀបនេះវាដូចជាសាំញ៉ាំ ហើយឈឺជើងណាស់សម្រាប់ខ្ញុំ ម្យ៉ាងទៀតខ្ញុំសប្បាយចិត្តនឹងដើរទម្លាក់ជើងធ្ងន់ៗទៀតផង ។

«បញ្ហាដែល លឿង ជួប គឺនៅថ្ងៃណាមួយ...» ម៉ាបានមានប្រសាសន៍ទៅកាន់ប៉ា ប៉ុន្តែត្រូវអាក់សម្តីទៅវិញនៅពេលស្ត្រីអ្នកបម្រើភ្ញៀវលើកស៊ុបមកដល់ ។

«គុយទាវភ្នំពេញពិសេសជាមួយសាច់មាន់ និងកែវទឹកក្តៅសម្រាប់អ្នកស្រី» ស្ត្រីអ្នកបម្រើតុនិយាយបណ្តើរ ហើយដាក់ចានស៊ុបក្តៅហុយៗមួយគោមដែលមានគុយទាវ ដំឡូងបារាំងអណ្តែតនៅក្នុងទឹកស៊ុបដ៏ថ្លានោះនៅមុខម៉ាបណ្តើរ ។ «គុយទាវសៀងហៃសរសៃតូចនិងពោះគោដ៏ហឹរពីរចាន» ។ មុននឹងដើរត្រឡប់ទៅវិញ អ្នកបម្រើបានដាក់ចានសំប៉ែតមួយដែលនៅក្នុងនោះមានសណ្តែកបណ្តុះ ចំណិតក្រូចឆ្មារ មើមខ្ទឹមកាត់ជាកង់ៗ ម្ទេសគ្រាប់ហាល ហើយនិងជីរអង្កាម ។

នៅពេលដែលខ្ញុំថែមមើមខ្ទឹម សណ្តែកបណ្តុះ និងជីរអង្កាមទៅក្នុងស៊ុបរបស់ខ្ញុំ ម៉ាបានជ្រលក់ស្លាបព្រានិងចង្កឹះខ្ញុំទៅក្នុងទឹកក្តៅ ហើយលើកមកជូតនឹងកន្សែងរបស់គាត់ មុននឹងគាត់ហុចមកឲ្យខ្ញុំវិញ ។

«ភោជនីយដ្ឋាននេះពុំសូវមានអនាម័យទេ ប៉ុន្តែទឹកក្តៅអាចសម្លាប់មេរោគបាន» ម៉ាជ្រលក់ស្លាបព្រានិងចង្កឹះរបស់គាត់ និងរបស់ប៉ាចូលក្នុងទឹកក្តៅដែរ ។

ក្នុងខណៈពេលដែលម៉ាភ្លក្សស៊ុបគុយទាវសាច់មាន់ដ៏ថ្លារបស់គាត់ ខ្ញុំបានដាក់ម្ទេសពីរគ្រាប់ចូលទៅក្នុងចានគុយទាវរបស់ខ្ញុំ ។ ប៉ាសម្លឹងមើលខ្ញុំដោយគ្មានជំទាស់ ។ ខ្ញុំដាក់ម្ទេសលើគែមចានហើយញោចវានឹងស្លាបព្រា ទីបំផុត ស៊ុបខ្ញុំត្រូវបានដាក់គ្រឿងគ្រោសព្វគ្រប់តាមដែលខ្ញុំចូលចិត្ត ។

ខ្ញុំហុតទឹកស៊ុប ភ្លាមនោះអណ្តាតរបស់ខ្ញុំក៏រលាកនឹងទឹកស៊ុប ហើយច្រមុះរបស់ខ្ញុំបែកញើសស្រក់តក់ៗ ។

កាលពីយូរយារណាស់មកហើយ ប៉ាបានប្រាប់ខ្ញុំថា មនុស្សរស់នៅក្នុងប្រទេសក្តៅគួរតែញ៉ាំអាហារហឹរ ពីព្រោះវាជួយឲ្យយើងដឹកទឹកបានកាន់តែច្រើន ។ កាលណាយើងដឹកទឹកកាន់តែច្រើន យើងក៏បែកញើសកាន់តែច្រើនដែរ ហើយវាជួយលាងភាពមិនស្អាតចេញពីក្នុងខ្លួនយើងផង ។ ខ្ញុំមិនយល់ពីពាក្យសម្តីរបស់ប៉ាទេ ប៉ុន្តែខ្ញុំចូលចិត្តភាពញញឹមរបស់ប៉ាមករកខ្ញុំ ដូច្នេះខ្ញុំក៏តម្រង់ចង្កឹះរបស់ខ្ញុំទៅរកចានម្ទេសជាថ្មីម្តងទៀត បណ្តាលឲ្យបុករលំដួលកំប៉ុងអំបិល ហើយរមៀលដូចដុំឈើធ្លាក់មកលើឥដ្ឋ ។

ម៉ាស្រែកសន្ធាប់ទាំងកំហឹងថា «កូនធ្វើស្អីហ្នឹង? ឈប់ទៅមើលមើ!» ប៉ាក៏មានប្រសាសន៍តបនឹងម៉ាទាំងញញឹមថា «វាជាឧបទ្ទវហេតុទេ» ។

ម៉ាជ្រួញចិញ្ចើមដាក់ប៉ា ហើយតបទៅវិញថា «កុំកាន់ជើងវា! បងឯងភ្លេចហើយឬពីរឿងដល់មាន់? វាក៏និយាយថាជារឿងឧបទ្ទវហេតុដែរ ហើយឥឡូវមើលមុខវាហ្នឹ!» ។ ខ្ញុំស្ទើរតែមិនជឿថាម៉ានៅតែខឹងខ្ញុំពីរឿងនោះទៀត ។ រឿងនោះកើតឡើងតាំងពីយូរយារណាស់មកហើយ ពេលដែលខ្ញុំលេងជាមួយកូនស្រីអ្នកជិតខាងរបស់អ៊ំខ្ញុំ ក្នុងខណៈដែលគ្រួសាររបស់យើងទៅសាកសួរសុខទុក្ខលោកអ៊ំប្រុសនិងអ៊ំស្រីនៅឯស្រុកស្រែ ។ កូនស្រីអ្នកជិតខាងរបស់អ៊ំខ្ញុំហើយនិងខ្ញុំមានមាន់មួយ យើងបីវាចុះឡើងៗដើម្បីដាក់ប្រដល់នឹងមាន់របស់ក្មេងៗដទៃទៀត ។ ម៉ានឹងមិនអាចដឹងពីរឿងនេះទេ ប្រសិនបើគ្មានស្នាមឆូតដ៏ធំនៅលើផ្ទៃមុខរបស់ខ្ញុំទេនោះ ។

«ការដែល លឿង អាចចូលប្រឡូកហើយអាចដកខ្លួនចេញពីសភាពការណ៍ទាំងនេះបាន ធ្វើឲ្យបងមានសេចក្តីសង្ឃឹមលើកូន ។ បងអាចឃើញយ៉ាងច្បាស់ថា នេះជាសញ្ញាណនៃភាពឆ្លាតវៃរបស់ លឿង» ។ ប៉ាតែងតែការពារខ្ញុំនៅចំពោះមុខអ្នកផ្សេងជានិច្ច ។ គាត់តែងតែមានប្រសាសន៍ជារឿយៗថា មនុស្សភាគច្រើនមិនសូវយល់ពីភាពឆ្លាតវៃរបស់កូនក្មេងយ៉ាងម៉េចទេ ហើយបញ្ហាបន្តរឿងទាំងអស់ដែលខ្ញុំធ្វើ គឺជាសញ្ញាណនៃកម្លាំងពលំនិងភាពវៃឆ្លាតរបស់ខ្ញុំ ។ ទោះពិតឬមិនពិតក្តី ប៉ាធ្វើឲ្យខ្ញុំជឿគាត់ទាំងអស់ ។ ខ្ញុំជឿលើអ្វីៗទាំងអស់ដែលប៉ាប្រាប់ខ្ញុំ ។ ប្រសិនបើម៉ាត្រូវបានទទួលស្គាល់ដោយសារតែសម្ផស្សរបស់គាត់ ប៉ាត្រូវបានគេស្រឡាញ់រាប់អានដោយសារតែគាត់ជាមនុស្សចិត្តល្អ ។ ក្នុងកម្ពស់ប្រហែល១,៦៥ម៉ែត្រ ប៉ាមានទម្ងន់ប្រហែល

៦៧,៩គីឡូក្រាម មានមាឌធំក្រអាញ ផ្ទុយពីម៉ាដែលមានរូបរាងស្គមខ្ពស់ ។

មាឌរបស់ប៉ាធ្វើឲ្យខ្ញុំនឹកដល់កូនខ្លាឃ្មុំតុក្កតាដ៏ទន់ធំមួយដែលងាយស្រួលឱប ។ ប៉ាមានសញ្ជាតិជាខ្មែរកាត់ចិន ។ គាត់មានសក់ខ្មៅរួញអង្កាដី ច្រមុះធំ បបូរមាត់ក្រាស់ និងមានមុខមូល ។

កែវភ្នែកទាំងគូរបស់ប៉ាមានពន្លឺស្រទន់ មានទម្រង់ដូចព្រះច័ន្ទពេញវង់ ហើយមានពណ៌ត្នោតដូចពណ៌ដី ។ អ្វីដែលខ្ញុំស្រលាញ់ប៉ាជាងគេបំផុតនោះ គឺមិនត្រឹមតែរបៀបដែលគាត់ញញឹមទេ ថែមទាំងកែវភ្នែកទាំងគូរបស់គាត់ទៀតផង ។

ខ្ញុំចូលចិត្តស្តាប់រឿងដែលប៉ានិងម៉ាបានជួបគ្នាហើយបានរៀបការជាមួយគ្នាណាស់ ។ ថ្ងៃមួយ នៅពេលដែលប៉ាជាលោកសង្ឃ បាននិមន្តឆ្លងស្ទឹងនៅកន្លែងដែលម៉ាកំពុងដងទឹកដាក់ក្អម ។ ប៉ាក្រឡេកមើលម៉ាមួយភ្លែត ហើយក៏ពេញចិត្តលើម៉ាមួយរំពេច ។ ម៉ាយល់ឃើញថាប៉ាគាត់ចិត្តល្អ មានមាឌធំមាំហើយសង្ហាផង ដោយថាហេតុ ម៉ាក៏បាក់ចិត្តស្រលាញ់ប៉ាវិញដែរ ។ ប៉ាបានលាចាកសិក្ខាបទ ការធ្វើដូច្នេះអាចឲ្យគាត់សុំម៉ារៀបការបាន ហើយម៉ាក៏យល់ព្រម ។ ទោះបីជាយ៉ាងនេះក៏ដោយ ដោយមូលហេតុថាប៉ាមានសម្បុរខ្មៅ និងជាមនុស្សក្រីក្រទៀតនោះ ឪពុកម្តាយរបស់ម៉ាបានជំទាស់មិនឲ្យគាត់ទាំងពីររៀបការទេ ។ ប៉ុន្តែគាត់ទាំងពីរស្រឡាញ់គ្នាយ៉ាងប្តូរផ្តាច់ ដូច្នេះហើយ គាត់ក៏សម្រេចចិត្តពង្រត់គ្នាចេញពីផ្ទះ ។ គាត់ទាំងពីរនាក់មានជីវភាពនឹងន រហូតដល់ពេលដែលប៉ាទៅលេងល្បែងស៊ីសង ។ ដំបូងគាត់លេងល្បែងខស្សរាហ៍ឈ្នះណាស់ ហើយគាត់ឈ្នះជាច្រើនដងទៀតផង ។ ក្រោយមក នៅថ្ងៃមួយនោះ ប៉ាលេងយ៉ាងចាស់ដៃ គាត់ភ្នាល់ដាក់អ្វីៗទាំងអស់នៅក្នុងវង់ល្បែង ដាក់ផ្ទះនិងដាក់លុយទាំងអស់ដែលគាត់មាន ។ ប៉ាបានចាញ់ការភ្នាល់នោះ ហើយស្ទើរតែបាត់បង់គ្រួសារទាំងមូលនៅពេលដែលម៉ាគំរាមថានឹងចាកចេញពីគាត់ ប្រសិនបើគាត់មិនព្រមឈប់លេងល្បែងទេ ។ បន្ទាប់ពីពេលនោះមក ប៉ាមិនដែលលេងបៀទៀតទេ ។ ឥឡូវនេះ យើងទាំងអស់គ្នាត្រូវបានហាមឃាត់មិនឲ្យលេងបៀឡើយ សូម្បីតែយកបៀមួយហ៊ូចូលផ្ទះក៏មិនបានផង ។ ប្រសិនបើយើងត្រូវប៉ាចាប់បាន សូម្បីតែខ្ញុំក៏ត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរពីប៉ាដែរ ។

ក្រៅពីល្បែង ប៉ាគឺជាប៉ាដ៏ល្អគ្រប់យ៉ាង ។ គាត់ចិត្តល្អទន់ភ្លន់ ហើយគួរឲ្យស្រឡាញ់ ។ ប៉ាធ្វើការយ៉ាងសកម្ម ។ ដោយសារតែប៉ាមានតួនាទីជាអនុសេនីយ៍ឯកប៉ូលិស ខ្ញុំមិនអាចជួបប៉ាឲ្យបានច្រើនដងតាមដែលខ្ញុំចង់ជួបទេ ។ ម៉ាប្រាប់ខ្ញុំថា ជោគជ័យរបស់ប៉ាមិនដែលបានមកពីការជាន់ឈ្លីអ្នកដទៃឡើយ ។ ប៉ាមិនដែលភ្លេចថាតើភាពក្រីក្រវាមានរសជាតិបែបណាទេ ។ ដោយហេតុនេះហើយ ទើបគាត់ចំណាយពេលវេលាជួយជនក្រីក្រតោកយ៉ាកជាច្រើន ។ មនុស្សជាច្រើនគោរពប៉ា ហើយស្រលាញ់ប៉ាយ៉ាងពិតប្រាកដ ។

«កូនល្មើង រវៀសរវៃហើយឆ្លាតណាស់ ដែលធ្វើឲ្យយើងពិបាកយល់ពីវា» ប៉ាមានប្រសាសន៍ព្រមទាំងមិចភ្នែកដាក់ខ្ញុំ ។ ខ្ញុំពេបមាត់ដាក់គាត់វិញ ។ ពេលដែលខ្ញុំមិនទាន់ដឹងពីភាពឆ្លាតវៃរបស់មនុស្ស ខ្ញុំគ្រាន់តែដឹងថា ខ្ញុំគឺជាក្មេងម្នាក់ដែលចង់ដឹងចង់ឮពីពិភពលោកនេះ ខ្ញុំចង់ដឹងចាប់តាំងពីដង្កូវ ជន្លេន និងសត្វល្អិត រហូតដល់ការប្រដល់មាន់ និងអាវទ្រនាប់របស់ម៉ាដែលព្យួរនៅក្នុងបន្ទប់គាត់ទៀតផង ។

«ឃើញទេ បងលើកជើងកូនឲ្យធ្វើចរិតរបៀបហ្នឹងទៀតហើយ» ។ ម៉ាក្រឡេកមើលខ្ញុំ ប៉ុន្តែខ្ញុំធ្វើមិនដឹងមិនឮ ហើយបន្តហុតស៊ុបរបស់ខ្ញុំតទៅទៀត ។

មានថ្ងៃមួយនោះ ខ្ញុំបានដើរឆ្ពោះទៅកាន់អ្នកលក់ជើងកង្កែបអាំងតាមផ្លូវ ហើយសួរគាត់ជាច្រើនសំណួរ «លោកពូ តើលោកពូចាប់កង្កែបមកពីស្រះនៅស្រុកលោកពូមែនទេ? ឬក៏លោកពូចិញ្ចឹមវា? លោកពូឲ្យវាស៊ីអី? តើធ្វើម៉េចដើម្បីបកស្បែកវាចេញ? តើលោកពូមានឃើញដង្កូវនៅក្នុងពោះវាទេ? ហើយលោកពូយកខ្លួនវាទៅណាពេលពូយកតែជើងវាមកលក់អីចឹង?» ខ្ញុំសួរសំណួរយ៉ាងច្រើនរហូតដល់ធ្វើឲ្យគាត់រុញរទេះចេញ ។ វាមិនមែនជារឿងសមរម្យទេសម្រាប់ក្មេងដែលចូលចិត្តនិយាយច្រើន ។ ពេលខ្ញុំកម្រើកខ្លួនចុះ-ឡើងនៅក្នុងកៅអីភ្នាក់ដៃម៉ាប្រាប់ខ្ញុំថានេះក៏ជាអត្តចរិតមិនសមរម្យមួយដែរ ។

«ខ្ញុំឆ្អែតហើយ អាចឲ្យខ្ញុំទៅបានទេ?» ខ្ញុំសួរទៅម៉ាដោយយោលជើងរបស់ខ្ញុំចុះឡើងកាន់តែខ្លាំងជាងមុន ។

«អត់អីទេ ឯងអាចទៅលេងបានហើយ» ម៉ាតបមកខ្ញុំវិញដោយដកដង្ហើមធំ ។ ខ្ញុំលោតចុះពីកៅអី ហើយដើរតម្រង់ទៅផ្ទះមិត្តភក្តិរបស់ខ្ញុំដែលនៅខាងមុខ ។

ទោះបីជាក្រពះរបស់ខ្ញុំឡើងតឹងក៏ដោយ ក៏ខ្ញុំនៅតែចង់ញ៉ាំនំចំណីប្លែកៗទៀតដែរ ។ ជាមួយប្រាក់ដែលប៉ាឲ្យខ្ញុំនៅក្នុងហោប៉ៅ ខ្ញុំក៏ដើរទៅកាន់រទេះលក់ចង្រិតលីងមួយ ។ មានរទេះលក់នំចំណីជាច្រើននៅកាច់ជ្រុងផ្លូវ ដែលមានលក់អ្វីៗគ្រប់មុខតាំងពីស្វាយទុំ អំពៅ មានតាំងពីនំលោកខាងលិចរហូតដល់នំបារាំង ។ ម្ហូបចំណីលក់តាមផ្លូវត្រូវគេត្រៀមជាស្រេចសម្រាប់លក់ ហើយតែងតែលក់ក្នុងតម្លៃថោកទៀតផង ។ តូបលក់ម្ហូបចំណីទាំងនេះពេញនិយមណាស់នៅក្នុងប្រទេសកម្ពុជា ។ មនុស្សអង្គុយចោងហោងញ៉ាំចំណីអាហារជាជួរៗ គឺជាទិដ្ឋភាពដែលយើងឃើញមានជាទូទៅនៅទីក្រុងភ្នំពេញ ។ ប្រជាជនកម្ពុជាចូលចិត្តញ៉ាំមិនថាម៉ោងណាជាម៉ោងណាទេ ហើយអាហារគ្រប់មុខត្រូវបានគេដាក់តាំងឲ្យភ្ញាក់ ប្រសិនបើអ្នកមានប្រាក់ក្នុងហោប៉ៅដូចជាខ្ញុំមាននៅថ្ងៃនេះអ៊ីចឹង ។

ចង្រិតពណ៌ត្នោតយ៉ាងរលោងដែលមានធំក្លិនឆ្ងៀងខុសនិងទឹកឃ្មុំ ត្រូវបានខ្ចប់ក្នុងស្លឹកឈូកពណ៌បៃតងចាស់សម្រាប់ខ្ញុំ ។ វាមានជាតិដូចគ្រាប់ផ្លែឈើប្លែកៗដូច្នោះដែរ ។ ពេលដើរយឺតៗតាមចិញ្ចើមថ្នល់ ខ្ញុំឃើញក្មេងប្រុសមួយហ្វូងឈរជុំវិញតូបដែលមានក្មេងស្រីស្អាតៗកំពុងលក់ដូរ ។ ខ្ញុំដឹងថា សម្ផស្សរបស់មនុស្សស្រីគឺសំខាន់ណាស់ សម្ផស្សនេះវានឹងមិនធ្វើឲ្យប៉ះទង្គិចដល់អាជីវកម្មរបស់អ្នកទេ ប្រសិនបើមានស្រីៗណាម្នាក់ជាអ្នកលក់ផលិតផលរបស់អ្នកនោះ ។ ស្រីក្មេងស្អាតៗអាចធ្វើឲ្យបុរសឆ្លាតៗក្លាយទៅជាក្មេងសឺៗបាន ។ ខ្ញុំធ្លាប់ឃើញបងប្រុសរបស់ខ្ញុំទិញនំចំណីដែលគាត់មិនដែលសូវញ៉ាំពីក្មេងស្រីស្អាតម្នាក់នៅពេលដែលគាត់ព្យាយាមចៀសមិនទិញចំណីអាហារដ៏ឆ្ងាញ់ដែលលក់ដោយក្មេងស្រីក្នុងស្រុក ។ នៅពេលមានអាយុប្រាំឆ្នាំខ្ញុំដឹងថាខ្ញុំជាក្មេងដ៏ស្អាតម្នាក់ ដោយសារតែខ្ញុំខស្បូវហ៍ពួកគេនិយាយជាមួយថាខ្ញុំអាក្រក់យ៉ាងនេះយ៉ាងនោះ ។

«តើវានឹងមិនមានមុខមាត់អាក្រក់ទេឬ?» មិត្តភក្តិរបស់ម៉ានិយាយជាមួយម៉ា ។ «សក់ខ្មៅរលោង ហើយមើលចុះ វាមានសម្បុរស្រអែមយ៉ាងស្រស់ផង! ទម្រង់មុខរាងដូចបេះដូងអ៊ីចឹងធ្វើឲ្យអ្នកណាៗក៏ចង់យកដៃក្តិចថ្ពាល់ខ្ចួចដូចផ្លែប៉ោមរបស់វាដែរ ។ មើលហ្ន៎ មើលបបូរមាត់ដ៏ពេញរបស់វា ហើយមើលវាញញឹមហ្ន៎ ពិតជាអាក្រក់មែន!» ។

ខ្ញុំស្រែកដាក់ពួកគាត់ថា «កុំនិយាយថាខ្ញុំអាក្រក់ណ៎ា!» ហើយគាត់ក៏នាំគ្នាសើច ។

កាលពីមុន ម៉ាធ្លាប់ពន្យល់ប្រាប់ខ្ញុំថា ជនជាតិខ្មែរមិនសរសើរក្មេងត្រង់ៗទេ ។ គេក៏មិនចង់ទាក់ទាញចំណាប់អារម្មណ៍របស់មនុស្សមកលើក្មេងៗឲ្យខ្លាំងពេកដែរ ។ ការសរសើរបែបនេះត្រូវបានគេជឿថាវានាំឲ្យព្រលឹងបិសាចឆាប់ច្រណែននឹងក្មេងនៅពេលដែលពួកបិសាចទាំងនោះឮសម្តីដែលគេកំពុងសរសើរក្មេង ព្រលឹងបិសាចប្រហែលជាមកឆាបយកព្រលឹងក្មេងនោះទៅភពផ្សេងទៀត ។

## គ្រួសារ អ៊ឹង

**ខែមេសា ឆ្នាំ១៩៧៥**

គ្រួសាររបស់យើងគឺជាគ្រួសារធំមួយមានសមាជិកទាំងអស់ប្រាំបួននាក់ ។ នៅក្នុងនោះមានប៉ា ម៉ា ក្មេងប្រុសបីនាក់ និងក្មេងស្រីបួននាក់ ។ ជាភ័ព្វសំណាងល្អ យើងមានផ្ទះដ៏ធំមួយដែលអាចឲ្យយើងគ្រប់គ្នារស់នៅបានយ៉ាងសុខដុមរម្យនា ។ ផ្ទះរបស់យើងមានរាងទ្រវែងដូចរថភ្លើង វាមានសភាពចង្អៀតបន្តិចនៅខាងមុខ និងមានបន្ទប់តភ្ជាប់ៗគ្នាទៅខាងក្រោយ ។ ផ្ទះយើងមានបន្ទប់ច្រើនជាងផ្ទះរបស់អ្នកដទៃដែលខ្ញុំបានទៅលេង ។ បន្ទប់សំខាន់ជាងគេបំផុតនៅក្នុងផ្ទះយើងគឺបន្ទប់ទទួលភ្ញៀវដែលជារឿយៗយើងទាំងអស់គ្នាតែងអង្គុយមើលទូរទស្សន៍នៅទីនោះ ។ បន្ទប់នោះធំទូលាយ ពិតានខ្ពស់ ហើយមានជណ្តើរតូចមួយឡើងទៅឡាតឿដែលជាបន្ទប់គេងរបស់បងប្រុសខ្ញុំទាំងបី ។ ផ្លូវដើរដ៏តូចមួយបាននាំយើងទៅកាន់ចង្ក្រានបាយដែលខណ្ឌចែកដោយបន្ទប់គេងរបស់ម៉ានិងប៉ាពីបន្ទប់គេងរួមរបស់បងប្អូនស្រីរបស់ខ្ញុំទាំងបីនិងខ្ញុំ ។

ក្លិនខ្ទឹមបំពងនិងបាយឆ្អិនបានហើរសាយភាយពេញចង្ក្រានបាយរបស់យើង នៅពេលដែលយើងមកអង្គុយជុំវិញ

តុបាយអាកាហ្វ៊ូ ដែលនៅកន្លែងនោះយើងមានកៅអីភ្ជាក់ដៃបង្អែកខ្ពស់ម្នាក់មួយៗ ។ នៅលើពិតានចង្ក្រានបាយ មានកង្ហារអគ្គិសនីមួយវិលគ្មានឈប់ នាំក្លិនដ៏ឈ្ងុយឈ្ងប់ចេញពីចង្ក្រានបាយ សាយភាយចូលពេញផ្ទះរហូតដល់បន្ទប់ទឹករបស់យើង ។ គ្រួសាររបស់យើងគឺជាគ្រួសារទាន់សម័យមួយ ។ បន្ទប់ទឹករបស់យើងត្រូវបានបំពាក់ដោយបរិក្ខារផ្សេងៗ ដូចជា មានបង្គន់កាច់ទឹកមួយ ក្បាលរ៉ូប៊ីណេដែកមួយ និងមានទឹកម៉ាស៊ីនឡើងដល់ជាន់លើទៀត ។ ខ្ញុំដឹងថាគ្រួសាររបស់យើងជាគ្រួសារវណ្ណៈកណ្តាល ដោយសារផ្ទះរបស់យើងនិងរបស់របរប្រើប្រាស់ដែលយើងមាន ។ មិត្តភក្តិខ្ញុំជាច្រើនរស់នៅក្នុងផ្ទះដ៏ចង្អៀត ដែលមានបន្ទប់តែពីរឬបីប៉ុណ្ណោះសម្រាប់សមាជិកគ្រួសារដល់ទៅដប់នាក់ ។

គ្រួសារអ្នកមានភាគច្រើនរស់នៅផ្ទះជាន់លើ ។ នៅទីក្រុងភ្នំពេញវាហាក់ដូចជាថា អ្នកណាមានប្រាក់កាន់តែច្រើន អ្នកនោះនឹងមានជណ្តើរឡើងផ្ទះកាន់តែខ្ពស់ដែរ ។ ម៉ាំនិយាយថា ផ្ទះជាន់ផ្ទាល់ដីមិនគួរឲ្យចង់រស់នៅទេ ដោយមូលហេតុមកពីដីហុយចូលផ្ទះនិងសំឡេងអ៊ូអររបស់មនុស្សដែលតែងតែក្រឡេកមើលចុះឡើង ។ ដូច្នេះវាជាការពិតណាស់ ផ្ទះជាន់ក្រោមគឺសម្រាប់អ្នកក្រីក្ររស់នៅ ។

តំបន់បោះតង់បណ្តោះអាសន្នសម្រាប់អ្នកក្រីក្រគោកយ៉ាករស់នៅ ជាកន្លែងដែលខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យទៅដើរលេងទេ ។ ជួនកាល ពេលខ្ញុំនៅតាមផ្លូវទៅផ្សារជាមួយម៉ាំ ខ្ញុំក្រឡេកឃើញតំបន់ដែលអ្នកក្រីក្ររស់នៅមួយភ្លែតៗដែរ ។ ខ្ញុំសម្លឹងមើលដោយជក់ចិត្តនៅពេលដែលក្មេងៗមានសក់ពណ៌ខ្មៅរលើបនិងពាក់អាវចាស់គគ្រិច រត់តម្រង់មករកស៊ីក្លូរបស់យើងទាំងជើងទទេ ។ ក្មេងជាច្រើនដែលមានមាឌប្រហាក់ប្រហែលខ្ញុំ ដើរយ៉ាងប្រញាប់ប្រញាល់ដោយមានអៀវប្អូនតូចៗស្រាតនទលគកនៅលើខ្នងផង ។ ទោះបីជាខ្ញុំមើលពីចម្ងាយក៏ដោយ ក៏ខ្ញុំឃើញដីក្រហមប្រឡាក់មុខរបស់គេ និងមានផ្នត់ក្អែលយ៉ាងក្រាស់នៅលើកនិងក្នុងក្រចកដៃរបស់គេដែរ ។ ក្មេងខ្លះទៀតកំពុងតែទប់ល្អីឬកញ្ជើដាក់រូបចម្លាក់តូចៗ ដូចជា រូបព្រះពុទ្ធ គោ ក្របី រទេះក្នុងសួន និងកាន់ខ្លុយឫស្សីតូចៗនៅដៃម្ខាង ហើយដៃម្ខាងទៀតទប់កញ្ជើរពាក់ ឬកណ្តៀតវានឹងត្រគាក ហៅយើងឲ្យជួយទិញទំនិញរបស់ពួកគេ ។ អ្នកខ្លះគ្មានរបស់អ្វីលក់ទេ ប៉ុន្តែបានហុចដៃមករកយើងដោយនិយាយខ្សឹបៗ ។ ជារៀងរាល់លើកមុនពេលដែលខ្ញុំអាចស្តាប់ឮអ្វីដែលក្មេងទាំងអស់ចង់និយាយ សំឡេងកណ្តឹងរោទិ៍ខ្លាំងៗរបស់ស៊ីក្លូបានធ្វើឲ្យពួកវារត់ប្រញាយចេញពីផ្លូវរបស់យើង ។ នៅទីក្រុងភ្នំពេញមានផ្សារជាច្រើន ផ្សារខ្លះធំ ផ្សារខ្លះតូច ប៉ុន្តែផ្សារទាំងអស់លក់ផលិតផលស្រដៀងៗគ្នា ។ ផ្សារទាំងនោះមានដូចជាផ្សារថ្មី ផ្សារទួលទំពូង ផ្សារអូឡាំពិក និងផ្សារតូចៗដទៃទៀត ។ កន្លែងដែលមនុស្សម្នាទៅផ្សារគឺអាស្រ័យផ្សារមួយណាដែលនៅជិតផ្ទះជាងគេ ។ ប៉ាប្រាប់ខ្ញុំថា ផ្សារអូឡាំពិកធ្លាប់ជាផ្សារដ៏ស្អាតមួយ ។ ឥឡូវនេះផ្នែកខាងក្រៅនៃសំណង់មានពណ៌ស្រអាប់បណ្តាលមកពីស្លែនិងការធ្វើឲ្យកខ្វក់ ជញ្ជាំងរបស់វាប្រេះដោយសារតែគ្មានការថែទាំ នៅលើដីដែលធ្លាប់តែមានស្មៅនិងផ្ការីកត្រសុំត្រសាយចម្រុះពណ៌ ប្រែទៅជាស៊ិតស្រពោន ហើយត្រូវបានប្រមូលយកទៅដុតចោលនៅខាងក្រោមតង់និងរទេះលក់ចំណីនៅខាងក្រៅជាកន្លែងដែលអ្នកទៅផ្សាររាប់ពាន់នាក់ដើរឆ្លងកាត់រៀងរាល់ថ្ងៃ ។

នៅក្រោមតង់ពណ៌បៃតងនិងពណ៌ផ្ទៃមេឃថ្លា អ្នកលក់បានដាក់លក់ទំនិញគ្រប់មុខ មានតាំងពីក្រណាត់សំពត់ដែលមានក្រឡាឆ្នូតៗនិងផ្កា រហូតដល់សៀវភៅជាភាសាចិន ខ្មែរ អង់គ្លេស និងបារាំង ។

នៅទីនេះ មានលក់ផ្លែដូងខ្ចីដែលកាប់ហើយស្រាប់ ផ្លែចេកពងមាន់ និងផ្លែស្រកានាគ ហើយមានត្រីមឹកពណ៌ប្រាក់ដែលមានភ្នែកដូចអង្កាំកំពុងវារវើកៗ និងបង្គាស្រស់កំពុងតែលោតផ្លោតៗនៅក្នុងធុងទឹកជ័រពណ៌ស ។ នៅខាងក្នុងផ្សារដែលជាទូទៅមានសីតុណ្ហភាពត្រជាក់ជាងខាងក្រៅ១០អង្សាសេ យើងឃើញក្មេងស្រីស្អាតៗពាក់អាវពណ៌ឆើតៗ និងស្លៀកសំពត់ភ្លឺស្វេងកំពុងតែអង្គុយលើជើងម៉ាក្រោយទូកញ្ចក់ដែលដាក់តាំងគ្រឿងមាសនិងប្រាក់ពេញទូ ។

នៅលើត្រចៀក ក ម្រាមដៃ និងកដៃរបស់អ្នកលក់មាសមានពាក់សុទ្ធតែគ្រឿងអលង្ការមាសម្តៃបួនការ៉ាត់ ដើម្បីទាក់ទាញអ្នកទិញឲ្យចូលតូបរបស់គេ ។ ចម្ងាយប្រមាណពីរបីជំហាន

ពីអ្នកលក់មាស នៅខាងក្រោយមានផាប់ដែលគេបោចរោមអស់ មានពណ៌លឿង និងថ្ពក់ព្យួររណែងរណោង មានបុរសជាច្រើននាក់ពាក់អាវអៀមប្រឡាក់សុទ្ធតែឈាម កំពុងតែលើកកាំបិតប៉័ងតោកាត់សាច់គោជាដុំៗយ៉ាងប៉ិនប្រសប់ ។ ឆ្ងាយពីអ្នកលក់សាច់បន្តិច យើងឃើញក្មេងជំទង់ៗទាន់សម័យដែលមានជើងសក់ដូចលោក អេលវីស ប្រេសលី ស្លៀកខោមានឡេវដូចកណ្ដឹង ពាក់អាវធំកម្ពីស្នូត កំពុងតែលេងតន្ត្រីសម័យពុខ្លាំងៗពីវង់ភ្លេងរបស់គេ ។ សំឡេងចម្រៀងនិងសម្រែកអ្នកលក់ បញ្ចេញតំណាលៗគ្នាដើម្បីទាក់ទាញអារម្មណ៍របស់អ្នកដើរចុះដើរឡើងទៅវិញទៅមក ។

ថ្មីៗនេះ ម៉ាឈប់យកខ្ញុំទៅផ្សារជាមួយគាត់ទៀតហើយ ប៉ុន្តែខ្ញុំនៅតែក្រោកពីព្រលឹមដើម្បីមើលគាត់ផ្ញុំសក់និងផាត់ម៉ាគីយ៉េ ។ នៅពេលម៉ាលើកអាវសូត្រពណ៌ខៀវមកពាក់ជាមួយសារុងពណ៌ត្នោតចាស់ ខ្ញុំបានអង្វរឲ្យគាត់យកខ្ញុំទៅផ្សារជាមួយដែរ ប៉ុន្តែម៉ាមិនព្រម ។ ពេលដែលគាត់កំពុងពាក់ខ្សែកមាស ក្រវិលត្បូងទទឹម ខ្សែដៃ និងនាឡិកាដៃរបស់គាត់ ខ្ញុំក៏អង្វរឲ្យម៉ាជួយទិញនំឲ្យខ្ញុំផង ។ បន្ទាប់ពីបាញ់ទឹកអប់ជុំវិញករួចហើយ ម៉ាបានស្រែកឲ្យអ្នកបម្រើយើងមើលខ្ញុំ ដើម្បីឲ្យគាត់ចេញទៅផ្សារ ។

ដោយសារតែយើងមិនមានទូទឹកកក ម៉ាតែងទៅផ្សារជារៀងរាល់ព្រឹក ។ ម៉ាចូលចិត្តទៅផ្សាររៀងរាល់ថ្ងៃ ពីព្រោះធ្វើរបៀបនេះ អ្វីដែលយើងញ៉ាំរាល់ថ្ងៃគឺសុទ្ធតែស្រស់ៗទាំងអស់ ។ សាច់ជ្រូក សាច់គោ និងមាន់ ដែលម៉ាទិញយកមក ត្រូវបានដាក់ក្លាស្សេនៅក្នុងធុងទឹកកកជាមួយដុំទឹកកកដែលទិញមកពីហាងទឹកកកនៅតាមផ្លូវខាងក្រោមផ្ទះ ។

នៅពេលម៉ាត្រឡប់មកពីផ្សារវិញទាំងហត់អស់កម្លាំងនិងក្តៅស្អុះ តាមទម្លាប់ប្រពៃណីរបស់ជនជាតិចិន អ្វីដែលម៉ាត្រូវធ្វើដំបូងបង្អស់មុនចូលផ្ទះ គឺដោះស្បែកជើងសង្រែករបស់គាត់ចេញ ហើយទុកវានៅជិតទ្វារផ្ទះ បន្ទាប់មកគាត់ឈរទាំងជើងទទេលើឥដ្ឋ ហើយដកដង្ហើមវែងៗដើម្បីបន្ធូរបន្ថយអារម្មណ៍នឿយហត់ ពេលដែលខ្យល់ត្រជាក់ភាយចេញពីកម្រាលឥដ្ឋជ្រាបតាមបាតជើងរបស់គាត់ ។

នៅពេលរាត្រី ខ្ញុំចូលចិត្តអង្គុយនៅលើយ៉ខាងក្រៅផ្ទះរបស់យើងជាមួយប៉ា ដើម្បីមើលពិភពមនុស្សដែលឆ្លងកាត់ខាងក្រោមយើង ។ មើលពីយ៉ផ្ទះរបស់យើងទៅ យើងឃើញសំណង់ដែលមានកម្ពស់ពីរឬបីជាន់លេចឡើងស្កុងៗ និងសំណង់បីឬបួនទៀតឈរត្រដែតឡើងដែលមានកម្ពស់ខ្ពស់ដល់ប្រាំបីជាន់ ។ សំណង់ទាំងនោះមានសភាពចង្អៀតហើយសាងសង់ជិតៗគ្នា ដោយសារតែទីក្រុងភ្នំពេញមានរាងទ្រវែង លាតសន្ធឹងតាមដងទន្លេសាបប្រវែងជាងបីគីឡូម៉ែត្រ ។ សម្រស់ទីក្រុងភ្នំពេញត្រូវបានគេទទួលស្គាល់ដោយសារភាពទំនើបទាន់សម័យនៃសំណង់ដែលសង់បែរមុខទៅរកសំណង់របស់អាណានិគមបារាំង ។ សំណង់ទាំងពីរនេះនៅទល់មុខគ្នា ដោយមានផ្ទះល្វែងខាងក្រោមរុំព័ទ្ធទៅដោយម្រែងភ្លើង ។

នៅពេលយប់ងងឹត ទីក្រុងទាំងមូលមើលទៅហាក់ដូចស្ងាត់ជ្រងំ និងមានដំណើរទៅមុខយឺតៗ ខណៈដែលភ្លើងនៅតាមដងវិថីភ្លឹភ្លឹបភ្លែតៗ ។ ភោជនីយដ្ឋានត្រូវបិទទ្វារ រទេះលក់ចំណីអាហារត្រូវបានយកទៅចតទុកនៅសងខាងផ្លូវ ។

អ្នកធាក់ស៊ីក្លូខ្លះឡើងគេងលើស៊ីក្លូ ក្នុងខណៈដែលអ្នកខ្លះទៀតនៅបន្តការលក់អីវ៉ាន់កំប៉ិកកំប៉ុកនៅជុំវិញនោះ ។ ជួនកាលនៅពេលដែលខ្ញុំមានអារម្មណ៍ក្លាហាន ខ្ញុំក៏ផ្ងោះទៅចុងម្ខាងទៀតនៃបង្កាន់ដៃផ្ទះ ហើយសម្លឹងមើលភ្លើងនៅខាងក្រោម ។ នៅពេលដែលខ្ញុំក្លាហានបំផុត ខ្ញុំបានឡើងអង្គុយលើបង្កាន់ដៃផ្ទះ ដោយកាន់បង្កាន់ដៃយ៉ាងណែន ។ ក្នុងខណៈដែលខ្លួនខ្ញុំទ្រទៅដោយបង្កាន់ដៃផ្ទះ ខ្ញុំហ៊ានក្រឡេកមើលម្រាមជើងខ្លួនឯងដែលសំយុងចុះនៅគែមម្ខាងទៀតនៃពិភពលោក ។ ពេលខ្ញុំមើលចុះទៅក្រោមឃើញរថយន្តនិងស៊ីក្លូ អារម្មណ៍ស្រពន់ជើងបានរត់មកចាក់ម្រាមជើងខ្ញុំ ធ្វើឲ្យខ្ញុំគិតថាដូចមាននរណាម្នាក់យកម្ជុលតូចៗរាប់ពាន់មកចាក់ជើងខ្ញុំអ៊ីចឹង ។ ជួនកាល ខ្ញុំគ្រាន់តែទៅឈរពិតនឹងបង្កាន់ដៃផ្ទះ ហើយខ្ញុំលើកដៃរបស់ខ្ញុំឡើងខ្ពស់ផុតក្បាល ។ ខ្ញុំលើកដៃទាំងពីរទទេះនៅក្នុងខ្យល់ ដោយចាត់ទុកខ្លួនខ្ញុំជាសត្វនាគដែលកំពុងហោះលេងលើទីក្រុង ។ យ៉នៅខាងមុខផ្ទះគឺជាកន្លែងពិសេសមួយសម្រាប់ខ្ញុំ ពីព្រោះវាជាកន្លែងដែលប៉ានិងខ្ញុំតែងសន្ទនារឿងសំខាន់ៗជាមួយគ្នាជារឿយៗ ។ **(នៅមានត)**

# អ្នកជំងឺភេទស្រី

របបកម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យទ្រុឌទ្រោមកាយសម្បទានិងបាត់បង់ជីវិតស្ត្រីអស់ជាច្រើននាក់ ។ ការទទួលចំណីអាហារមិនគ្រប់គ្រាន់ និងការបង្ខំឲ្យធ្វើពលកម្មធ្ងន់ធ្ងរ បានធ្វើឲ្យរាងកាយស្ត្រីចុះខ្សោយនិងឆាប់ទទួលរងនូវជំងឺរាតត្បាតផ្សេងៗ ។ ក្រោយឆ្នាំ១៩៧៩ ស្ត្រីស្ទើរតែទាំងអស់ដែលនៅរស់រានមានជីវិត សុទ្ធសឹងមានជំងឺប្រចាំកាយ ។ ស្ត្រីខ្លះក្លាយទៅជាជនពិការដែលមិនអាចមានកូនអស់មួយជីវិត ។ ស្ត្រីភាគច្រើនកើតជំងឺរាំរៃរដូវ ស្រុតស្បូនរីងរៃ និងឈឺសន្លាក់ដៃជើង ដោយសារតែធ្វើការងារធ្ងន់និងគ្មានអាហារគ្រប់គ្រាន់ក្នុងពេលសម្រាលកូន ។ ស្ត្រីមួយចំនួនទៀតមានជំងឺផ្លូវចិត្តដោយសារតែការព្រាត់ប្រាសសាច់ញាតិក្រុមគ្រួសារ ។ ជំងឺនេះគ្មានឱសថទិព្វណាអាចព្យាបាលបានឡើយ មានតែគម្លាតនៃពេលវេលាទេទើបធ្វើឲ្យស្ត្រីបានធូរស្បើយក្នុងអារម្មណ៍ខ្លះ ។

នៅក្នុងឯកសារ «ទស្សនៈស្តីពីបញ្ហាសេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ» បានសរសេរថា រដ្ឋអំណាចជាឧបករណ៍ផ្តាច់ការរបស់បដិវត្តន៍និងបក្ស ។ ដោយសារអំណាចផ្តាច់ការបដិវត្តន៍នេះហើយ ទើបកម្ពុជាប្រជាធិបតេយ្យបង្កើតគោលនយោបាយបែងចែកប្រជាជនជាបីប្រភេទ ។ ប្រជាជន១៧មេសាត្រូវបានចាត់ចូលក្នុងប្រភេទទីបី ឬហៅថាជាជនបញ្ញើក្អែក ។ ប្រជាជននៅក្នុងប្រភេទនេះត្រូវអង្គការរើសអើង តាមសង្កត់ និងតាមដានគ្រប់ពេលវេលា ដើម្បីបោសសម្អាតនូវកម្អែលសក្តិភូមិនាយទុនដូចដែលមាត្រាទី៣នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យចែងថា «វប្បធម៌របស់ប្រទេសកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈជាតិ ប្រជាជន និងចម្រើន ស្អាតស្អំ... វប្បធម៌នេះប្រឆាំងដាច់ខាតនឹងវប្បធម៌ពុករលួយប្រតិកិរិយារបស់វណ្ណៈជិះជាន់ផ្សេងៗ និងរបស់អាណានិគមចក្រពត្តិនិយមនៅកម្ពុជា» ។ នៅក្នុងបទសម្ភាសន៍របស់ ប៉ុល ពត ជាមួយគណៈប្រតិភូបែលហ្ស៊ិកនាថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៨ ក៏បាននិយាយដែរថា «វប្បធម៌កម្ពុជាប្រជាធិបតេយ្យមានលក្ខណៈជាវប្បធម៌ថ្មី... លុបបំបាត់ចំណុចណាដែលប្រតិកិរិយា» ។

ការមិនឲ្យមានវប្បធម៌ប្រតិកិរិយា កម្អែលសក្តិភូមិនាយទុនធ្វើឲ្យសង្គមកម្ពុជាប្រជាធិបតេយ្យមានប្រសិទ្ធភាពក្នុងការប្រើអំពើហិង្សា ។ ការធ្វើទារុណកម្មនិងសម្លាប់ ធ្វើឲ្យប្រជាជនគ្រប់រូបខ្លាចបាក់ស្បាត និងខិតខំគោរពប្រតិបត្តិចំពោះវិន័យរបស់អង្គការ ។ សូម្បីតែអ្នកឈឺជិតស្លាប់ក៏ខិតខំប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវវិន័យនេះដែរ ។ អង្គការក៏បានបង្កើតនូវរចនាសម្ព័ន្ធគ្រប់គ្រងថ្មីមួយតាមទស្សនៈមហាលោតផ្លោះមហាអស្ចារ្យ ៣គោនក្នុង១ហិកតា ។ ង៉ែត លន់ ប្រជាជននៅភូមិពងទឹក ខាងជើង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ បាននិយាយថា ឆ្នាំ១៩៧៥ នៅស្រុកត្រាំកក់ អង្គការបានបង្កើតសហករណ៍ហូបបាយរួម ។ ការធ្វើសហករណ៍របស់អង្គការមានលក្ខណៈតឹងតែងខ្លាំងណាស់ ។ ប្រជាជនចាប់ផ្តើមកើតជំងឺហើមដោយសារអត់អាហារនិងធ្វើការងារហួសកម្លាំង ជាពិសេសអ្នក១៧មេសាជានារីភេទ ។ នៅពេលមានជំងឺធ្ងន់ធ្ងរ អ្នកជំងឺបានទៅមន្ទីរពេទ្យ ប៉ុន្តែពេទ្យខ្មែរក្រហមគ្មានថ្នាំអ្វីចែកឲ្យក្រៅពីថ្នាំតែប៉ុន្មានមុខដែលពេទ្យផលិតបានដោយខ្លួនឯងតែប៉ុណ្ណោះ ព្រោះមេដឹកនាំខ្មែរក្រហមបានលុបបំបាត់មន្ទីរពេទ្យនិងបដិសេធបច្ចេកវិទ្យាពេទ្យមកពីរបបមុនៗ ហើយបង្កើតមន្ទីរពេទ្យនិងជ្រើសរើសគ្រូពេទ្យថ្មីដែលខ្លួនយល់ថាស្អាតស្អំនិងមានគោលជំហរបដិវត្តខ្ពស់ ។

បទសម្ភាសន៍ជាមួយ ម៉ាត់ លី បច្ចុប្បន្នជាតំណាងរាស្ត្រមណ្ឌលកំពង់ចាម បានឲ្យដឹងថា អង្គការបានបង្កើតគោលការណ៍ «៨ខ» ដើម្បីកែប្រែសង្គមកម្ពុជាឲ្យទៅជាសង្គមមួយស្អាតស្អំ ។ «ខ» មួយក្នុងចំណោម «ខ» ទាំង៨ បានចែងថា «អង្គការត្រូវលុបបំបាត់ចោលមន្ទីរពេទ្យនិងបុគ្គលិកពេទ្យពីសង្គមចាស់ទាំងអស់ ដើម្បីបង្កើតមន្ទីរពេទ្យថ្មីតាមបែបសង្គមបរិសុទ្ធស្អាតស្អំរបស់បដិវត្តន៍» ។ ពេទ្យបដិវត្តន៍ទៅបម្រើប្រជាជនដល់លំនៅឋាន

និងការដ្ឋានធ្វើការងារតែម្តង ។ នៅក្នុងសៀវភៅកំណត់ហេតុរបស់កម្មាភិបាលពេទ្យម្នាក់បានសរសេរថា «ពេទ្យអង្គការបម្រើអ្នកជំងឺមិនឲ្យទាស់ចិត្ត ពេទ្យមិនត្រូវការលុយកាក់ដូចពេទ្យពីសង្គមចាស់ឡើយ» ។ បទសម្ភាសន៍ជាមួយវេជ្ជបណ្ឌិត ថោង ស៊ិន ទទួលបន្ទុកផ្នែកសុខាភិបាលនៅខេត្តតាកែវ និងឯកសារឧក្រិដ្ឋកម្មប៉ុលពត ប្រព្រឹត្តមកលើប្រជាជននៅទីក្រុងភ្នំពេញ បានឲ្យដឹងថា ពេទ្យរបស់អង្គការពិតជាបានបម្រើប្រជាជនមែន ។ ពេទ្យបានដើរចាក់និងចែកថ្នាំព្យាបាលប្រជាជនដល់ការដ្ឋានធ្វើការងារ ប៉ុន្តែការចាក់និងចែកថ្នាំនោះគ្មានលក្ខណៈបច្ចេកទេសទាល់តែសោះ ទោះជាអ្នកជំងឺឈឺអ្វីក៏ដោយ ក៏ពេទ្យចែកនិងចាក់ថ្នាំឲ្យតែមួយមុខដែរ ។ ពេទ្យអង្គការសុទ្ធតែនារីក្មេងៗអាយុពី១៤-១៥ឆ្នាំ រៀនវគ្គបណ្តុះបណ្តាលបច្ចេកទេសពេទ្យយ៉ាងយូរ៣ខែ ។

នារីក្មេងៗដែលពុះពោរទៅដោយកំហឹងវណ្ណៈនិងមានឆន្ទៈដាច់ខាតក្នុងបុព្វហេតុបដិវត្តន៍ ត្រូវបានជ្រើសរើសឲ្យចូលបម្រើវិស័យសុខាភិបាលតាមគោលនយោបាយរបស់បក្ស ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជា ជូនចំពោះបក្សពលករដាណឺម៉ាក ដែលថ្លែងដោយ នួន ជា កាលពីខែកក្កដា ឆ្នាំ១៩៧៨ បាននិយាយថា «ពេទ្យបដិវត្តន៍ត្រូវតែចេញពីវណ្ណៈកម្មករកសិករ ព្រោះវណ្ណៈកសិករជាវណ្ណៈធំជាងគេ ហើយវណ្ណៈកម្មករជាវណ្ណៈចម្រើន...។ បក្សត្រូវការជំហរវណ្ណៈធំជាងសមត្ថភាពក្នុងការកសាងប្រទេស» ។ នារីពេទ្យក្មេងៗមិនសូវចេះអក្សរដែលអង្គការជ្រើសរើស ត្រូវទទួលការបណ្តុះបណ្តាលដោយវិធីអនុវត្តផ្ទាល់ ។ ការបណ្តុះបណ្តាលរយៈពេលខ្លី បានធ្វើឲ្យនារីពេទ្យបានទទួលចំណេះដឹងត្រឹមតែចាក់និងចែកថ្នាំឲ្យអ្នកជំងឺប៉ុណ្ណោះ ។ ពេលខ្លះ នារីពេទ្យឲ្យថ្នាំខុស បណ្តាលឲ្យអ្នកជំងឺប្រតិកម្មនិងស្លាប់អស់ជាច្រើន ។

នៅឆ្នាំ១៩៧៥ គឹម អ៊ន នៅភូមិទួលត្បែង ឃុំជាងទង ស្រុកត្រាំកក់ ហៀបនឹងស្លាប់ដោយសារការចាក់ថ្នាំ ។ អ៊ន និយាយថា គ្រាន់តែនារីពេទ្យដកម្ជុលចេញភ្លាម គាត់ក៏ប្រកាច់បញ្ច្រាសភ្នែកមួយរំពេច និងបន្ទោរបង់ទឹកនោមសុទ្ធតែឈាម ។ នារីពេទ្យខ្មែរក្រហមច្រឡំយកថ្នាំសម្រាប់ព្យាបាលមាន់ទៅចាក់ឲ្យ គឹម អ៊ន ។ មូលហេតុដែលច្រឡំមកពីដបថ្នាំសម្រាប់មាន់ដាក់នៅជិតដបថ្នាំសម្រាប់មនុស្ស ហើយថ្នាំទាំងពីរនេះមានលក្ខណៈស្រដៀងគ្នា ។


អ៊ិត ស្តើង

អ៊ិត ស្តើង អតីតនារីពេទ្យខ្មែរក្រហម បាននិយាយថា នៅឆ្នាំ១៩៧៥ នារីម្នាក់ឈ្មោះ អំ ប្រកាច់ស្លាប់ភ្លាម បន្ទាប់ពីប្រធានពេទ្យឈ្មោះ បូ ចាក់ថ្នាំឲ្យ ។ ស្ត្រីអ្នក១៧មេសាម្នាក់នៅស្រុកត្រាំកក់ គាំងបេះដូងស្លាប់មួយរំពេច បន្ទាប់ពីពេទ្យដកម្ជុលចេញពីសាច់ ។

លោកយាយ ហែម អឿន និយាយថា ឆ្នាំ១៩៧៦ គាត់កើតជំងឺញាក់និងឈឺស្បូន ហើយត្រូវបានអង្គការបញ្ជូនទៅព្យាបាលនៅពេទ្យឃុំព្រៃល្វា ។ នារីពេទ្យនៅទីនោះសុទ្ធតែក្មេងៗ មានអាយុ១៤-១៥ឆ្នាំ ។ នៅពេលលេបថ្នាំម្តងៗ លោកយាយវិលមុខនិងស្រវាំងភ្នែកមើលអ្វីមិនឃើញ ។ វិធីបន្សាបប្រតិកម្មថ្នាំរបស់ខ្មែរក្រហមគឺឲ្យអ្នកជំងឺទទួលទានស្ករ ។ រយៈពេល៥ខែនៃការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ជំងឺរបស់លោកយាយនៅតែមិនជាដដែល ។ ដោយធុញថប់នឹងការនៅក្នុងមន្ទីរពេទ្យយូរ លោកយាយក៏សុំពេទ្យត្រឡប់មកផ្ទះវិញ សុខចិត្តទៅធ្វើការទាំងឈឺមិនទាន់ជាសះស្បើយ ។

បទសម្ភាសន៍ជាមួយវេជ្ជបណ្ឌិត ថោង ស៊ិន បានឲ្យដឹងថា នៅតាមមូលដ្ឋាននានា អង្គការបានរៀបចំមន្ទីរពេទ្យសម្រាប់ព្យាបាលអ្នកជំងឺ ប៉ុន្តែលទ្ធភាពនិងលក្ខខណ្ឌព្យាបាលរបស់នារីពេទ្យក្មេងៗ មិនបានបំពេញតាមតម្រូវការរបស់អ្នកជំងឺឡើយ ។ ពេទ្យខ្មែរក្រហមពិនិត្យរោគវិនិច្ឆ័យដោយប្រើដៃស្ទាប និងចេះព្យាបាលតែជំងឺណាដែលមើលឃើញនឹងភ្នែក ដូចជា របួសបូស ដំបៅ រាករូស និងគ្រុនបត្តិចបន្តួចប៉ុណ្ណោះ ចំណែកជំងឺខាងក្នុងខ្លួនដូចជាជំងឺស្បូន ពោះវៀន ក្រពះជាដើម ពេទ្យរករោគវិនិច្ឆ័យមិនឃើញទេ ។ នៅពេលដែលរករោគវិនិច្ឆ័យមិនឃើញ ពេទ្យខ្មែរក្រហមចោទអ្នកជំងឺថា«ឈឺសតិអារម្មណ៍» ហើយចាប់

យកទៅសម្លាប់ចោល ។ ដោយសារតែហេតុនេះហើយទើបស្ត្រីមួយចំនួនមិនហ៊ានប្រាប់មេកងថាខ្លួនមានជំងឺទេ សុខចិត្តទ្រាំធ្វើការងាររហូតដល់ស្លាប់ ។ មួយចំនួនទៀតមានជំងឺរ៉ាំរ៉ៃរហូតដល់បច្ចុប្បន្ន ។


ងិន ហាន

ងិន ហាន នៅភូមិទឹកថ្លា ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ បាននិយាយថា ក្នុងរបបប៉ុលពត អ្នកជំងឺមួយចំនួនស្លាប់នៅនឹងកន្លែងធ្វើការ ព្រោះយកមកពេទ្យមិនទាន់ ។ បងស្រីបន្ថែមថា នៅពេលដែលស្ត្រីឈឺ អង្គការមិនថាឈឺព្រោះតែខំប្រឹងធ្វើការនិងទទួលរបបអាហារតិចទេ បែរជាចោទថាឈឺសតិអារម្មណ៍ ។ ហេតុដូច្នេះហើយទើបស្ត្រីខ្លះឈឺហើយនៅតែខំធ្វើការ មិនហ៊ានសុំឈប់សម្រាក ព្រោះខ្លាចអង្គការចោទថាឈឺសតិអារម្មណ៍ ។ ស្ទើរតែរៀងរាល់ថ្ងៃ មានស្ត្រី១៧មេសាជាច្រើននាក់ដួលស្លាប់នៅលើការដ្ឋាន ។

យិន សាមុត អតីតគ្រូពេទ្យនៅខេត្តស្វាយរៀង បានរៀបរាប់ថា នៅក្នុងមន្ទីរពេទ្យមានអ្នកជំងឺស្ត្រីច្រើនណាស់ ភាគច្រើនជាជំងឺខ្វះជីវជាតិ ឈឺស្បូន របេង បាក់កម្លាំង និងគ្រុនចាញ់ ។

ចម្លើយសារភាពរបស់ ឈុន ហៀក នៅគុកទួលស្លែង បាននិយាយថា នៅឆ្នាំ១៩៧៦ គាត់បានពិនិត្យអ្នកជំងឺស្ត្រីម្នាក់ជាប្រពន្ធរបស់ ញឹម លេខាភូមិភាគពាយ័ព្យ ឃើញកើតជំងឺដុះសាច់ក្នុងស្បូន ក៏ប៉ុន្តែពេលអ្នកជំងឺមកពិនិត្យនៅពេទ្យ១៧មេសា បែរជាឃើញជំងឺស្ងួតទៅវិញ ។


អ៊ុក ឡាយអ៊ីម

អ៊ុក ឡាយអ៊ីម នៅភូមិអង្គតាសោម ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ បាននិយាយថាឆ្នាំ១៩៧៦ នៅឃុំអង្គតាសោមមានស្ត្រីជាច្រើនមានរោគប្រចាំកាយ ដោយហេតុអង្គការប្រើឲ្យលើកទំនប់កាត់បឹង ត្រូវត្រាំក្នុងទឹកមួយថ្ងៃទល់ល្ងាច ។ នៅពេលយប់ ស្ត្រីទាំងអស់នោះត្រូវដេកទាំងសម្លៀកបំពាក់សើម ព្រោះគ្មានសម្លៀកបំពាក់សម្រាប់ផ្លាស់ប្តូរ ។ ដូច្នេះមេរោគក៏ជ្រៀតចូលបង្កជាជំងឺគ្រប់ប្រភេទ ។ អ្នកឈឺល្មមៗ មេកងមិនអនុញ្ញាតឲ្យទៅមន្ទីរពេទ្យទេ លុះត្រាតែឈឺធ្ងន់សន្លប់លែងដឹងខ្លួន ទើបបញ្ជូនមកមន្ទីរពេទ្យ ។ អ្នកណាឈឺល្មមៗធ្វើការមិនរហ័សរហួន មេកងចោទថាឈឺសតិអារម្មណ៍ជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ត្រូវទទួលរងការវាយដំប្រំផាក់ ឬកាត់របបអាហារ ។ ឡាយអ៊ីម បន្ថែមថា «*ចោទថាឈឺសតិអារម្មណ៍នោះមិនពិតទេ ដូចជាស្ត្រីមានរោគក្នុងខ្លួន ឈឺស្បូនរ៉ាំរ៉ៃ ស្ត្រីកូនខ្ចីទាស់សរសៃ ស្ពមរឹងរៃធ្វើការមិនបាន ដល់ទៅពេទ្យ ពេទ្យគ្មានសមត្ថភាពពិនិត្យ គ្មានសម្ភារបច្ចេកទេសសម្រាប់ឆ្លុះដឹងតែស្ទាបទៅឃើញក្តៅថាក្តៅ ឃើញត្រជាក់ថាត្រជាក់ ។ ចំណែកជំងឺក្នុងខ្លួនពេទ្យមើលមិនឃើញ ក៏ចោទថាឈឺសតិអារម្មណ៍ ចាប់បញ្ជូនទៅធ្វើទារុណកម្មរហូតដល់ស្លាប់ក៏មាន*» ។

អាយ ណាសឿន បាននិយាយថា នៅការដ្ឋានរបស់គាត់ អង្គការបង្ខំឲ្យធ្វើពលកម្មតាំងពីព្រឹករហូតដល់ម៉ោង១០យប់ ។ ពេលមានរដូវ បងស្រីបានសុំច្បាប់មេកងឈប់សម្រាក ប៉ុន្តែមេកងបែរជាចោទថាខ្ជិលច្រអូស ប្រឆាំងនឹងផែនការរបស់អង្គការ ។

ប៉ែន ចាន់តារា បច្ចុប្បន្នជាគ្រូបង្រៀននៅរាជធានីភ្នំពេញ បានឲ្យដឹងថា គាត់ត្រូវមេកងបញ្ជូនទៅមន្ទីរពេទ្យបន្ទាប់ពីដួលសន្លប់នៅការដ្ឋាននៅឃុំអូរនាងនុង ឃុំចំការលើ ។ ចាន់ដារា ដួលសន្លប់ដោយសារមានជំងឺធ្លាក់សធ្ងន់ធ្ងរ ។ នៅមន្ទីរពេទ្យ កម្មាភិបាលពេទ្យគ្មានសមត្ថភាពព្យាបាលជំងឺរបស់គាត់ឡើយ ។ ចាន់ដារា បានដើររកដើមនិងឫសឈើយកមកដាំទឹកហូបដោយខ្លួនឯង ប៉ុន្តែថ្នាំនេះមិនបានធ្វើឲ្យជំងឺរបស់គាត់ជាសះស្បើយទេ ។ ជំងឺរបស់គាត់បានក្លាយជាជំងឺរលាកស្បូនរហូតមកដល់បច្ចុប្បន្ន ។ ចាន់ដារា បញ្ជាក់ថា ជំងឺធ្លាក់សកើតមកពីការធ្វើពលកម្មត្រាំក្នុងទឹករយៈពេលយូរ បណ្តាលឲ្យសត្វល្អិតនិងមេរោគគ្រប់ប្រភេទងាយនឹងជ្រៀតចូលបង្កជារោគផ្សេងៗ ។ មិនមែនតែ ចាន់ដារា

ម្នាក់ទៀតដែលកើតរោគស្ត្រីនេះ ។ នៅក្នុងការដ្ឋានជាមួយគាត់មានស្ត្រីច្រើនណាស់ដែលមានរោគប្រចាំកាយ ។ ចាន់តារាបានបន្ថែមថា នៅឆ្នាំ១៩៧៧គាត់មានផ្ទៃពោះ ប៉ុន្តែនៅតែបន្តធ្វើការងារនៅការដ្ឋានរហូតដល់ថ្ងៃសម្រាលកូន ។ បន្ទាប់ពីសម្រាលកូនបានតែប៉ុន្មានថ្ងៃ ចាន់ដារា ត្រូវអង្គការដាក់ទិសឲ្យទៅធ្វើជាមេដោះនៅមណ្ឌលទារកទៀត ។ មួយថ្ងៃៗ ចាន់ដារាត្រូវបំបៅក្មេងជាច្រើននាក់ ប៉ុន្តែមិនបានទទួលរបបអាហារលើសពីមួយវែកឡើយ ជាហេតុធ្វើឲ្យគាត់ហេវហត់អស់កម្លាំងរាងកាយចុះទន់ខ្សោយជាលំដាប់ ។

វណ្ណា សមាជិកឃុំលាយបូ ស្រុកត្រាំកក់ ខេត្តតាកែវ បានរៀបរាប់ទាំងទឹកភ្នែកថា “នៅឆ្នាំ១៩៧៧ ខ្ញុំទាស់ស្គមរីងរៃ ត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ តែពេទ្យរបស់អង្គការសាហាវណាស់ វាចោទខ្ញុំថាឈឺសតិអារម្មណ៍ ។ តាមពិតខ្ញុំឈឺពិតមែន ។ ពួកវាបង្អត់បាយខ្ញុំ ។ ខ្លួនខ្ញុំស្គមតូច ក្បាលជង្គង់ធំជាងក្បាលទៅហើយ ពួកវានៅតែមើលមិនឃើញ ។ ពួកវាស្អប់អ្នក១៧មេសាខ្លាំងណាស់ ។ ឪពុកម្តាយនិងកូនទាំងអស់របស់ខ្ញុំត្រូវស្លាប់យ៉ាងវេទនា ។ សព្វថ្ងៃខ្ញុំរស់នៅតែម្នាក់ឯងគ្មានសាច់ញាតិបងប្អូនទេ ។ ទោះបីរាល់ថ្ងៃបានសេចក្តីសុខស្រួលក៏ដោយ ក៏ខ្ញុំមិនអាចបំភ្លេចរបបដ៏អប្រិយនេះដែរ” ។

របបកម្ពុជាប្រជាធិបតេយ្យបានកំណត់របបការងារឲ្យប្រជាជនធ្វើការយ៉ាងតិច១៦ម៉ោងក្នុងមួយថ្ងៃ ។ ការងារត្រូវបែងចែកទៅតាមអាយុនិងភេទ ។ ស្ត្រីនៅលីវនិងស្ត្រីមានប្តីត្រូវចាត់ចូលជាកម្លាំងស្រួច ហើយមានការងារស្មើបុរសដែរ ។ មាត្រាទី១៨នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ចែងថា “បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាលើគ្រប់វិស័យទាំងអស់” ។ ហេតុដូច្នេះហើយទើបស្ត្រីត្រូវធ្វើការងារស្មើនឹងបុរសដែរ ។ ការងារដ៏មមាញឹកគ្មានពេលសម្រាក រួមផ្សំនឹងចំណីអាហារតិចតួចបណ្តាលឲ្យស្ត្រីធ្លាក់ចូលក្នុងសភាពទន់ខ្សោយ បាក់កម្លាំង និងមានជំងឺប្រចាំកាយ ។

ខៀវ សំផន ប្រធាននៃគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ បានទូលថ្វាយសម្តេច ព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៧៦ថា “បណ្តាជនរួមជាតិដែលត្រូវជម្លៀស សុទ្ធតែមានសុខភាពល្អប្រសើរទាំងអស់ ។ ពួកគេធ្វើការលំបាកពិតមែន ប៉ុន្តែធ្វើដោយស្ម័គ្រចិត្តនិងសប្បាយរីករាយយ៉ាងខ្លាំង” ។ ការពិតនោះគឺ ប្រជាជនទាំងអស់ត្រូវទទួលការគាបសង្កត់ពីអង្គការ ការបង្អត់អាហារ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មយ៉ាងធ្ងន់ធ្ងរ ។

របបកម្ពុជាប្រជាធិបតេយ្យពុំមានច្បាប់អនុញ្ញាតឲ្យស្ត្រីមានផ្ទៃពោះសម្រាកមុននិងក្រោយពេលសម្រាលកូនឡើយ ។ ស្ត្រីមានផ្ទៃពោះត្រូវបង្ខំឲ្យធ្វើការរហូតដល់ថ្ងៃសម្រាលកូន ។ បន្ទាប់ពីសម្រាលកូនប្រមាណពីរឬបីសប្តាហ៍ ស្ត្រីត្រូវត្រឡប់ទៅធ្វើពលកម្មវិញ ។ ក្នុងអំឡុងពេលសម្រាលកូនឬដេកឈឺមិនបានបំពេញការងារពលកម្មជូនសមូហភាព ស្ត្រីត្រូវបានអង្គការកាត់បន្ថយរបបអាហារ ។ លើសពីនេះទៅទៀត ពេទ្យអង្គការនឹងដេញអ្នកជំងឺចេញពីមន្ទីរពេទ្យឲ្យទៅធ្វើការនៅការដ្ឋានវិញភ្លាម ប្រសិនបើឃើញថាអ្នកជំងឺណាម្នាក់បរិភោគអាហារអស់ពីចាន ព្រោះពេទ្យយល់ថា ប្រសិនបើអ្នកជំងឺបរិភោគអាហារអស់ពីចាន បានន័យថាអ្នកជំងឺជាសះស្បើយហើយ និងអាចបំពេញការងារពលកម្មបាន ដូច្នេះត្រូវតែត្រឡប់ទៅធ្វើការវិញជាបន្ទាន់ ។ ស្ត្រីកូនខ្ចីភាគច្រើនទាស់ស្គមរីងរៃ និងខ្វះទឹកដោះឲ្យកូនបៅ ។ ស្ត្រីក្រុមខ្លះទៀតមានជំងឺស្បូនដោយសារតែធ្វើពលកម្មហួសហេតុ ។

យង់ សម្រាលកូនបានជាងកន្លះខែ ត្រូវអង្គការដាក់ទិសឲ្យទៅកើបអាចម៍គោ បោសសំរាម និងសែងដី ។ ក្រោយមក យង់ ក៏មានជំងឺទាស់គ្មានទឹកដោះ ដោយសារតែការងារធ្ងន់ធ្ងរ និងរបបអាហារតិច ។

អោក ស៊ុម សម្រាលកូននៅឆ្នាំ១៩៧៧ ។ បន្ទាប់ពីសម្រាលកូនរួចបានតែប៉ុន្មានថ្ងៃ អង្គការបានចាត់តាំងគាត់និងស្ត្រីកូនខ្ចីម្នាក់ទៀត ឲ្យមើលកុមារតូចៗចំនួន៤០នាក់ ។ កុមារទាំងនោះមានអាយុចាប់ពី២ខែដល់២ឆ្នាំ ។ អោក ស៊ុម និយាយថា ក្នុងមួយថ្ងៃៗគាត់អស់កម្លាំងស្ទើរតែដួលរលំទៅហើយ ដោយសារគាត់មានគ្នាតែ២នាក់ ប៉ុន្តែត្រូវមើលក្មេងដល់ទៅ៤០នាក់ ។ ម្យ៉ាងទៀត គាត់ត្រូវបំបៅដោះក្មេងថែមទៀត ឯរបបអាហារដូចអ្នកធ្វើពលកម្មធម្មតាដែរ ហូបមិនគ្រប់គ្រាន់

មានតែបបរជាមួយសម្លត្រកួនព្រលឹត ជាហេតុធ្វើឲ្យគាត់កាន់តែខ្សោយទៅៗ ។

វៀល សន អតីតប្រធានពេទ្យស្រុកត្រាំកក់ បច្ចុប្បន្នរស់នៅភូមិព្រៃតាលី ឃុំត្រពាំងធំខាងជើង បានឲ្យដឹងថា គាត់តែងតែរាយការណ៍ទៅថ្នាក់លើអំពីស្ត្រីជាច្រើនដែលមានជំងឺស្បូន ប៉ុន្តែអង្គការមិនជឿទេ ថែមទាំងចោទគាត់ថា វាយប្រហារអង្គការទៅវិញ ។

អ៊ុច គីមអ៊ន នៅភូមិទួលត្បែង ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ បាននិយាយថា ស្ត្រីម្នាក់ៗខ្លាចស្លាប់ ទើបខិតខំធ្វើការងារធ្ងន់ៗផ្គាប់ចិត្តថ្នាក់លើ រែកដីប្រណាំងគ្នាសុទ្ធតែត្រូតបង្គី ចំណែករបបអាហារវិញគឺតិចបំផុត ។ ព្រោះតែដូច្នេះហើយទើបស្ត្រីភាគច្រើនមានជំងឺស្បូន ។

មីងយី នៅឃុំក្រសាំង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល វិះនឹងបាត់បង់ជីវិតដោយសារជំងឺស្បូនរបស់គាត់ ។ បន្ទាប់ពីប្តីរបស់ មីងយី ត្រូវអង្គការកម្ទេច គាត់ត្រូវអង្គការបង្ខំឲ្យធ្វើការធ្ងន់ធ្ងរទាំងនៅសរសៃខ្ចី ។

ទាំងការព្យាបាលជំងឺនិងការបង្កើតទារក ពេទ្យខ្មែរក្រហមពុំបានតាមដាននិងត្រួតពិនិត្យឲ្យហ្មត់ចត់តាមលក្ខណៈវិទ្យាសាស្ត្រនិងអនាម័យទេ ហើយក៏ពុំបានផ្តល់អាហារឲ្យបានគ្រប់គ្រាន់ដែរ ។ ការធ្វេសប្រហែសនេះបណ្តាលឲ្យមាតានិងទារកត្រូវប្រឈមមុខនឹងការបាត់បង់ជីវិតជាច្រើន ។

នារីពេទ្យខ្មែរក្រហមម្នាក់ឈ្មោះ ធួន ធ្វើការនៅពេទ្យព-១ (ពេទ្យកាល់ម៉ែត) បានឲ្យដឹងថា ពីឆ្នាំ១៩៧៧រហូតដល់ឆ្នាំ១៩៧៩ មន្ទីរពេទ្យព-១បានទទួលកុមារជាច្រើនឲ្យសម្រាកព្យាបាលជំងឺ ។ កុមារដែលមានវាសនាមកសម្រាកព្យាបាលនៅមន្ទីរពេទ្យក្នុងក្រុងភ្នំពេញ សុទ្ធតែជាកូនកម្មាភិបាលធំៗប្រចាំស្រុក ខេត្ត និងភូមិភាគ ។ ចំណែកឯកុមារ១៧មេសាគ្មានវាសនាបានមកព្យាបាលជំងឺនៅមន្ទីរពេទ្យនេះឡើយ ។ កុមារដែលមកព្យាបាលភាគច្រើនកើតជំងឺគេតាណូស ស្វិតដៃជើង កញ្ជ្រឹល អុតស្វាយ របេង ខាន់លឿង គ្រុនក្តៅ ជំងឺឆ្លង រាករូស និងអាសន្នរោគ ។ ក្នុងមួយថ្ងៃៗមានកុមារស្លាប់ច្រើនណាស់ ។ ជំងឺទាំងអស់នេះបណ្តាលមកពីកង្វះអនាម័យរបស់ពេទ្យឆ្មបក្នុងពេលបង្កើតទារក និងការថែរក្សាក្មេងមិនបានដិតដល់ ។

នៅឆ្នាំ១៩៧៧ កូនស្រីអាយុ៨ខែរបស់ ស៊ីគឿន បានស្លាប់ដោយសារជំងឺតេតាណូស ។ ឆ្នាំដដែលនេះ កូនតូចអាយុ១ឆ្នាំរបស់ អោក ស៊ុម មានជំងឺតេតាណូសនិងខ្វះជីវជាតិ ។ កូនរបស់ អោក ស៊ុម រស់រានមានជីវិតបានអាស្រ័យដោយមើមឈើឬសឈើដែលគាត់ខិតខំរកមកដាំទឹកឲ្យហូប ។

កិច្ចសម្ភាសន៍ជាមួយស្ត្រីជាច្រើនបានឲ្យដឹងថា កុមារភាគច្រើនស្លាប់ដោយសារជំងឺកញ្ជ្រឹល អុតស្វាយ តេតាណូស និងខ្វះជីវជាតិ ។ កង្វះអនាម័យរបស់ឆ្មបបានបណ្តាលឲ្យកុមារកើតជំងឺតេតាណូស ។ សម្ភារដែលឆ្មបខ្មែរក្រហមប្រើប្រាស់ក្នុងការបង្កើតទារក គ្មានអ្វីក្រៅពីកន្ត្រៃច្រែះស៊ីដែលគ្មានការសម្លាប់មេរោគ និងការផ្តល់ថ្នាំបន្តិចបន្តួច ។ បន្ទាប់ពីសម្រាលកូនរួចស្ត្រីបានទទួលថ្នាំអាចម៍ទន្សាយដែលពេទ្យខ្មែរក្រហមផលិតដោយខ្លួនឯង ។ ស្ត្រីមួយចំនួនបានស្លាប់ក្នុងពេលសម្រាលកូន ។ នៅក្នុងរបាយការណ៍ស្តីអំពីការស៊ើបអង្កេតបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបន ប៉ុល ពត អៀង សារី បានប្រព្រឹត្តមកលើប្រជាជនទីក្រុងភ្នំពេញ រៀបចំកាលពីឆ្នាំ១៩៧៩ បានសរសេរថា “ភាគច្រើន ស្ត្រីដែលមានលទ្ធភាពមានផ្ទៃពោះនិងបង្កើតកូនគឺស្ត្រីជាអ្នកមូលដ្ឋាន ចំណែកស្ត្រីជាអ្នក១៧មេសាអង្គការមិនពេញចិត្តឲ្យមានផ្ទៃពោះឡើយ ទុកឲ្យបំពេញការងារខាងផលិតកម្មវិញ” ។

ស្ត្រីមួយចំនួនបានរលូតកូនក្នុងពេលកំពុងបំពេញការងារ ។ អង្គការហាមមិនឲ្យនរណាម្នាក់និយាយពីរឿងស្ត្រីមានជំងឺឬរលូតកូនឡើយ ។ គ្រីយ បេងហុង បានឲ្យដឹងថា នៅឆ្នាំ១៩៧៨ នៅសហករណ៍ស្រុកកងមាស ប្រពន្ធរបស់គាត់ដែលមានផ្ទៃពោះ២ខែ និងប្អូនស្រីជីទួតមួយដែលមានផ្ទៃពោះ៦ខែ បានរលូតកូនកណ្តាលវាលស្រែ ។

អ្នកជំងឺស្ត្រីទាំងឡាយដែលមកសម្រាកព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យ ក្រៅពីមិនបានទទួលការព្យាបាលនិងថែទាំដិតដល់ពីគ្រូពេទ្យប៉ុណ្ណោះទេ ថែមទាំងទទួលរងគ្រោះថ្នាក់ពីការពិសោធន៍ថ្នាំរបស់អង្គការ ឬត្រូវសម្លាប់ក្រោមការចោទប្រកាន់ថាឈឺសតិអារម្មណ៍ទៀត ។ ក្រៅពីគ្រោះថ្នាក់ខាងលើនេះ ការទៅ



នារីពេទ្យខ្មែរក្រហមកំពុងផលិតថ្នាំគ្រាប់

សម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យកាន់តែប្រឈមនឹងការឆ្លងនូវប្រភេទជំងឺជាច្រើនទៀត ដោយមូលហេតុថា នៅក្នុងមន្ទីរពេទ្យសម្បូរទៅដោយ ចៃ សង្កើច រុយ និងមូស ដែលជាភ្នាក់ងារចម្លងជំងឺគ្រប់ប្រភេទ ។ ជំងឺអាសន្នរោគ គ្រុនចាញ់ រាករូស រាគត្បាតយ៉ាងឆាប់រហ័សតាមរយៈពពួកសត្វល្អិតទាំងអស់នេះ ។ ជួនកាល អ្នកជំងឺសុខចិត្តសម្រាកព្យាបាលខ្លួននៅផ្ទះ ហើយស្វែងរកថ្នាំឫសឈើមើមឈើមកដាំទឹកផឹក ប្រសើរជាងទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។

ក្រៅពីជំងឺក្នុងរាងកាយដែលបណ្ដាលមកពីកង្វះអាហារនិងការងារហួសកម្លាំង ស្ត្រីភាគច្រើនមានជំងឺមួយប្រភេទទៀតដែលធ្ងន់ធ្ងរដូចគ្នា គឺជំងឺសរសៃប្រសាទ ។ ដោយសារការនិរាសព្រាត់ប្រាសក្រុមគ្រួសារ កូនចៅ ប្ដីសី ញាតិមិត្តបងប្អូន ធ្វើឲ្យស្ត្រីពិបាកចិត្ត គិតច្រើន ភ្លេចមុខភ្លេចក្រោយ ក្លាយទៅជាមនុស្សវិកលចរិតនិយាយផ្ដេសផ្ដាសលែងដឹងខុសត្រូវ ជួនកាលនិយាយប៉ះពាល់ដល់គោលនយោបាយរបស់អង្គការ ក៏ត្រូវអង្គការយកទៅកម្ទេចចោលក៏មាន ។ ជំងឺនេះមានឥទ្ធិពលយូរអង្វែងរហូតមកដល់បច្ចុប្បន្ន ។ ទោះបីជារបបខ្មែរក្រហមបានរលំរលាយទៅអស់រយៈកាលជាង២០ឆ្នាំមកហើយក៏ដោយ ក៏ក្ដីនឹករឭកទុក្ខព្រួយសោកសៅដែលបណ្ដាលមកពីការបាត់បង់ប្ដីនិងកូនជាទីស្រលាញ់ នៅតែដក់ជាប់ក្នុងចិត្តរបស់ស្ត្រីមិនអាចលុបបានឡើយ ។ ស្ត្រីជាច្រើននៅតែយំស្ដាយប្ដីនិងកូន ។ ស្ត្រីមេម៉ាយខ្លះមិនព្រមយកប្ដីទៀតទេ សុខចិត្តលំបាកចិញ្ចឹមកូនតែម្នាក់ឯង ។

លោកយាយ ហែម អឿន ក្លាយជាមនុស្សវិកលចរិតដោយសារតែអង្គការបានសម្លាប់ប្ដីនិងកូនទាំងបីនាក់របស់គាត់ ។ លោកយាយដើរស្រែកច្រៀងថ្ងាថ្ងៃពីទុក្ខសោករបស់គាត់ដែលព្រាត់ប្រាសប្ដីនិងកូនជាទីស្រលាញ់ ។ បច្ចុប្បន្ននេះ លោកយាយបានជាសះស្បើយពីជំងឺវិកលចរិត ប៉ុន្តែផ្លូវចិត្តរបស់លោកយាយនៅតែមានរបួសដដែល ។ លោកយាយបញ្ជាក់ថា «ខ្ញុំឆ្កួតក៏ព្រោះតែកូននិងប្ដីស្លាប់ចោល» ។

មីង រ៉េន នៅឃុំសៀមរាប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ក្លាយជាមនុស្សវិកលចរិតបន្ទាប់ពីកូននិងប្ដីរបស់គាត់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ក្រោយឆ្នាំ១៩៧៩ មីង រ៉េន មានលក្ខណៈជាមនុស្សមិនសូវគ្រប់ទឹក ហើយនិយាយស្ដីមិនសូវដឹងខុសត្រូវ ។ ឆ្នាំ១៩៩០ គាត់បានជាសះស្បើយពីជំងឺផ្លូវចិត្ត និងបានរៀបការជាមួយបុរសម្នាក់ទៀត ។ ជាវាសនាអាក្រក់ កូនរបស់មីងរ៉េននិងប្ដីក្រោយ ក៏ស្លាប់ជាបន្តបន្ទាប់ទៀតដោយសារជំងឺ ។ រឿងរ៉ាវអតីតកាលបន្សល់ពីរបបខ្មែរក្រហម គួបផ្សំនឹងរឿងរ៉ាវទើបនឹងកើតឡើងថ្មីៗ ធ្វើឲ្យ មីងរ៉េន ក្លាយទៅជាមនុស្សវិកលចរិតម្ដងទៀតព្យាបាលលែងជា ។

ដោយសារគោលនយោបាយ «ឯករាជម្ចាស់ការ ខ្លួនទីពឹងខ្លួន បំបាត់វប្បធម៌ចាស់ចោល បង្កើតវប្បធម៌ថ្មីស្អាតស្អំ» របបកម្ពុជាប្រជាធិបតេយ្យបានបន្សល់ទុករាប់មិនអស់នូវស្ត្រីមេម៉ាយ ស្ត្រីមានវិបត្តិផ្លូវចិត្ត វិកលចរិត កុមារកំព្រាអនាថា មានកាយសម្បទាមិនរឹងមាំ បញ្ញាខ្សោយ និងវិបត្តិសង្គមជាច្រើនទៀតដែលអ្នកនៅរស់ត្រូវប្រឈមមុខដោះស្រាយ ។

**វ៉ែអម សុខឃីម**

# ករណីយកិច្ចក្នុងការចោទប្រកាន់អំពីរំលោភសិទ្ធិមនុស្ស

ប្រទេសនានាដែលកំពុងតែរំកិលខ្លួនចេញពីរបបគាបសង្កត់ផ្តាច់ការ តែងតែជួបប្រទះនឹងស្ថានការណ៍លំបាកថាតើត្រូវប្តឹងផ្តល់អំពីការរំលោភសិទ្ធិមនុស្សនៃរបបមុនៗដែរឬយ៉ាងណា ។ ទស្សនៈការណ៍តាមទ្រឹស្តីជាច្រើនត្រូវបានប្រកាន់យកក្នុងគោលបំណងគាំទ្រចំពោះជំហរនីមួយៗផ្សេងៗគ្នា ។ មានអ្នកខ្លះទាញហេតុផលថា ល្អិកណាចារីនៃបទល្មើសត្រូវបាននាំមកកាត់ទោសជាបន្តបន្ទាប់ទៅតាមទំហំនៃកំហុស សង្គមក៏ចេះតែគាំទ្រដល់ការប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សទៅតាមនោះដែរ ។ មានមតិខ្លះនិយាយប្រាសមកវិញថា ការផ្តន្ទាទោសច្បាស់លាស់និងជាលក្ខណៈផ្លូវការទៅលើអំពើឃោរឃៅវាសំខាន់ហើយ ក៏ប៉ុន្តែចំនួនមនុស្សដែលត្រូវបានយកមកកាត់ទោសមិនមែនជាបញ្ហាទេ ។ អ្នកដែលគាំទ្រជំហរទីមួយនិយាយថា ការអភ័យទោសបញ្ជាក់ថាអ្នកដែលមានអំណាចនិងឥទ្ធិពលមិនស្ថិតនៅក្រោមសំណាញ់ច្បាប់ឡើយ ។ ហ្សូ ហ្សាឡាកែត ទាញហេតុផលផ្សេងពីនេះថាប្រទេសនានាគួរតែចូលរួមជាបន្ទាន់ក្នុងការទប់ស្កាត់មិនឲ្យអំពើរំលោភសិទ្ធិមនុស្សកើតឡើងសាជាថ្មី និងជួសជុលសំណងការខូចខាតដែលបង្កឡើងដោយការរំលោភពីអតីតកាល ។ តែទោះជាយ៉ាងណា នៅក្នុងចំណោមអ្នកទ្រឹស្តីទាំងនោះក៏មានការមូលមតិគ្នាថា បើនិយាយគ្រប់ជ្រុងជ្រោយ បុព្វហេតុនៃសិទ្ធិមនុស្ស ការជំរឿនលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋ តម្រូវឲ្យមានការស៊ើបអង្កេតនិងការកាត់សេចក្តីទៅលើការរំលោភសិទ្ធិមនុស្សដែលបង្កឡើងដោយរបបមុនៗ ។

ថ្វីបើមានកត្តាដែលត្រូវបញ្ចូលក្នុងការធ្វើវិនិច្ឆ័យយ៉ាងនេះក៏ដោយ ក៏មានអ្នកច្បាប់មួយចំនួនបានទាញជាអំណះអំណាងថាច្បាប់អន្តរជាតិធ្វើឲ្យរដ្ឋនានាមានកាតព្វកិច្ចក្នុងការចោទប្រកាន់ទៅលើការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ពោលគឺជាអំពើដែលរំលោភសិទ្ធិរបស់បុគ្គល ដូចជា សិទ្ធិមានជីវិត និងបូរណភាពខាងរូបរាងកាយនិងស្មារតីចិត្តគំនិត ដែលការរំលោភទាំងនេះកើតឡើងនៅក្នុងវង្វង់សមត្ថកិច្ចដែនដី ។ រីឯដំណោះស្រាយកែតម្រូវគឺអាចជាសំណងរដ្ឋប្បវេណីឬសំណងព្រហ្មទណ្ឌ ។ ដំណោះស្រាយកែតម្រូវទាំងពីរយ៉ាងនេះមានមុខងារផ្សេងគ្នា ។ នៅក្នុងច្បាប់ព្រហ្មទណ្ឌ ចារីនៃបទល្មើសត្រូវបានដាក់ទណ្ឌកម្មចំពោះទង្វើរបស់ខ្លួនប្រឆាំងនឹងសង្គមជាតិ ។ ចំណែកឯសំណងរដ្ឋប្បវេណីគឺធ្វើឡើងដើម្បីសងជាជំងឺចិត្តដល់ជនរងគ្រោះ ។ ដំណោះស្រាយកែតម្រូវទាំងពីរយ៉ាងនេះគឺមានបំណងធ្វើឲ្យរាងចាលមិនឲ្យប្រព្រឹត្តអំពើនេះទៀត ទោះបីជាក្នុងរូបភាពខុសប្លែកគ្នាជាក់ស្តែងក៏ដោយ ។

អ្នកធ្វើអត្ថាធិប្បាយនានាបានឃើញករណីយកិច្ចក្នុងការប្តឹងផ្តល់ប្រឆាំងនឹងការរំលោភរបស់របបមុនៗ ក្រោមច្បាប់អន្តរជាតិនៅកន្លែងជាច្រើន មានដូចជាៈ សន្ធិសញ្ញានីតិព្រហ្មទណ្ឌ បញ្ញត្តិនានាដែលចែងអំពីការ «ធានានិងគោរព» សន្ធិសញ្ញា និង «បញ្ញត្តិស្តីអំពីសិទ្ធិទទួលដំណោះស្រាយកែតម្រូវ» ។ ច្បាប់ទម្លាប់អន្តរជាតិក៏ប្រហែលជាដាក់កាតព្វកិច្ចដល់រដ្ឋនានាក្នុងការប្តឹងផ្តល់ប្រឆាំងនឹងការរំលោភបែបនេះដែរ ។

### **ក) សន្ធិសញ្ញានីតិព្រហ្មទណ្ឌ**

សន្ធិសញ្ញានីតិព្រហ្មទណ្ឌគឺជាសន្ធិសញ្ញាដែលដាក់វិធានការនានា ដែលតម្រូវឲ្យរដ្ឋត្រូវតែទទួលយក ប្រឆាំងនឹងបុគ្គលឬភ្នាក់ងារទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសផ្ទុយទៅនឹងច្បាប់អន្តរជាតិ ។ ក្នុងករណីនេះ លិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិជាច្រើន រួមទាំងគោលការណ៍ *aut dedere aut judicare* ដែលមានន័យថា បត្យាប័ន ឬ ការប្តឹងផ្តល់ ។ ឧទាហរណ៍ៈ មាត្រា៤នៃអនុសញ្ញាអំពើប្រល័យពូជសាសន៍តម្រូវឲ្យមានការដាក់ទណ្ឌកម្មដល់អ្នកដែលប្រព្រឹត្តល្មើសនឹងអនុសញ្ញានេះ ។ មិនតែប៉ុណ្ណោះ អនុសញ្ញាស្តីអំពីការប្រឆាំងនឹង

ទារុណកម្ម តម្រូវថា រដ្ឋត្រូវតែផ្តន្ទាទោសដល់ការប្រព្រឹត្តទារុណកម្ម (តាមមាត្រា៤) អនុវត្តយុត្តាធិការទៅលើបទល្មើសទាំងឡាយណាដែលកើតឡើងនៅលើទឹកដីរបស់ខ្លួន (មាត្រា៥) និងធ្វើបត្យាប័នជនល្មើស ឬកាត់ទោសជនល្មើសនៅក្នុងស្រុកតែម្តង (មាត្រា៧) ។ សន្ទុះមួយនៅពីក្រោយអនុសញ្ញាប្រឆាំងនឹងទារុណកម្ម គឺចេតនាចង់អនុវត្តឲ្យមានប្រសិទ្ធភាពនូវបម្រាមទាំងឡាយប្រឆាំងនឹងទារុណកម្មដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។ អនុសញ្ញាប្រឆាំងនឹងទារុណកម្មក៏បានបញ្ចូលនូវនីតិវិធីអំពីសិទ្ធិជ្រើសរើសពិសេស ដែលផ្តល់អំណាចដល់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម ដើម្បីឲ្យពិចារណាទៅលើបណ្តឹងអំពីការធ្វើទារុណកម្មដែលប្តឹងផ្តល់មកលើរដ្ឋនានាដែលបានផ្សព្វផ្សាយនូវសេចក្តីថ្លែងការស្តីពីសិទ្ធិជ្រើសរើសពិសេសនានានៅក្នុងមាត្រា២២ ។ មិនតែប៉ុណ្ណោះ គណៈកម្មាធិការនេះអាចផ្តួចផ្តើមនូវការស៊ើបអង្កេតរបស់ខ្លួនផ្ទាល់ ប្រសិនបើខ្លួនដឹងថាទារុណកម្មកំពុងតែត្រូវបានអនុវត្តជាប្រព័ន្ធនៅក្នុងរដ្ឋណាមួយដែលជាភាគីនៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ។ ចំណុចចុងក្រោយគឺ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការមិនអនុវត្តនូវច្បាប់អាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក៏ចងរដ្ឋជាភាគីនៃអនុសញ្ញានេះឲ្យកាត់ទោសអ្នកប្រព្រឹត្តបទល្មើសឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

ការចោទប្រកាន់នានារបស់តុលាការនៅនូរិមប៊ឺកនិងតូក្យូបានបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមច្បាប់អន្តរជាតិ ហើយអាចគាំទ្រដល់ករណីយកិច្ចរបស់រដ្ឋក្នុងការប្តឹងប្រឆាំងនឹងចារីដែលបានប្រព្រឹត្តបទល្មើសទៀតផង ។ យោងតាមមាត្រា ៦(គ) នៃកតិកាសញ្ញាតុលាការយោធាអន្តរជាតិ ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរួមមាន "មនុស្សឃាត ការសម្លាប់រង្គាល ការដាក់ជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងជនស៊ីវិលមុនឬក្នុងពេលមានសង្គ្រាម ឬការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ ជាតិសាសន៍ ឬសាសនា ក្នុងការអនុវត្តឬពាក់ព័ន្ធនឹងបទល្មើសនៅក្នុងដែនសមត្ថកិច្ចរបស់តុលាការនេះ ទោះបីអំពើនោះរំលោភឬមិនរំលោភទៅលើច្បាប់ក្នុងស្រុកនៃប្រទេសដែលមានអំពើនោះកើតឡើងក៏ដោយ" ។ ការយកកតិកាសញ្ញានូរិមប៊ឺកស្តីពីតុលាការយោធាអន្តរជាតិមកអនុវត្តនៅក្នុងស្ថានភាពប្រទេសកម្ពុជាបច្ចុប្បន្នមានកម្រិត ពីព្រោះកតិកាសញ្ញានេះហាមប្រាមតែទង្វើណាដែលត្រូវបានប្រព្រឹត្តប្រឆាំងជនស៊ីវិលតែប៉ុណ្ណោះ នៅមុនឬក្នុងពេលមានសង្គ្រាម ។ ក៏ប៉ុន្តែ ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ដែលផ្តល់សមត្ថកិច្ចឲ្យមានការជំនុំជម្រះក្តីអំពីឧក្រិដ្ឋកម្មសង្គ្រាមនៅប្រទេសអាល្លឺម៉ង់ ដែលត្រូវបានកាន់កាប់ក្រោយពីមានការជំនុំជម្រះក្តីនៅនូរិមប៊ឺកនោះ បានលុបចោលនូវភាសាសម្ព័ន្ធសង្គ្រាម ហើយសម្គាល់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថាជា"អំពើឃោរឃៅនិងបទល្មើសទាំងឡាយ....ឬអំពើអមនុស្សធម៌ដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងជនស៊ីវិល" ។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តជាឯកច្ឆ័ន្ទ នូវលក្ខន្តិកៈនិងសាលក្រមរបស់តុលាការយោធាអន្តរជាតិនៅនូរិមប៊ឺក ដែលជាទូទៅហៅថា ច្បាប់នូរិមប៊ឺក ឬ គោលការណ៍នូរិមប៊ឺក ថាជាច្បាប់អន្តរជាតិដែលមិនអាចទុកជាមោឃៈបាន ។ រដ្ឋមិនអាចធ្វើព្រងើយកន្តើយចំពោះកាតព្វកិច្ចរបស់ខ្លួន ហើយការពារបុគ្គលឲ្យរួចពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬប្រាសចាកពីកាតព្វកិច្ចក្នុងការដាក់ឲ្យមានការទទួលខុសត្រូវចំពោះអំពើល្មើសឡើយ ។

នៅខែកុម្ភៈ ឆ្នាំ១៩៩៣ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបង្កើតនូវតុលាការឧក្រិដ្ឋកម្មសង្គ្រាមសម្រាប់អតីតយូហ្គោស្លាវី ដោយប្រើអំណាចដូចចែងក្នុងជំពូក VII និងចាត់ទុកការប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅបូស្នៀថាជាការគំរាមកំហែងដល់សន្តិភាព ។ ជាពិសេសទៅទៀតនោះ មាត្រា២នៃច្បាប់តុលាការនោះក៏ធានាក្នុងការផ្តល់ឲ្យតុលាការអន្តរជាតិនេះ នូវអំណាចក្នុងការកាត់ទោសបុគ្គលទាំងឡាយដែលប្រព្រឹត្ត ឬបញ្ជាឲ្យប្រព្រឹត្ត បទល្មើសធ្ងន់ធ្ងរទៅលើអនុសញ្ញា

ទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។ ក្នុងនាមជាឧបករណ៍ច្បាប់ តុលាការនេះមានអំណាចរបស់ក្រុមប្រឹក្សាសន្តិសុខ ក្នុងការចោទប្រកាន់បុគ្គលទាំងឡាយណាដែលប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរមកលើច្បាប់មនុស្សធម៌អន្តរជាតិ ដោយមិនគិតថាតើការរំលោភនោះកើតឡើងនៅពេលមានជម្លោះប្រដាប់អាវុធឬនៅក្នុងយុទ្ធនាការប្រឆាំងនឹងជនស៊ីវិលនោះឡើយ ។

**ខ) បញ្ញត្តិនានាដែលចែងពីការ “ធានានិងគោរព” សិទ្ធិសញ្ញា**

លិខិតុបករណ៍ផ្នែកសិទ្ធិមនុស្សជាច្រើនបង្ខំរដ្ឋមិនត្រឹមតែមិនឲ្យជ្រៀតជ្រែកទៅលើសេរីភាពបុគ្គលតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឲ្យគោរពសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយមួយចំនួនផង និងធានាឲ្យប្រាកដថាសិទ្ធិទាំងនេះត្រូវបានផ្តល់ឲ្យដល់បុគ្គលនានាដែលស្ថិតនៅវង្វង់សមត្ថកិច្ចរបស់ខ្លួន ។ អ្នកអត្ថាធិប្បាយជាច្រើនអះអាងថា បញ្ញត្តិទាំងនេះធ្វើឲ្យរដ្ឋមានកាតព្វកិច្ចការពារយ៉ាងហ្មត់ចត់ ឬដោះស្រាយកែតម្រូវចំពោះការរំលោភទៅលើសិទ្ធិដូចរៀបរាប់ខាងលើនេះ ។ នៅក្នុងករណីវ៉ាង វ៉េឡាសកេ រ៉ូឌ្រីហ្គេ ជាមួយនឹងប្រទេសហុងឌូរ៉ាស តុលាការអន្តរអាមេរិកាំងក៏បានប្រកាន់យកនូវជំហរប្រហាក់ប្រហែលនេះដែរ ។ នៅក្នុងរឿងក្តីនេះ យោធាហុងឌូរ៉ាសត្រូវបានចោទប្រកាន់ថាបានចាប់ចងធ្វើទារុណកម្ម និងសម្លាប់សកម្មជននិស្សិត ដែលជាការរំលោភទៅលើសេចក្តីថ្លែងការណ៍របស់អាមេរិកាំងស្តីពីសិទ្ធិនិងករណីយកិច្ចរបស់យុទ្ធជន ។ តុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំងបានសម្រេចថា “រដ្ឋនេះមានករណីយកិច្ចនីត្យានុកូលក្នុងការចាត់វិធានការទទួលខុសត្រូវទប់ស្កាត់នូវការរំលោភសិទ្ធិមនុស្ស និងប្រើប្រាស់គ្រប់មធ្យោបាយដែលខ្លួនមាន ក្នុងការស៊ើបអង្កេតទៅលើរាល់ការរំលោភទាំងឡាយដែលប្រព្រឹត្តនៅក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន ដើម្បីរកឲ្យឃើញនូវអ្នកដែលទទួលខុសត្រូវដាក់ទណ្ឌកម្មសមស្របទៅតាមទោសកំហុស និងធានាសងនូវការខូចខាតរបស់ជនរងគ្រោះឲ្យបានគ្រប់គ្រាន់” ។ តុលាការក៏បានបញ្ជាឲ្យរដ្ឋាភិបាលហុងឌូរ៉ាសសងនូវជំងឺចិត្តចំពោះគ្រួសាររបស់វ៉េឡាសកេ ក្នុងទឹកប្រាក់ចំនួន១សែន៥ម៉ឺនដុល្លា ។

**គ) បញ្ញត្តិស្តីពី“សិទ្ធិក្នុងការទទួលដំណោះស្រាយកែតម្រូវ”**

លិខិតុបករណ៍ជាលក្ខណៈពហុភាគី ដូចជា សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាអាមេរិកាំងស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្សនិងសេរីភាពចម្បង សុទ្ធតែទទួលស្គាល់នូវសិទ្ធិរបស់បុគ្គលក្នុងការរួចផុតពីការរំលោភសិទ្ធិមនុស្សដូចដែលមានចែងហើយស្រាប់ ។ បម្រាមនានានៅក្នុងសេចក្តីប្រកាសជាសាកល ត្រូវបានពង្រឹងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលបង្ខំឲ្យសមាជិកធ្វើតាមនិងគោរពសិទ្ធិមនុស្សដូចដែលបានចែងនៅក្នុងសេចក្តីប្រកាសជាសាកល ។ សន្ធិសញ្ញាសិទ្ធិមនុស្សនានាមានកម្រិតក្នុងការចែងពីចំណាត់ការជាវិជ្ជមានរបស់រដ្ឋ ។ រីឯសន្ធិសញ្ញាខ្លះទៀតបង្ហាញនូវ “សិទ្ធិក្នុងការទទួលដំណោះស្រាយកែតម្រូវ” ដល់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ។ ឧទាហរណ៍ៈ មាត្រា៨នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សបញ្ជាក់ថា “ជនគ្រប់រូបមានសិទ្ធិទទួលបាននូវដំណោះស្រាយកែតម្រូវពីសំណាក់តុលាការមានសមត្ថកិច្ចក្នុងស្រុក ចំពោះអំពើទាំងឡាយណាដែលរំលោភដល់សិទ្ធិជាមូលដ្ឋានដែលផ្តល់ឲ្យដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់” ។ មាត្រា២(៣)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ក៏ទទួលស្គាល់នូវសិទ្ធិទទួលដំណោះស្រាយកែតម្រូវនេះដែរ ។ **(នៅមានត)**

**អេលីហ្សាប៊ែត វ៉ាន់ស្គាក់**

**ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជីវភាពពេញទីខាងសំភារៈ ខាងស្មារតី និងខាងវប្បធម៌ ដែលត្រូវបានកែប្រែឱ្យរីកចំរើនកាន់តែខ្ពស់ឡើងជានិច្ច។ ប្រជាជនកម្ពុជាគ្រប់រូបសុទ្ធតែត្រូវបានធានាអះអាងខាងជីវភាពទាំងអស់។**

- **កម្មករគ្រប់រូបជាម្ចាស់រោងចក្រ។**
- **កសិករគ្រប់រូបជាម្ចាស់ស្រែចំការ។**
- **ពលករផ្សេងទៀតមានសិទ្ធិមានការងារធ្វើទាំងអស់។**

**ភាពគ្មានការងារធ្វើមិនមានជាដាច់ខាតក្នុងកម្ពុជាប្រជាធិបតេយ្យ។**

(មាត្រា១២ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ)

# បទសម្ភាសន៍ជាមួយ ព្រះភិក្ខុ យស ហ៊ុត ខេមចារោ



ព្រះភិក្ខុ យស ហ៊ុត ខេមចារោ

**ព្រះភិក្ខុ យស ហ៊ុតៈ** ចម្រើនពរ! រឿងតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនេះយើងបាននិយាយគ្នាច្រើនឆ្នាំហើយ នៅតែមិនទាន់បានសម្រេចយ៉ាងណានៅឡើយទេ ឲ្យជ្រះស្រឡះភ្លឺថ្លា អស់ចិត្តអស់ថ្លើមទាំងអស់គ្នា ឲ្យអស់កង្វល់ ឲ្យបញ្ចប់ការជជែកគ្នារឿងដដែលៗមិនចប់មិនហើយ ហើយឈានទៅរកការគិតខំប្រឹងប្រែងកសាងជីវិតកសាងសង្គមជាតិឲ្យបានល្អឡើងវិញ ។ សម្រាប់អាត្មាភាពយល់ថា ការណ៍នេះវាទាក់ទងនឹងសេចក្តីប្រាថ្នារបស់មនុស្ស ។ មនុស្សខ្មែរក៏ដូចជាមនុស្សទូទាំងសកលលោកដែរ **ចង់ដឹងការពិត**អំពីព្រឹត្តិការណ៍ដែលបានកើតឡើង ហើយដែលមានសាក្សីមានភស្តុតាងជាច្រើនរហូតដល់សព្វថ្ងៃនេះ ។ អ្នកដែលរងគ្រោះផ្ទាល់ ដែលធ្លាប់រស់នៅក្នុងរបបខ្មែរក្រហម ក៏បានក្រេបជញ្ជក់រសជាតិនៃការលំបាក បានឃើញនូវមហន្តរាយដល់អាយុជីវិត ដល់ទ្រព្យសម្បត្តិរបស់ខ្លួន របស់ជាតិ ។ ប៉ុន្តែចង់រកឲ្យឃើញតាមច្បាប់ហេតុផល ច្បាប់កម្មផលនោះឯង ថាតើហេតុអ្វីបានជាកើតឡើងដូច្នេះ ហើយតើអ្នកណាខ្លះដែលទទួលខុសត្រូវសំខាន់ៗ ។ ចង់ឲ្យមានការទទួលស្គាល់ ចង់ឲ្យមានការទទួលខុសត្រូវចំពោះអំពើនិងផលនៃអំពើដែលបានកើតឡើងនោះ ។ នេះជាការចង់ដឹងតាមហេតុផល ចង់ដឹងការពិតដើម្បីបានជាមេរៀនរបស់មនុស្សដែលរស់នៅសព្វថ្ងៃនេះ មនុស្សរស់ពីសម័យរងគ្រោះនោះផង មនុស្សជំនាន់ក្រោយផង ។ ហើយក៏ចង់បញ្ចប់ការជជែកគ្នាពីរឿងហ្នឹង នាំឲ្យខាតពេលវេលា នាំឲ្យមានការចោទប្រកាន់គ្នាមិនចេះចប់មិនចេះហើយ ដែលជាឧបសគ្គមិនឲ្យមានសាមគ្គីផ្សះផ្សាដ៏ពិតប្រាកដ ។ និយាយឲ្យខ្លីមកគឺចង់ដឹងការពិត ។ បើកាលណាដឹងការពិតហើយ ទើបអស់ចិត្ត ។

**សួរៈ** តើព្រះតេជគុណចង់ដឹងការពិតពីអ្នកណា?

**ព្រះភិក្ខុ យស ហ៊ុតៈ** ចង់ដឹងការពិតពីអ្នកដែលគេចោទប្រកាន់ អ្នកដែលជាមេដឹកនាំកំពូលៗ អ្នកដែលចូលរួមសម្រេច ចូលរួមដឹកនាំអង្គការសម័យរបបកម្ពុជាប្រជាធិបតេយ្យ ។ ចង់ឲ្យអ្នកទាំងនោះឆ្លើយចំពោះមុខតុលាការ ដើម្បីឆ្លើយនឹងការចោទប្រកាន់ ។ តាមច្បាប់ ដរាបណាមិនទាន់មានការកាត់សេចក្តីទេ មនុស្សម្នាក់នៅតែត្រូវចាត់ទុកថាជាមនុស្សឥតទោសនៅឡើយ ។ ច្បាប់ជាតិក៏ដោយ ច្បាប់អន្តរជាតិក៏ដោយ ។ គ្រាន់តែសង្ស័យ គ្រាន់តែចោទ ប៉ុន្តែបើមិនមានសេចក្តីសម្រេចទេ ក៏នៅតែមិនទាន់ចាត់ទុកថាជាមនុស្សមានទោសឬឥតទោសនៅឡើយ ។

នេះជាច្បាប់ ជាការគោរពនូវសិទ្ធិមនុស្ស ។ ដូច្នេះចាំបាច់ត្រូវទៅឆ្លើយចំពោះការចោទប្រកាន់ ។ ដំបូងឡើយគ្រាន់តែជាការសង្ស័យ ប៉ុន្តែសាមីខ្លួនត្រូវឆ្លើយ ។ បើមានផ្លូវដោះសាក៏ដោះសារទៅ ។ តុលាការនឹងសម្រេចតាមភស្តុតាងតាមសាក្សីទាំងអស់ ។ បើគេសម្រេចថាមានទោស ខ្លួនត្រូវសារភាព ទទួលខុសត្រូវ ហើយសុំទោសដល់ជាតិខ្មែរទាំងមូល ដល់គ្រួសារអ្នករងគ្រោះទាំងអស់ ហើយតាំងចិត្តនិងសន្យាថានឹងមិនប្រព្រឹត្តអំពើខុសនេះតទៅទៀតទេ ។ ហើយបើមានការលើកលែងទោសឬយ៉ាងណា ស្រេចតែលទ្ធផលដែលចេញមកពីការសម្រេចកាត់សេចក្តីនោះ ។

**សួរៈ** ក្នុងកាលៈទេសៈបច្ចុប្បន្នដែលមានមេដឹកនាំខ្មែរក្រហមមួយចំនួនដែលបានចុះចូលជាមួយរាជរដ្ឋាភិបាល ហើយមិនបានសារភាពកំហុស ប៉ុន្តែបានសុំការលើកលែងនិងអធ្យាស្រ័យទោស តើព្រះតេជគុណមានព្រះតម្រិះយ៉ាងណាដែរ?

**ព្រះភិក្ខុ យស ហ៊ុតៈ** ដើម្បីនឹងឲ្យអភ័យលើកលែងទោស លុះណាតែបានទទួលសារភាពថាបានធ្វើខុស បានប្រព្រឹត្តនូវអំពើឃោរឃៅអីទាំងអស់ហ្នឹង ។ បន្ទាប់ពីទទួលសារភាពហើយទើបអាចទទួលការលើកលែងទោសឬការអត់ឱនទោសឲ្យ ។ បើយើងនិយាយពីរឿងលើកលែងទោសដោយអត់មានការទទួលសារភាព វាអត់មានន័យអី ។

**សួរៈ** តើព្រះតេជគុណចង់បានតុលាការដែលមានបទដ្ឋានកម្រិតណា?

**ព្រះភិក្ខុ យស ហ៊ុតៈ** ដើម្បីរកយុត្តិធម៌ តុលាការហ្នឹងត្រូវតែជាតុលាការដែលមានសមត្ថភាព មានចំណេះច្បាស់លាស់ ជាតុលាការឯករាជ្យ មិនមានផលប្រយោជន៍ផ្ទាល់ខ្លួន ផលប្រយោជន៍បក្ខពួកទេ មិនមាននយោបាយទេ ហើយធ្វើទៅតាមច្បាប់ ។ មួយទៅតាមសីលធម៌របស់មនុស្ស សុចរិត ទៀងត្រង់ ប្រកបដោយធម៌ យុត្តិធម៌ មួយទៀតទៅតាមច្បាប់ តាមបទដ្ឋានដែលយកជាការបាន ។ ព្រោះរឿងបែបនេះមិនមែនមានតែនៅស្រុកខ្មែរទេ នៅប្រទេសដទៃនៅសម័យដទៃទៀតក៏មាន ។ តុលាការត្រូវតែបំពេញលក្ខខណ្ឌត្រឹមត្រូវយកជាការបានទើបអស់ចិត្តទាំងអស់គ្នា ។ ប្រជារាស្ត្រខ្មែរអ្នករងគ្រោះនិងអ្នកជំនាន់ក្រោយទទួលយកបាន ពីព្រោះយើងចង់បញ្ចប់ការជជែកគ្នាការចោទប្រកាន់គ្នា ហើយបានទៅជាមេរៀនសម្រាប់ជីវិតសម្រាប់ការគ្រប់គ្រងប្រទេស សម្រាប់កសាងសង្គមជាតិជាថ្មីឡើងវិញឲ្យបានសុខសប្បាយ ឲ្យមនុស្សប្រុងប្រយ័ត្នកុំយកគំរូតាមអ៊ីដែលអាក្រក់ទៀត ។

**សួរៈ** សូមព្រះតេជគុណប្រទានឱវាទថាតើពេលនេះទាំងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិគួរតែធ្វើដូចម្តេចខ្លះដើម្បីឲ្យតុលាការខ្មែរក្រហមអាចកើតចេញជារូបរាង ។

**ព្រះភិក្ខុ យស ហ៊ុតៈ** អ៊ីក៏ដោយ ដើម្បីអាចសម្រេចផលល្អបានទីមួយគឺត្រូវមានឆន្ទៈ ។ សុឆន្ទៈថាប្រាកដជាចង់រកការពិតនោះមែន អត់គិតលាយឡំអីទៀតទេ រកការពិតដើម្បីឲ្យបញ្ចប់រឿងខ្មែរក្រហម ។ បើមានឆន្ទៈគឺរកផ្លូវឃើញហើយ ប៉ុន្តែកុំយករឿងអ៊ីក្រៅមកគិត រឿងផ្ទាល់ខ្លួន រឿងបក្ខពួក រឿងអីទៀត ។ បើយកមកលាយឡំច្រើន ការបង្កើតតុលាការរកយុត្តិធម៌នឹងមិនងាយបានសម្រេចទេ ។ កុំគិតតែពីបុគ្គលខ្លួនឯង ។ គិតពីផលប្រយោជន៍ទាំងអស់គ្នា ផលប្រយោជន៍ជាតិ ព្រោះនេះមិនមែនជារឿងនយោបាយទេ ។ បើជាតុលាការនយោបាយវាមានរូបភាពម្យ៉ាងទៀត ។ តុលាការដែលរកយុត្តិធម៌មិនត្រូវឲ្យជាប់ជំពាក់រឿងផលប្រយោជន៍បុគ្គលឬផលប្រយោជន៍បក្សនេះបក្សនោះ បុគ្គលនេះបុគ្គលនោះទេ ។ លុះត្រាតែមានចិត្តលះបង់ដូច្នេះទើបនាំទៅរកការស្រុះស្រួលគ្នាបង្កើតតុលាការបានហើយរកយុត្តិធម៌រកការពិតឃើញ ។

**សួរៈ** តាមទឹកព្រះទ័យរបស់ព្រះតេជគុណផ្ទាល់ បើមេដឹកនាំខ្មែរក្រហមព្រមសារភាពថាខ្លួនគេធ្វើខុសហើយសុំអធ្យាស្រ័យ តើព្រះតេជគុណនឹងអត់ឱនឲ្យពួកគេទេ?

**ព្រះភិក្ខុ យស ហ៊ុតៈ** អាត្មាជាអ្នកប្រតិបត្តិសាសនា គឺព្រះពុទ្ធសាសនា អាត្មាធ្វើបានដោយឥតមានស្តាយស្រណោះអ៊ីទេ ។ បើពិចារណាតាមធម៌ អ្នកដែលធ្វើខុសពីព្រោះមានគំនិតខុស ។ ពីព្រោះមានមិច្ឆាទិដ្ឋិ មិច្ឆាសង្កប្ប មានគំនិតខុស មានការត្រិះរិះខុស យល់ឃើញខុស បានជានាំឲ្យធ្វើខុស ។ មានលោភៈ ទោសៈ

មោហៈ គ្របសង្កត់ឲ្យទៅជាវង្វេង ទៅជាឆ្កួត ។ ដូច្នេះយើងត្រូវអាណិតមនុស្សដែលធ្វើខុសនោះវិញទេ ហើយជួយរកមធ្យោបាយឲ្យយល់ត្រូវ ឲ្យលះបង់អំពើអាក្រក់អំពើខុស ។ ដូច្នេះនិយាយតាមផ្លូវធម៌ អត់មានគំនុំ អត់មានកំហឹង អត់មានចងពៀរទេ ។ សូម្បីមនុស្សដែលខឹងយើង ដែលតាំងខ្លួនជាសត្រូវនឹងយើង យើងអត់តាំងខ្លួនជាសត្រូវវិញទេ ។ ព្រះពុទ្ធសាសនាបង្រៀនថា ឲ្យយកឈ្នះលើអំពើអាក្រក់ដោយធ្វើអំពើល្អ យកឈ្នះលើកំហឹងដោយមិនខឹងតប ដោយសេចក្តីស្រលាញ់ ដោយក្តីករុណាអាណិតអាសូរ យកឈ្នះមនុស្សកំណាញ់ដោយការឲ្យ យកឈ្នះលើភូតភរកុហកដោយនិយាយតែការពិត នេះគឺឈ្នះមិនមានពៀរ ឈ្នះមិនត្រឡប់ចាញ់វិញ ។ គំនុំសងសឹកអត់ចប់ទេបើចេះតែដោះស្រាយទៅតាមការជាប់ជំពាក់ តណ្ហា ឧបាទាន លោភៈ ទោសៈ មោហៈ ។ ការដែលយើងយកអ្នកទោសទៅដាក់ពន្ធនាគារគឺដើម្បីចង់កែមនុស្ស ។ ដូច្នេះគុកដែលមានច្បាប់មានសីលធម៌ត្រឹមត្រូវ មិនមែនជាកន្លែងធ្វើទារុណកម្មលើរូបកាយទេ ។ គឺជាកន្លែងសម្រាប់អប់រំមនុស្សឲ្យល្អឡើងវិញ និងដើម្បីកុំឲ្យទៅប្រព្រឹត្តអំពើឧក្រិដ្ឋទៀត មិនមែនយកមនុស្សទៅទុកចោលឲ្យគ្រាន់តែនៅក្នុងគុកទេ ពីព្រោះបើមិនអប់រំ មិនកែមនុស្សឲ្យបានល្អ មិនឲ្យភ្ញាក់រឭកមានបញ្ញាយល់ដឹងឡើងវិញ ពេលចេញពីគុកវិញមនុស្សនោះទៅធ្វើអំពើអាក្រក់ដដែល ដោយកំហឹង ដោយការសងសឹក ។ របៀបមួយទៀតដែលគេធ្លាប់ដាក់ទោសមេដឹកនាំប្រព្រឹត្តខុស គឺនិរទេស ។ យើងមើលរឿងព្រះវេស្សន្តរ ព្រះវេស្សន្តរត្រូវប្រជារាស្ត្រនិរទេសឲ្យទៅរស់នៅក្នុងព្រៃ ដោយសារព្រះអង្គបានដាក់ទានដំរីសទៅឲ្យនគរផ្សេង គឺព្រះអង្គធ្វើផ្ទុយនឹងឆន្ទៈរបស់ប្រជារាស្ត្រ ប៉ុន្តែមួយរយៈក្រោយ ព្រះអង្គត្រូវគេយាងឲ្យត្រឡប់មកវិញ ។ ដូច្នេះការសងសឹកអត់មានចំណេញអីទេ ។ សំខាន់យើងចង់ដឹងការពិត ចង់ឲ្យមានការទទួលខុសត្រូវ ដើម្បីជាមេរៀនដល់អ្នកដទៃកុំធ្វើដូច្នោះទៀត ។

**ស្នួរ:** ប្រសិនបើតុលាការខ្មែរក្រហមកើតឡើង តើព្រះតេជគុណយល់ថាមានប្រយោជន៍យ៉ាងណាខ្លះដល់សង្គមខ្មែរ?

**ព្រះភិក្ខុ យស ហ៊ុតៈ** ប្រយោជន៍ដើម្បីការពិត ។ ពីព្រោះការពិតសំខាន់ណាស់ ។ ការពិតទៅតាមហេតុផល ។ ការពិតនោះហើយជាផលប្រយោជន៍ ។ គឺឲ្យអស់ចិត្ត ឲ្យមានការទទួលខុសត្រូវ កុំឲ្យមនុស្សបច្ចុប្បន្នធ្វើដូច្នេះទៀត ឯអ្នកជំនាន់ក្រោយក៏អីចឹងដែរ ។ ធ្វើមិនត្រឹមត្រូវមិនបានផលល្អទេ ទោះបីមានបំណងល្អយ៉ាងណាក៏ដោយ ប៉ុន្តែបើប្រើមធ្យោបាយខុស មធ្យោបាយហិង្សានឹងនាំឲ្យវិនាសអន្តរាយ ។ ខ្មែរក្រហមក៏បាននិយាយដែរថាគេធ្វើដូច្នេះព្រោះតែស្រលាញ់ជាតិ ដើម្បីការពារផលប្រយោជន៍ប្រជាជន ប៉ុន្តែខ្មែរក្រហមប្រើមធ្យោបាយខុស ។ បើស្រលាញ់ម្តេចក៏ធ្វើបាបប្រជាជន ម្តេចក៏សម្លាប់ប្រជាជន? ស្រលាញ់ជាតិហេតុអីក៏សម្លាប់ជាតិ ធ្វើឲ្យជាតិវិនាសអន្តរាយ ទាំងជីវិតមនុស្ស ទាំងវប្បធម៌ ទាំងសីលធម៌ ប្រពៃណី ។ យើងប្រើមធ្យោបាយខុស មធ្យោបាយអាក្រក់ វាមិននាំឲ្យបានលទ្ធផលល្អទេ កម្ម-ផលគឺដូច្នេះ ។ អាត្មាអាចនិយាយថា ពួកអ្នកប្រព្រឹត្តអំពើឧក្រិដ្ឋកម្មទាំងអស់នោះជាបុគ្គលដែលមានអស្មិមានះដល់កំពូល មានលោភៈ ទោសៈ មោហៈ លើកកម្ពស់ខ្លួនឯងថាជាមនុស្សល្អផុតលេខ ។ នេះជាការយល់ឃើញខុស ជាមិច្ឆាទិដ្ឋិ ទុកគេដទៃទៀតជារបស់ឥតមានតម្លៃ ខ្លួនចង់ធ្វើអ្វីក៏បាន ។ នេះជាការយល់ច្រឡំ យល់ខុស អវិជ្ជា វង្វេង វិបល្លាសខាងផ្លូវចិត្ត ។

ប្រយោជន៍មួយទៀតគឺនាំទៅរកការផ្សះផ្សា ។ មនុស្សអស់ចិត្ត ឈប់គិតច្រើន ឈប់ចោទប្រកាន់គ្នា ព្រោះរកមុខអ្នកទទួលខុសត្រូវឃើញហើយ ។ ទើបឈានទៅរកការផ្សះផ្សាសាមគ្គី សន្តិភាពពិតប្រាកដជាប់លាប់យូរអង្វែង ស្រលាញ់រាប់អានគ្នា អាណិតអាសូរគ្នា ហើយកសាងសង្គមជាតិឲ្យបានសុខសប្បាយទាំងអស់គ្នាឡើងវិញ ។

ម្យ៉ាងទៀតគឺដើម្បីបញ្ចប់និទណ្ឌភាព គឺភាពឥតទោស ភាពមិនដាក់ទោស ភាពមិនទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលនៅមានជាទូទៅក្នុងសង្គមយើង ។

**ស្នួរ:** តាមទស្សនៈកម្ម-ផលរបស់ព្រះពុទ្ធសាសនាគឺ “អ្នកណាធ្វើល្អបានល្អ អ្នកណាធ្វើអាក្រក់បានអាក្រក់” ។ មេដឹកនាំខ្មែរក្រហម

បានធ្វើអាក្រក់អីចឹង ប្រសិនបើតុលាការបានកាត់ទោសគាត់ ដោយយុត្តិធម៌ហើយ តើពេលដែលស្លាប់ទៅគាត់ទៅសោយទុក្ខវេទនាដែរឬទេ ហើយបើគាត់មិនបានទទួលការកាត់ទោសទេ តើគាត់ស្លាប់ទៅសោយក្តីទុក្ខមែនឬអត់?

**ព្រះភិក្ខុ យស ហ៊ុតៈ** សូមជ្រាបថា កម្ម-ផលជាច្បាប់ហេតុផល ជាច្បាប់ធម្មជាតិ ។ ច្បាប់នេះមាននៅក្នុងធម្មជាតិជាសកល មិនមែនតែស្រុកខ្មែរទេ មិនមែនតែសម្រាប់អ្នកកាន់ព្រះពុទ្ធសាសនាទេ ។ ច្បាប់កម្ម-ផលជាច្បាប់ធម្មជាតិ ជាច្បាប់សង្សារវដ្តទាំងមូល ។ មានតែព្រះនិព្វានទេដែលលែងមានកម្ម-ផល ផុតពីហេតុនិងផល ផុតពីកើតស្លាប់ ផុតពីសុខទុក្ខ ។ អ្វីៗទាំងអស់ក្នុងលោកនេះប្រព្រឹត្តទៅតាមច្បាប់ហេតុផល ទាំងល្អ ទាំងអាក្រក់ ។ ហើយមិនមែនព្រះសម្មាសម្ពុទ្ធជាអ្នកបង្កើតច្បាប់កម្ម-ផលទេ ព្រះអង្គគ្រាន់តែបានរកឃើញ បានត្រាស់ដឹង ។ ខ្មែរក្រហមបានធ្វើអំពើអ្វីខ្លះ? ហើយគាត់បានផលមកជាអ្វីខ្លះ? ផលសម្រាប់ខ្លួនគាត់? ផលសម្រាប់ជាតិខ្មែរ? ខ្លួនគាត់ផ្ទាល់ក៏មិនដែលបានសុខដែរ មនុស្សខឹង មនុស្សកាច មនុស្សប្រើហិង្សារមែងមានទុក្ខជានិច្ច គ្មានសេចក្តីសុខទេ ។ មនុស្សដែលខឹងគេ មនុស្សដែលបៀតបៀនគេ មនុស្សដែលប្រើអំពើហិង្សា ជាមនុស្សមានទុក្ខ មិនសប្បាយចិត្តត្រជាក់ចិត្តទេ មិនមានមង្គលសេរីសួស្តីទេ ។ ដូច្នេះមិនមែនតែពេលបច្ចុប្បន្នទេ សូម្បីពេលដែលគាត់កំពុងតែធ្វើអំពើហ្នឹងក៏ដោយ គាត់ធ្វើដោយខឹង គាត់ធ្វើដោយស្អប់ គាត់ធ្វើដោយគំនុំ ។ ទស្សនាវដ្តីស្វែងរកការពិតក៏បានចុះផ្សាយពាក្យស្លោកដែលគាត់បង្រៀនកូនចៅខ្មែរថាឲ្យចងកំហឹង ។ ដូច្នេះចេតនាអាក្រក់ បំណងអាក្រក់ បៀតបៀនគេ ទាំងអស់នេះនាំឲ្យខ្លួនមានទុក្ខស្រេចទៅហើយ ។ ជីវិតរបស់គាត់មិនដែលបានសុខទេ គាត់រស់នៅក្នុងក្តីភិតភ័យ ពីព្រោះគាត់ដឹងថាមានសត្រូវចង់សម្លាប់គាត់វិញដែរ ដេកមិនលក់បក់មិនល្ហើយគ្រប់ពេលវេលា ដើរទៅកន្លែងណាមួយមានអ្នកការពារច្រើនណាស់ គាត់ផ្លាស់ទីកន្លែងនិងលួចស្ងៀតដើម្បីការពារខ្លួនគាត់ ។ ត្រូវគេស្អប់ ត្រូវគេខឹង ត្រូវគេប្រទេចផ្តាសា បរិហារ នេះជាផលនៃអំពើរបស់គាត់ហើយ ។ មានអ្នកកាសែតសួរអាត្មាថា គេឃើញមេខ្មែរក្រហមរស់នៅសុខហើយសម្បូណ៌សប្បាយផង ។ អាត្មាយល់ថាដូចជាអត់សប្បាយទេ ខាងផ្លូវចិត្តគិតច្រើនណាស់ មានកង្វល់ មានវិប្បដិសារីចំពោះអំពើដែលធ្វើហើយដែលត្រូវគេបរិហារ ត្រូវគេស្អប់ខ្ពើម ។ នេះជាទណ្ឌកម្មមួយធំណាស់តាមផ្លូវចិត្ត ជានរកហើយហ្នឹង នរកបច្ចុប្បន្នជាក់ស្តែង កុំគិតរឿងនរកជាតិក្រោយឯណាទៀត នរកសួគ៌មាននៅក្នុងចិត្តយើងបច្ចុប្បន្ននេះឯង ។ កាលណាចិត្តយើងមានសន្តិភាព ពេញចិត្តសប្បាយចិត្ត ហ្នឹងចាត់ទុកជាឋានសួគ៌ហើយ ។ ហើយបើមានទុក្ខក្តៅក្រហាយ វិប្បដិសារី ទោមនស្សក្នុងចិត្ត ហ្នឹងហើយជានរក ។ យើងមិនគួរទៅរវល់តែនរកសួគ៌នៅជាតិក្រោយទេ យើងគួររវល់នរកសួគ៌ជាក់ស្តែងដែលយើងពិសោធន៍រាល់ថ្ងៃនេះ ។ អ្នកដែលធ្វើអាក្រក់មាននរកជាក់ស្តែង អត់មានក្តីសុខទេ អត់សប្បាយទេ ទោះនៅក្នុងភូមិគ្រឹះនៅក្នុងប្រាសាទក៏ដោយ ក៏អត់មានសប្បាយទេ ។ នេះផលវិបាកចំពោះខ្លួនឯង ។ ចំណែករឿងទុក្ខវិនាសអន្តរាយរបស់ប្រជារាស្ត្រខ្មែរ យើងថាតើជាផលនៃកម្មរបស់រាស្ត្រខ្មែរឬយ៉ាងម៉េច? រឿងនេះវែងឆ្ងាយណាស់ ។ យើងកើតមកជាមនុស្សគឺមិនទៀង ។ ជីវិតមនុស្សមាន កើត ចាស់ ឈឺ ស្លាប់ មានសុខ មានទុក្ខ ទោមនស្ស សោមនស្ស មានជួបហើយបែកគ្នា មានប្រាថ្នាយ៉ាងណាហើយមិនបានដូចប្រាថ្នា ។ ធម៌នេះមានប្រចាំលោកទាំងមូល នរណាក៏មិនអាចគេចផុតដែរ ស្លាប់ដោយឈឺ ស្លាប់ដោយហេតុនេះហេតុនោះ ស្លាប់ដោយគ្រោះថ្នាក់ ស្លាប់ដោយសង្គ្រាម ពីព្រោះអ្វីៗទាំងអស់មិនទៀង ។ អាត្មានិយាយដើម្បីបន្ធូរទុក្ខខ្មែរផងថា មិនមែនមានតែស្រុកខ្មែរទេសង្គ្រាមនោះ ។ វិនាសកម្មដូចនេះក៏ធ្លាប់មានរួចហើយ សង្គ្រាមលោកលើកទី១ ទី២ នៅអឺរ៉ុប ។ សង្គ្រាមនៅប្រទេសដទៃទៀតក៏សម្លាប់មនុស្សអស់រាប់ម៉ឺនរាប់សែនរាប់លាននាក់ សម័យបុរាណក៏មាន សម័យថ្មីក៏មាន ។ អ្វីៗទាំងអស់ក្នុងលោកនេះមិនទៀង បើមិនចង់ជួបប្រទះសោកនាដកម្ម សេចក្តីទុក្ខវិនាសអន្តរាយ លុះត្រាតែខំកសាងឲ្យបានសម្រេចមគ្គផលព្រះនិព្វានទៅ ។ មនុស្សកើតមកព្រោះមានកម្ម បើអត់មានកម្ម-ផលអត់កើតមកទេ ហើយបើកាលណាមានកម្ម-ផល មាន

កើតមានស្លាប់អ៊ីចឹង ។ មនុស្សទាំងអស់កើតមកក្នុងឋានៈជាពលរដ្ឋ បានចូលរួមក្នុងកិច្ចការសង្គមកិច្ចការប្រទេសជាតិ ។ បានសុខ បានទុក្ខយ៉ាងម៉េច ខ្លួនឯងហ្នឹងក៏បានរួមចំណែកក្នុងការណ៍ហ្នឹង ដោយចេតនាក្តី ដោយអចេតនាក្តី ដោយផ្ទាល់ក្តី ដោយប្រយោលក្តី ដោយយល់ត្រូវក្តី ដោយយល់ខុសក្តី ខ្លួនយើងរួមចំណែកក្នុងសេចក្តីសុខឬសេចក្តីទុក្ខរបស់ប្រទេស ។ បើប្រទេសហ្នឹងបានទុក្ខ បានវិនាសអន្តរាយ ខ្លួនយើងទុក្ខជាមួយដែរ ។ ដូច្នេះយើងមានការទទួលខុសត្រូវរួមគ្នា ។ មួយការទទួលខុសត្រូវផ្ទាល់ខ្លួនយើង មួយទៀតការទទួលខុសត្រូវរួមក្នុងឋានៈជាពលរដ្ឋ ។ ដូច្នេះកុំថាតែអ្នកដទៃខុស អញត្រូវទាំងអស់ ពិបាកថាណាស់ ព្រោះយើងបានចូលរួមតាមរបៀបណាមួយ ចូលរួមជាមួយអ្នកនយោបាយ បក្សនេះ បក្សនោះ សេរីក៏ដោយ កុម្មុយនិស្តក៏ដោយ របបនេះ របបនោះ ។ សូម្បីខ្មែរក្រហមហ្នឹងក៏មានអ្នកចូលរួមគាំទ្រមិនតិច ។ នេះមកពីយើងមានការយល់ខុស ឬមកពីការធ្វេសប្រហែសជ្រុលខ្លួនឲ្យបុគ្គលមួយក្រុមដែលជាមនុស្សកាចឃោរឃៅបានឡើងកាន់អំណាច បានគ្រប់គ្រងបំផ្លិចបំផ្លាញដល់កម្រិតហ្នឹង ។ នេះជាការដាស់សតិយើងឲ្យប្រយ័ត្ន កុំបណ្តោយឲ្យបុគ្គលឬក្រុមណាធ្វើអីតាមអំពើចិត្ត ។ កុំចេះតែគាំទ្រទាំងងងឹតងងល់ ។ កុំចេះតែជឿងាយៗ កុំចាញ់បោកគេ នាំឲ្យរងគ្រោះដល់ខ្លួនឯងហើយដល់ជាតិទាំងមូលទៀត ។ រឿងកម្មផលនេះយើងដឹងមិនអស់ទេ ។ យើងសាងកម្មពីជាតិមុនក្តី ជាតិនេះក្តី វាបូកផ្សំគ្នាទាំងអស់ ។ កម្មផ្ទាល់ខ្លួនផង រួមបូកជាមួយគ្នាក្នុងឋានៈជាសមាជិកនៃជាតិមួយផង ហើយវាឲ្យផលបូករួមមក ។ ដូច្នេះម្នាក់ៗត្រូវពិចារណាឲ្យយល់ច្បាស់តាមហេតុផលទៅ កុំគិតតែទម្លាក់កំហុសលើអ្នកដទៃ មិនទទួលខុសត្រូវ ហើយកុំឲ្យភ្លាត់ស្នៀតទៅចាញ់បោកគេទៀត ។

**សួរៈ** បើដូចព្រះតេជគុណមានពុទ្ធដីកាថា រឿងខ្មែររងគ្រោះក្រោមរបបខ្មែរក្រហមជារឿងមិនទៀង ។ បើដូច្នេះតើមនុស្សម្នាក់ៗចាំបាច់ធ្វើអំពើល្អធ្វើអី បើលោកនេះមិនទៀង យើងមិនដឹងថារឿងអាក្រក់នឹងកើតឡើងនៅពេលណាទៀត?

**ព្រះភិក្ខុ យស ហ៊ុតៈ** ចំរើនពរ! អីចេះ ធ្វើល្អបានសុខគួរសមល្មមទ្រាំទ្របាន សុខជាបណ្តើរៗ មិនអាចបានសុខជាសុក្រឹតទេនៅក្នុងលោកនេះគ្មានទេ ។ ចង់បានសុខដែលគ្មានលាយឡំដោយទុក្ខ សុខឥតប្រែប្រួលគឺព្រះនិព្វាន ។ គឺមនុស្សអស់លោភៈ ទោសៈ មោហៈ អស់ប្រាថ្នាជាតិកំណើតទៀត ។ បើប្រាថ្នាជាតិកំណើតបានសេចក្តីថាប្រាថ្នាកើតស្លាប់ ។ ការចាស់ ជរា ឈឺ ស្លាប់ ជាផលនៃការកើត ។ បើចង់កើតហើយ ចង់ឲ្យមានជីវិតហើយកុំឲ្យជួបនឹងធម៌អនិច្ចំ ទុក្ខំ អនត្តា មិនមានទេ ។ អ្វីទាំងអស់ក្នុងលោកនេះនៅក្រោមច្បាប់អនិច្ចំ ទុក្ខំ អនត្តា ទាំងអស់ ។ ក្នុងលោកទាំងមូលនេះ ទេវតាឥន្ទ្រព្រហ្មក៏ដោយ មនុស្សសត្វក៏ដោយ របស់ឥតវិញ្ញាណក៏ដោយ គឺអនិច្ចំទាំងអស់ ។ នេះជាច្បាប់ធម្មជាតិដែលអ្នកវិទ្យាសាស្ត្រក៏ទទួលស្គាល់ ទោះបីជាមិនអាចយល់ដល់កម្រិតជ្រៅបំផុតក៏ដោយ ។ គ្មានអ្វីនៅនឹងដែលទេក្នុងលោកនេះ គឺប្រែប្រួលទាំងអស់ គ្រប់ពេលវេលា គ្រប់ខណៈ ។ បើអ្នកចង់ឲ្យរួចពីធម៌មិនទៀង មានតែខំប្រឹងប្រតិបត្តិដើម្បីឲ្យរួចផុតពីច្បាប់ហេតុផល គឺព្រះនិព្វានដែលហៅថាបរមសុខលែងប្រែប្រួល ។ ការដែលយើងធ្វើអំពើល្អដោយកាយ វាចា ចិត្តដែលយើងហៅថាបុញ្ញកម្ម កុសលកម្ម អំពើល្អដោយការធ្វើទានដោយការរក្សាសីល ដោយការចម្រើនភាវនា ដោយមានមេត្តាករុណា ព្រហ្មវិហារធម៌ វានាំឲ្យជីវិតយើងបានសុខបន្តូរ ហើយយើងខំប្រឹងប្រតិបត្តិតទៅទៀតដើម្បីរំដោះខ្លួនឲ្យរួចពីសេចក្តីទុក្ខគ្រប់យ៉ាង សុខជាបន្តូរទេ មិនមានសេចក្តីសុខជាសុក្រឹត សន្តិភាពជាសុក្រឹត នៅក្នុងលោកដែលនៅមានកិលេសគឺលោភៈ ទោសៈ មោហៈ នេះទេ ។ ប្រទេសណាក៏ដូចគ្នា សុខ ទុក្ខ សន្តិភាព សង្គ្រាម ចម្រើន វិនាស មានជានិច្ច ។ គ្មានប្រទេសណាមួយនៅទៀងតែសុខចម្រើនទេ ។ អ្វីៗទាំងអស់មានច្បាប់ធម្មជាតិមួយគ្រប់គ្រង គឺថាបើកើតឡើងហើយត្រូវតែរលត់ទៅវិញ ។

**សួរៈ** បច្ចុប្បន្ននេះគឺជាពេលវេលាដែលយើងកំពុងជំរុញឲ្យមានការផ្សះផ្សាជាតិឡើងវិញ ។ ដោយសារប្រជាជនខ្មែរភាគច្រើនគោរពព្រះពុទ្ធសាសនា ដូច្នេះតើព្រះពុទ្ធសាសនាអាចចូលរួមចំណែកអ្វីខ្លះដល់ការផ្សះផ្សាសង្គមជាតិខ្មែរ?

**ព្រះភិក្ខុ យស ហ៊ុតៈ** គឺទេសនាឲ្យមនុស្សស្ដាប់ ឲ្យមនុស្សទទួលស្គាល់ការពិត កុំគិតតែទម្លាក់កំហុសលើអ្នកដទៃ ចេះទទួលខុសត្រូវចំពោះសុខទុក្ខរបស់ប្រទេសជាតិ ។ ឲ្យមនុស្សចេះអត់ឱន ។ មនុស្សច្រើនណាស់នៅតែគិតថាខ្លួនឯងត្រូវទាំងអស់ ហើយអ្នកដទៃខុសទាំងអស់ ប៉ុន្តែកុំភ្លេចថា អ្នកដែលធ្វើខុសខ្លាំងបានមកពីមានអ្នកគាំទ្រ ។ ព្រះពុទ្ធសាសនាបង្រៀនឲ្យមើលឃើញការពិតតាមពិត ។ រឿងដែលកន្លងទៅហើយមិនអាចត្រឡប់ទៅកែបានទេ វាផុតហួសទៅហើយ វាបានត្រឹមតែជាមេរៀន ជាការពិសោធន៍សម្រាប់ការងាររបស់យើងបច្ចុប្បន្ននេះ សំខាន់គឺបច្ចុប្បន្នដែលកំពុងតែធ្វើនេះ ។ អ្វីដែលកន្លងទៅហើយសូម្បីតែមួយខណៈក៏ដោយ យើងមិនអាចទៅអន្តរាគមន៍កែអំពើនោះឲ្យល្អវិញបានឡើយ មានតែធ្វើអំពើថ្មីឲ្យបានល្អ ដោយទាញយកមេរៀនពីអំពើមុនៗនោះ ។ ដូច្នេះព្រះពុទ្ធសាសនាថាមិនបាច់កើតទុក្ខទោមនស្សសោកសង្រេងចំពោះរឿងដែលកន្លងទៅហើយទេ ត្រូវតាំងចិត្តថាពីពេលនេះតទៅមិនធ្វើអំពើអាក្រក់អំពើហិង្សាទៀតទេ ព្រោះវានាំឲ្យទុក្ខ នាំឲ្យអន្តរាយដល់ខ្លួនផង ដល់អ្នកដទៃផង ។ មេរៀនពីមុនមក អ្វីដែលធ្វើទៅហើយបានផលល្អ បានសុខ នឹងខំធ្វើនិងពង្រីកអំពើបែបនោះតទៅទៀត ហើយអ្វីដែលឲ្យផលវិបាកអាក្រក់ នឹងចៀសវាងឈប់ធ្វើតទៅទៀត ។ ព្រះពុទ្ធសាសនាបង្រៀនដូច្នេះឯង ។

**សួរៈ** បន្ទាប់ពីមានតុលាការខ្មែរក្រហម តើយើងនឹងធ្វើអ្វីទៀតជាមួយនឹងប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម?

**ព្រះភិក្ខុ យស ហ៊ុតៈ** បន្ទាប់ពីរកការពិតហើយ គឺមានអ្នកសរសេរប្រវត្តិសាស្ត្រ ។ សរសេរប្រវត្តិសាស្ត្រសម្រាប់ឲ្យខ្មែរដែលរស់នៅនេះរៀន ឲ្យក្មេងជំនាន់ក្រោយរៀនតទៅទៀត ។ បានជាមេរៀនរបស់មនុស្សជាតិ ។ បន្ទាប់មកបានជាចំណេះបញ្ញាសម្រាប់ឲ្យមនុស្សយើងកុំប្រមាទ គឺកុំឲ្យមានការធ្វេសប្រហែស បើធ្វេសប្រហែសអាចមានរឿងដូច្នេះទៀត ។

**សួរៈ** តាមព្រះពុទ្ធសាសនា តើ «កម្ម-ផល» មានន័យដូចម្ដេច?

**ព្រះភិក្ខុ យស ហ៊ុតៈ** «កម្ម-ផល» គឺអំពើនិងលទ្ធផលនៃអំពើ ។ «កម្ម» ប្រែថាអំពើដែលធ្វើឡើងដោយចេតនា ហើយវាឲ្យផលភ្លាមក៏មាន ឲ្យយូរបន្តិចក៏មាន ឲ្យទៅជាតិក្រោយក៏មាន ។ អ្វីដែលយើងធ្វើទាំងអស់ ដោយចេតនា ដោយដឹងខ្លួន វាជាប់ទុកទាំងអស់ក្នុងព្រលឹងវិញ្ញាណរបស់យើង ។ អំពើដោយកាយ ដោយវាចា ដោយចិត្ត (កាយកម្ម វចីកម្ម មនោកម្ម) ។ ទាំងខាងអាក្រក់ក៏ជាប់ ទាំងខាងល្អក៏ជាប់ ។ នេះជាមរតក ជាកេរ ជាសម្បត្តិរបស់យើងពិតប្រាកដមែន ព្រោះវាជាប់តាមយើងហើយវានឹងឲ្យផល ។ ជាសុខ ជាទុក្ខ ឬយ៉ាងណាទៅតាមកម្មដែលបានកសាង ។ បើកម្មល្អវាឲ្យផលជាសុខ ជាចម្រើនមង្គលសិរីសួស្ដីក្នុងជីវិត ។ យើងអ្នកធ្វើកម្មអាចគ្រប់គ្រងវាបាននៅពេលដែលយើងកំពុងតែធ្វើ ។ អ្វីដែលធ្វើហើយវាហួសទៅហើយ យើងមិនអាចបញ្ជាថាកម្មត្រូវឲ្យផលពេលណាទេ វាមានស្វ័យភាពរបស់វា ។ វារកពេល រកឱកាស ដែលគួរនឹងបញ្ចេញផ្លែផ្កានោះ យើងអត់ដឹងទេ នេះវាហួសវិស័យនៃវិចារណញ្ញាណ ។ មិនមែនយើងអ្នកឲ្យផលទេ គឺកម្មហ្នឹងឯងវាបញ្ចេញជាផលដោយស្វ័យប្រវត្តិ ។ ជួនកាលអំពើល្អដែលយើងកំពុងតែធ្វើឬបានធ្វើថ្មីៗ មិនទាន់ឲ្យផលល្អទេ វាមានកម្មអាក្រក់ពីពេលណាមកនោះឆ្លៀតឲ្យផលពេលនេះទៅវិញ ។ ជួនកាលទៀតអំពើអាក្រក់ដែលយើងកំពុងតែធ្វើឬបានធ្វើរួចហើយ មិនទាន់ឲ្យផលអាក្រក់ភ្លាមទេ វាមានកម្មល្អពីពេលណាមួយនោះឆ្លៀតឲ្យផលមុន ។ ដូច្នេះយើងអត់ដឹងទេ, ប៉ុន្តែជាការពិសោធន៍ជាក់ស្ដែង អ្នកដែលរស់នៅក្នុងសីលធម៌ អ្នកដែលធ្វើអំពើល្អ ឃើញផលជាក់ស្ដែងខ្លួនឯង ។ មនុស្សភាគច្រើនយល់ពាក្យ «កម្ម-ផល» មិនត្រឹមត្រូវទេ គឺយល់ខុស ។ ចេះតែបកស្រាយថាជាព្រហ្មលិខិតដៅមកចារមក ។ ប៉ុន្តែតាមពិតកម្ម-ផលគឺ «ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់» «ចេះពីរៀន មានពីរក» ។ ចេះជាផល រៀនជាកម្ម រកជាកម្ម មានជាផល ។ ធ្វើស្រែជាកម្ម ហៅថាកសិកម្ម ដល់បានស្រូវមកជាផល ។ យើងជីកទឹកជាកម្ម ដល់បាត់ស្រេកទឹកជាផល ។ យើងស្រលាញ់រាប់អានអាណិតអាសូរគេ គេក៏ស្រលាញ់រាប់អានអាណិតអាសូរយើងវិញ ។ យើងស្អប់គេ គេស្អប់យើងវិញ ។ យើងជេរគេ គេជេរយើងវិញ ។ យើងវាយគេ គេវាយយើងវិញ ។ **(តទៅទំព័រ៩៨)**

# ភ្នាក់ងារផ្តាច់ព្រលឹង៖

## បរិយាយអំពីការប៉ះទង្គិចផ្លូវអារម្មណ៍តាមលក្ខណៈចិត្តសាស្ត្រសង្គម នៅក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា

**(តចប់)**

### *ការឲ្យហេតុផលតាមផ្លូវសីលធម៌*

ទាំងការធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស និងការប្រើពាក្យសម្រាលកុំឲ្យអាក្រក់ស្តាប់ពេក ធ្វើឲ្យអ្នកសម្លាប់មានភាពងាយស្រួលក្នុងការឲ្យហេតុផលតាមផ្លូវសីលធម៌ចំពោះទង្វើរបស់ខ្លួន ។ នៅក្នុងការពិសោធន៍ក្នុងគុកសិប្បនិម្មិតមួយនៅសាលា ស្តែនហ្វដ «អ្នកទោស» បានក្លាយជាមនុស្សមួយប្រភេទដែលទទួលដោយស្របច្បាប់នូវធម៌ក្តៅកាន់តែខ្លាំងថែមទៀត ។ ស្រដៀងគ្នានេះដែរ ដោយសារជនជាតិជ្វីហ្វត្រូវបានប្រៀបប្រដូចទៅនឹង «ជំងឺ» មួយប្រភេទដែលគំរាមកំហែងដល់សហគមន៍អាល្លឺម៉ង់ ណាហ្ស៊ីអាចចាត់ទុកការលុបបំបាត់ថាជាការចំបាច់បំផុតសម្រាប់សុខភាពសាធារណៈ ។ នៅក្នុងករណីនីមួយៗ ក្រុមមនុស្សដែលត្រូវសម្លាប់ចោល ត្រូវបានកត់សម្គាល់តាមផ្លូវមួយដែលបង្ហាញថាគំរូសីលធម៌លែងមានចំពោះអ្នកទាំងនោះទៀតហើយ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការផ្លាស់ប្តូរទម្រង់សីលធម៌សាជាថ្មីត្រូវបានជំរុញដោយធម្មានុរូបកម្មតាមថ្នាក់មូលដ្ឋាន នូវសីលធម៌ហិង្សានិងការលើកតម្កើងនូវហិង្សាជាទូទៅ ។ ដូចដែលបានជម្រាបខាងដើមហើយថា អ្នកដែលត្រូវសង្ស័យថាជា «ខ្មាំង» របស់អង្គការ គឺត្រូវដកភាពជាមនុស្សចេញ ហើយយកទៅសម្លាប់ចោលតែម្តង ។ កម្មាភិបាលខ្មែរក្រហមមិនត្រឹមតែត្រូវបានបង្រៀនឲ្យស្អប់មនុស្សប្រភេទនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឲ្យកម្ទេចចោលដោយគ្មានញញើតញញើម ឬមិនឲ្យអាណិតអាសូរទៀតផង ។ ចំពោះមនុស្សដូចជាសមមិត្ត ចេវ ការសម្លាប់ «ខ្មាំង» មានសារសំខាន់ទាំងខាងនយោបាយនិងខាងសីលធម៌ៈ «ប្រសិនបើសមមិត្ត ចេវ សម្លាប់មនុស្សបានច្រើននោះ គាត់ពេញចិត្តចំពោះខ្លួនឯង ។ ចេវ បានបំពេញភារកិច្ចជូនអង្គការ» ។ ក្នុងនាមជា «ជនក្បត់» អ្នកដែលរិះគន់នយោបាយរបស់អង្គការ លួចបាយហូប ចង់រត់គេចសមគំនិតប្រឆាំងនឹងរដ្ឋអំណាច ឬមិនបង្ហាញនូវស្មារតីបដិវត្តន៍ «ត្រឹមត្រូវ» នឹងត្រូវដាក់ទណ្ឌកម្មដោយស្របច្បាប់ និង/ឬសម្លាប់ចោល ។ អំពើហិង្សាប្រឆាំងនឹងខ្មាំងត្រូវបានលើកទឹកចិត្តដោយមនោគមវិជ្ជារបស់ខ្មែរក្រហមដែលប្រៀបធៀបទៅនឹងពណ៌ឈាមក្រហមឆ្អិនឆ្អៅដូចដែលលើកឡើងនៅក្នុងចម្រៀងជាតិសុន្ទរកថានយោបាយ និងចម្រៀងបដិវត្តនានា ។

ការប្រៀបធៀបដ៏ប៉ិនប្រសប់ទៅនឹងឈាម ក៏មាននៅក្នុងវប្បធម៌របស់ខ្មែរដែរ ពោលគឺពាក្យ «គុំ» ឬកំហឹងដែលតែងតែនាំដល់ការសងសឹកលើសពីអំពើដែលមនុស្សម្នាក់ទទួលរងទៅទៀត ។ «គុំ» គឺជា «ការចងកំហឹងក្នុងរយៈពេលយូរមិនងាយនឹងសាបរលាបនាំដល់ការសងសឹក ។ ហើយការសងសឹកនេះមានកម្រិតធ្ងន់លើសពីការខូចខាតពីមុនទៅទៀត ។ ប្រសិនខ្ញុំវាយអ្នកឯងមួយដៃ ប្រាំឆ្នាំក្រោយ អ្នកឯងលួចបាញ់ខ្ញុំពីក្រោយខ្នងនៅពេលយប់ងងឹតមួយ ។ នេះហៅថា «គុំ» ។ ជនជាតិខ្មែរដឹងច្បាស់ណាស់អំពីពាក្យ«គុំ» ។ នេះជាជំងឺឆ្លងដែលរាលដាលនៅក្នុងព្រលឹងជាតិយើង» ។ ដោយសារវាជារឿងទូទៅទៅហើយក្នុងការបណ្តុះកំហឹងនៅពេលមនុស្សម្នាក់ធ្វើឲ្យខ្លួនបាក់មុខបាក់មាត់ឬឈឺចាប់ មានប្រជាកសិករច្រើនណាស់សម្តែងការមិនពេញចិត្តចំពោះអ្នកមានប្រាក់និងអ្នកមានអំណាចដែលមើលងាយមើលថោកដល់ខ្លួន ហើយរស់នៅស្រណុកជាងខ្លួន ។ គំនិតរបស់ខ្មែរក្រហមបានលើកយកបញ្ហានេះមកពន្យល់ឲ្យអ្នកគាំទ្រមានការជឿជាក់ថាអ្នកមានពិតជាបានជិះជាន់គាបសង្កត់អ្នកក្រ ហើយថា មានតែ

ការតស៊ូវណ្ណៈទេដែលអាចផ្លាស់ប្តូរស្ថានការណ៍នេះបាន (ដែលជាគំនិតរំពុកឡើងវិញនូវប្រពៃណីតស៊ូ) ។ នៅពេលឡើងមកកាន់អំណាចភ្លាម ខ្មែរក្រហមជាច្រើនមានកំហឹងវណ្ណៈចំពោះ "ពួកមូលធន" ដែលតែងតែខ្វះការគោរព និងជាអ្នកធ្វើឲ្យខ្លួនកាន់តែក្រទៅៗ លំបាកទៅៗ និងជាអ្នកដែលគាំទ្រដល់កម្លាំងរបស់លន់ណុលដែលបានសម្លាប់ជនរួមជាតិរបស់ខ្លួន ។

ការដែលដឹងមុនថាខ្មែរក្រហមនឹងប៉ុនប៉ងសងសឹកមកលើអ្នកនៅទីក្រុងក្រោយពេលឡើងកាន់អំណាច គឺជាភ័ស្តុតាងបញ្ជាក់ដោយអ្នកដែលរស់រានមានជីវិតមួយចំនួន ។ មានបុគ្គលម្នាក់បានរាយការណ៍ពីខ្មែរក្រហមដែលសារភាពជាសាធារណៈថា "ខ្លួនមានកំហឹងពុះកញ្ជ្រោលដែលមិនអាចទប់បានចំពោះពួកសង្គមចាស់ ។ យើងមានកំហឹងយ៉ាងខ្លាំងនៅពេលយើងចេញពីក្នុងព្រៃភ្លាម" ។ មានម្នាក់និយាយថា សូម្បីតែកូនង៉ែតក្នុងអង្រឹងម្នាក់ក៏យើងមិនទុកឲ្យរស់ដែរ" ។ ហាំង ង៉ោ ក៏បានលើកឡើងនូវរឿងមួយដែលគួរឲ្យចាប់អារម្មណ៍ តែមិនមែនប្រឌិត ទាក់ទងនឹងសិល្បៈរបាំដែលមានខ្លឹមសារឃោសនា ។ ពេលនោះតួអង្គជាកម្មាភិបាលស្លៀកពាក់ដូចៗគ្នា គក់ទ្រូងខ្លាំងៗ ព្រមទាំងស្រែកហើយស្រែកទៀតយ៉ាងកងរំពងថា "ឈាមត្រូវសងដោយឈាម!... ឈាមសងដោយឈាម ។ អ្នកឯងសម្លាប់ខ្ញុំ ខ្ញុំសម្លាប់អ្នកឯងវិញ" ។ យើងជាប្រជាជន"ថ្មី" ធ្លាប់នៅម្ខាងនៅក្នុងអំឡុងសង្គ្រាមស៊ីវិលខ្មែរក្រហម...។ ខ្មែរក្រហមបានប្រកាសជាសញ្ញាថាពួកគេនឹងសងសឹកយើងវិញ ។ ខ្មែរក្រហមអាចយកហេតុផលតាមផ្លូវសីលធម៌ថា ការសម្លាប់របស់ខ្លួនពិតជាត្រឹមត្រូវ វាជាអំពើសងសឹកចំពោះអ្នកដែលធ្លាប់ធ្វើឲ្យមានវិសមភាពវណ្ណៈ និងបង្កឲ្យសមមិត្តយើងស្លាប់ជាច្រើននាក់នៅក្នុងកលយុគ ។

ហេតុផលខាងផ្លូវសីលធម៌ពីរទៀតក្នុងការសម្លាប់មនុស្សក៏មានសារសំខាន់ផងដែរនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺការប្រើលេសប្រៀបធៀប និងការធ្វើទារុណកម្មដើម្បីស្រង់យកចម្លើយ ។ **ទីមួយ** ការឈឺចាប់និងការស្លាប់របស់ប្រជាជន ជួនកាលត្រូវបានធ្វើឲ្យមានលក្ខណៈស្របច្បាប់តាមរយៈការប្រៀបធៀបសុខុមាលភាពរបស់ខ្មែរក្រហមដែលទទួលរងនៅសម័យកលយុគ ។ ការឆ្លើយតបជាទូទៅមួយរបស់ខ្មែរក្រហមចំពោះបញ្ហាទាក់ទងនឹងការធ្វើការបាក់កម្លាំង ជំងឺតម្កាត់ ការបង្អត់អាហារ ជីវភាពរស់នៅ និង/ឬ ការសម្លាប់ព្រាវៗ គឺថា "ជនបដិវត្តន៍ឆ្លងការឈឺចាប់លើសនេះ១០ដងនៅក្នុងសម័យកលយុគ" ។ តាមរយៈការប្រើការប្រៀបធៀបទាំងនេះ កម្មាភិបាលខ្មែរក្រហមមានលទ្ធភាពក្នុងការកាត់បន្ថយនូវផលប៉ះពាល់នៃការស្លាប់និងការរស់នៅលំបាកឲ្យឃើញតិចបំផុត ។ **ទីពីរ** ខ្មែរក្រហមតែងតែបញ្ជូនជនសង្ស័យថាជា "ខ្មាំង" ទៅដាក់គុក ដែលនៅទីនោះជនសង្ស័យត្រូវបានធ្វើទារុណកម្មរហូតទាល់តែឆ្លើយសារភាពថាខ្លួនពិតជាបាន"ធ្វើខុស"មែន ។ លក្ខខណ្ឌរស់នៅកន្លែង"អប់រំកែប្រែ"ទាំងនេះគួរឲ្យរន្ធត់ណាស់ៈ អ្នកទោសត្រូវដាក់ច្រវាក់ញាត់ចូលកន្លែងតូច ក្តៅ ចង្អៀតរកតែងើបខ្លួនមិនចង់រួច ។ អ្នកទោសត្រូវវាយដំប្រំផាក់ឬធ្វើឲ្យមើលលែងស្គាល់ ទុកចោលឲ្យរស់នៅប្រឡូកប្រឡាក់ជាមួយលាមកនិង

ការរៀបចំអដ្ឋិធាតុជនរងគ្រោះបន្ទាប់ពីគាស់ចេញពីរណ្តៅសាកសពរួម



ទឹកនោមរបស់ខ្លួន ធ្វើទារុណកម្មគួរឲ្យព្រឺព្រួច និង/ឬ សម្លាប់ចោលតាមអំពើចិត្ត ។ ការធ្វើឲ្យបាត់បង់តម្លៃជាមនុស្សរបៀបនេះ ធ្វើឲ្យមានភាពងាយស្រួលក្នុងការធ្វើទារុណកម្មជនរងគ្រោះ ។ ទារុណកម្មធ្វើឲ្យចេញចម្លើយសារភាព ។ ចម្លើយសារភាពធ្វើឲ្យមានហេតុផលតាមផ្លូវសីលធម៌ដល់ដំណើរការទាំងមូល ។

### ការកាត់បន្ថយភាពឆាប់រំភើប

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវមួយក្រោយពេលសង្រ្គាមបង្ហាញឲ្យឃើញថា កងកម្លាំងប្រដាប់អាវុធសហរដ្ឋអាមេរិកដែលហ្វឹកហ្វឺនហើយជាង៥០ភាគរយប៉ុណ្ណោះ ដែលត្រូវបានរាយការណ៍មកថាបានបាញ់កាំភ្លើងចេញពីកាណុងរបស់ខ្លួននៅក្នុងសង្រ្គាមលោកលើកទី២ ។ ផ្អែកទៅតាមព័ត៌មាននេះ ការហ្វឹកហ្វឺនយោធាត្រូវបានផ្លាស់ប្តូរ ធ្វើយ៉ាងណាដើម្បីឲ្យទាហានរើសថ្មីកាត់បន្ថយនូវភាពឆាប់រំភើបមិនញញើតនឹងសម្លាប់មនុស្ស ។ បច្ចេកទេសបញ្ចូលមនោគមវិជ្ជាត្រូវបានបង្កើនឡើងជាលំដាប់ ដើម្បីឲ្យពលទាហានស៊ាំនឹងគំនិត "កម្ទេច" ខ្មាំង ។ ដូចដែលទាហានជើងទឹកម្នាក់និយាយថាៈ "សម្លាប់ សម្លាប់ សម្លាប់ សម្លាប់ ។ គេបង្ហាត់បង្រៀនយើងអ៊ីចឹង ធ្វើម៉េចនៅពេលជួបសភាពការណ៍ជាក់ស្តែង ឲ្យយើងក្លាហានកុំខ្វាយខ្វល់ញញើតញញើម" ។


រូបថតឆ្នាំ១៩៨២

កម្មាភិបាលខ្មែរក្រហមហាក់បីដូចជាប្រកាន់យកតាមផ្លូវនេះដែរ ។ យុទ្ធជនថ្មីថ្មោងត្រូវដាក់បញ្ចូលមនោគមវិជ្ជាដែល "ធ្វើឲ្យចិត្តគំនិតរបស់គេមានកំហឹងកម្រោលចំពោះខ្មាំង" ។ វគ្គប្រជុំឃោសនា បំពាក់បំប៉នចិត្តសាស្រ្ត ស្វ័យទិតៀន និងការបញ្ចូលជាសមាជិកទៅតាមអង្គភាពនានា បានបង្កើននូវ "ស្មារតីបដិវត្ត" ។ ក្មេងៗតូចៗមកពីស្រទាប់អ្នកក្រខ្សត់ត្រូវបានធ្វើឲ្យចូលចិត្តចង់ធ្វើយុទ្ធជន ដោយសារក្មេងទាំងនោះបើតាមពាក្យម៉ៅនិយមថាជា"ក្រដាសសយ៉ាងស្អាតដែលអាចសរសេរអ្វីក៏បាន" ។

ខ្មែរក្រហមស៊ាំទៅនឹងអំពើឃោរឃៅនៅក្នុងអំឡុងសង្រ្គាមឈ្លប ការទម្លាក់គ្រាប់បែក និងសង្រ្គាមស៊ីវិល រួចទៅហើយ ។ អ្នករស់រានមានជីវិតជាច្រើននាក់បាននិយាយអំពីស្ថានភាពប្រយុទ្ធតឹងតែងរបស់យុទ្ធជនខ្មែរក្រហមនៅពេលវាយចូលទីក្រុងភ្នំពេញ ។ អាកប្បកិរិយាហិង្សារបស់ខ្មែរក្រហមមិនសូវខុសគ្នានឹងសមមិត្ត ចេវ ប៉ុន្មានទេ ។ "ការសម្លាប់មនុស្សជារឿងធម្មតាទៅហើយ ។ វាជារឿងការងារ ។ មិនបាច់គិតច្រើនទេ គឺត្រូវតែធ្វើ" ។ មានម្នាក់បានប្រាប់ខ្ញុំថា ដំបូងដូចជាសមមិត្ត ចេវ ដែរ គឺថា"គ្មានចិត្តសម្លាប់មនុស្សទេ ហើយមានចិត្តអាណិតជនរងគ្រោះណាស់ ។ ក៏ប៉ុន្តែក្រោយពីសម្លាប់បានពីរបីដងហើយ ការសម្លាប់ក៏ក្លាយជារឿងធម្មតា ។ វាជាវិធីមួយបង្ហាញពីភាពក្លាហានទៅវិញ" ។ "ការស្លាប់គ្មានន័យ" ត្រូវបានបំពាក់បំប៉នដោយមនោគមវិជ្ជាកម្ពុជាប្រជាធិបតេយ្យ ជាពិសេសការប្រតិបត្តិសីលធម៌ហិង្សានៅតាមមូលដ្ឋាន និងការលើកសរសើរដល់ការបូជាសាច់ស្រស់ឈាមស្រស់ ។ ដូចជាវេជ្ជបណ្ឌិតធ្វើការនៅជំរំណាហ្ស៊ីដែរ សមាជិកដែលទើបចូលថ្មីទៅក្នុងជំរំឃោរឃៅនេះ ត្រូវតែដឹកឲ្យស្រវឹងសិនមុនពេលសម្លាប់ជនរងគ្រោះ ។

ប៉ុន្តែយុទ្ធជនភាគច្រើនមិនបាច់ស្រវឹងក៏សម្លាប់បានដែរ ។ មានអ្នកខ្លះរហូតដល់សប្បាយនឹងសម្លាប់មនុស្ស ហើយអ្នកខ្លះទៀតក្រោយពីសម្លាប់ហើយ អួតប្រាប់គេប្រាប់ឯងទៀតផង ។ ចំពោះ«ភ្នាក់ងារផ្តាច់ព្រលឹង» ការដែលខ្លួនស្ថិតនៅជោគជាំជាមួយហិង្សាដូច្នេះទៅ វាធ្វើឲ្យលែងខ្លាចនឹងសម្លាប់មនុស្សទៀតហើយ ។

### គោរពអំណាច

បើមានមនុស្សច្រើនសង្ស័យទៅនឹងការរៀបរាប់របស់អារិនដ៍ ទៅលើរឿងរ៉ាវរបស់ អេចម៉ាន់ ដែលជាការិយាលេខានុការសាមញ្ញដែលជាការបង្ហាញនូវ «ភាពឥតន័យនៃអំពើអាក្រក់» ចម្ងល់ទាំងនេះត្រូវបានឆ្លើយតបភាគច្រើនតាមរយៈការសិក្សាស្រាវជ្រាវរបស់ ស្តែនលី មីលក្រាម ក្រោមប្រធានបទ «ការគោរពអំណាច» ។ មីលក្រាម រកឃើញថា ភាគច្រើននៃអ្នកចាំឆក់ខ្សែភ្លើងគឺធ្វើតាមការបញ្ជារបស់អ្នកធ្វើពិសោធន៍ដើម្បីបន្តឆក់«អ្នករៀន» ទោះបីជាឃើញច្បាស់ថា ទ្រនិចវ៉ុលអគ្គិសនីលោតភ្លែតៗថា «គ្រោះថ្នាក់-ឆក់ខ្លាំងណាស់» យ៉ាងណាក៏ដោយ ។ ក្រោយមក អ្នកដែលចាំឆក់ជាច្រើននាក់ពន្យល់ថាខ្លួន«ធ្វើអ្វីតាមតែគេប្រាប់ប៉ុណ្ណោះ» ។ ការសិក្សាស្រាវជ្រាវនេះបង្ហាញថា មនុស្សងាយនឹងប្រព្រឹត្តអំពើហិង្សាណាស់នៅក្នុងស្ថានការណ៍ដែលគេបញ្ជាថា «ត្រូវតែធ្វើ» និងស្ថានការណ៍ដែលធ្វើឲ្យខ្លួនអាចបង្វែរកំហុសទៅអ្នកធំៗដែលមានអំណាច ។

ប្រផ្នូលសង្គមនៃការគោរពបែបនេះចាក់ឫសនៅក្នុងវប្បធម៌ខ្មែរយូរហើយ ។ ក៏ដូចជាប្រទេសនៅអាស៊ី-អាគ្នេយ៍ដែរ ទំនាក់ទំនងផ្នែកនយោបាយរបស់កម្ពុជាតែងតែធ្វើឡើងតាមរបៀបបក្ខពួកឬខ្សែរយៈ ។ ជាថ្នូរនឹងការគាំពារនិងជំនួយការលើបញ្ហាផ្សេងៗ ដែលបញ្ហាទាំងនោះមានតែម្នាក់ដែលមានអំណាចជាងគេ ហើយអាចធ្វើទៅបានសម្រេចនោះ កូនចៅគឺត្រូវជំពាក់បំណុលខាងសីលធម៌ដែលត្រូវតែសងវិញតាមរយៈភក្តីភាព លាភសក្ការៈ និងការគោរពបញ្ជា ចំពោះចៅហ្វាយនាយដែលមានអំណាចកាន់តែខ្លាំងឡើងៗ ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ អង្គការក្លាយទៅជាអំណាចនយោបាយថ្មីមួយដែលត្រូវតែមានភក្តីភាពនិងការគោរពដាច់ខាត ។ ប្រជាជនត្រូវបានប្រាប់ថា កុំឲ្យគិតអី «អង្គការគិតឲ្យហើយ» ។ ការគោរពបញ្ជាត្រូវបានជំរុញដោយការបំភិតបំភ័យ ការតាមដាន ប្រជុំស្វ័យទិតៀន វគ្គបំពាក់បំប៉នសតិអារម្មណ៍ និងភេរវកម្ម ។

បន្ថែមពីលើការសង្ឃឹមដែលថាប្រជាជននឹងគោរពអង្គការ យុទ្ធជនត្រូវបានហ្វឹកហ្វឺនឲ្យគោរពបញ្ជាអង្គការដាច់ខាត ។ យុទ្ធជនដែលទើបត្រឡប់មកពីរៀនសូត្រវិញត្រូវបានប្រែក្លាយទៅជា«ជនដាច់ខាតរបស់បក្សដែលមិនងាករេពីការងារជាគោល» ។ ដោយហេតុថា សីលធម៌ហិង្សាត្រូវបានធ្វើឲ្យស្របច្បាប់នៅតាមមូលដ្ឋាន វិន័យយោធានិងការគោរពបញ្ជាតឹងរ៉ឹងនៅតែមានអានុភាពពេញទូទាំងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ។ «នៅក្នុងសង្គ្រាមស៊ីវិល យុទ្ធជនប្រភេទនេះត្រូវបានហ្វឹកហ្វឺនឲ្យសម្លាប់កងទ័ពលន់ណុល ។ នៅពេលដែលមានបញ្ជាឲ្យសម្លាប់ប្រជាជន«ថ្មី»នៅសមរភូមិមុខ យុទ្ធជនទាំងនោះធ្វើដោយស្វ័យប្រវត្តិ» ។ ពេជ្ឈឃាតខ្មែរក្រហមម្នាក់បានប្រាប់ខ្ញុំថា «ខ្ញុំសម្លាប់គឺដោយសារខ្ញុំគោរពបញ្ជាពីថ្នាក់លើ ។ ប្រសិនបើគេបញ្ជាឲ្យខ្ញុំធ្វើអ្វី ខ្ញុំត្រូវតែធ្វើ ។ បើមិនធ្វើតាមគឺត្រូវស្លាប់» ។

ការគោរពបញ្ជានេះត្រូវបានពង្រឹងដោយធម្មនិយមរបស់ក្រុម ។ ប្រជាជនខ្មែរឲ្យតម្លៃទៅលើមុខមាត់ខ្លាំងណាស់ ពីព្រោះកិត្តិយសទទួលបានតាមរយៈការគោរពនិងការធ្វើតាមពីសំណាក់អ្នកដទៃ ។ នៅក្នុងទំនាក់ទំនងសង្គម ជនជាតិខ្មែរនៅតែមានការព្រួយបារម្ភទៅលើបញ្ហាថាតើការគោរពប្រតិបត្តិរបស់ខ្លួនចំពោះអ្នកដទៃនោះ វាសមនឹងឋានៈរបស់គេដែរឬទេ ហើយគេវាយតម្លៃយ៉ាងដូចម្តេច ។ ការចង់បានកិត្តិយសតាមរយៈការឲ្យតម្លៃជាវិជ្ជមានពីអ្នកដទៃ ជាការរួមចំណែកដល់ការឯកភាពនៅក្នុងក្រុម ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ យុទ្ធជនខ្មែរក្រហមជារបស់អង្គការផង និងជារបស់អង្គភាពតូចៗផង ដែលពឹងផ្អែកទៅលើគ្នាទៅវិញទៅមកដើម្បីរស់ ។ ក្រៅពីគោរពវិន័យយោធាតឹងតែង និងស្មោះត្រង់ចំពោះថ្នាក់ដឹកនាំរបស់ខ្លួន បុគ្គលទាំងនោះត្រូវតែគោរពបញ្ជាដាច់ខាត ព្រោះខ្លាចបាក់មុខបាក់មាត់នៅចំពោះមុខសមមិត្តរួមអង្គភាព ។ មានម្នាក់ពន្យល់ប្រាប់ខ្ញុំថា ប្រសិនបើយុទ្ធជនមិនគោរពបញ្ជាសម្លាប់

មនុស្សទេនោះ «វាមានន័យថា ម្នាក់នោះជាមនុស្សកំសាក ជាមនុស្សអន់ជាងគេនៅក្នុងក្រុម ជាអ្នកចាញ់គេទាំងអស់» ។ ជាងនេះទៅទៀត អ្នកដែលធ្វើឲ្យខ្លួនឯងលេចធ្លោជាងគេនៅក្នុងការបំពេញការងារ ពិតជាបានទទួលកិត្តិយស ហើយអាចនឹងតម្លើងឋានន្តរស័ក្តិទៀតផងក៏មាន ។ លទ្ធផលគឺថា «នៅពេលដែលបញ្ជាចេញពីអង្គការថាឲ្យសម្លាប់ គេត្រូវតែធ្វើតាម» ។

កង្វះនូវអារម្មណ៍ថាខ្លួនឯងមានទោស ដែលបង្ហាញឲ្យឃើញតាមរយៈខ្មែរក្រហមទាំងនេះ គឺមួយផ្នែកដោយសារសមត្ថភាពរបស់អ្នកទាំងនេះក្នុងការទម្លាក់ការទទួលខុសត្រូវដែលខ្លួនបានប្រព្រឹត្តទៅលើអ្នកដទៃ ។ បទបញ្ជាចេញពីអង្គការ ដូច្នេះមិនមែនជាការទទួលខុសត្រូវរបស់បុគ្គលទាំងនោះឡើយ ក្នុងការប្រព្រឹត្តអំពើហិង្សា ។ ពាក្យដោះទាល់របស់អ្នកធ្វើតាមបញ្ជាអាចថា «នេះជាច្បាប់ អង្គការជាអ្នកចេញ មិនមែនខ្ញុំចេញដោយខ្លួនឯងឯណា ។ អ្នកធ្វើទារុណកម្មអាចប្រាប់ទៅជនរងគ្រោះរបស់ខ្លួនថា «ប្រាប់ការពិតដល់អង្គការទៅ» ។ ដោយសារតែអង្គការជាតំណាងឲ្យ«បុគ្គលគ្រប់ៗរូប» ដូច្នេះការទទួលខុសត្រូវចំពោះទង្វើទាំងនេះអាចធ្វើឲ្យរសាយបានយ៉ាងជោគជ័យ» ។


ប៊ុន ជីង

## ដំណើរការប្រែក្លាយខ្លួន

ធ្វើដូចម្តេចបានជាមនុស្សដូចជាសមមិត្ត ចេវ ក្លាយខ្លួនជាឃាតករប្រល័យពូជសាសន៍បាន? ដូចដែលបានលើកឡើងខាងដើមរួចហើយថា ការធ្វើឲ្យមនុស្សម្នាក់ក្លាយទៅជា «ភ្នាក់ងារផ្តាច់ព្រលឹង» វាមានលក្ខណៈផ្សេងៗពីគ្នាទៅតាមប្រវត្តិជីវិតរបស់បុគ្គលម្នាក់ៗ ។ យុទ្ធសាស្ត្រកាត់បន្ថយការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមមួយឬច្រើន ឬទាំងអស់ដែលបានលើកឡើងខាងលើ អាចមានសារសំខាន់បំផុតក្នុងការបង្កើតមនុស្សដែលអាចប្រព្រឹត្តអំពើអាក្រក់ ។ មនុស្សទាំងនេះនឹងផ្អែកទៅលើ «ការឆ្លើយតបជាលក្ខណៈរដ្ឋ» នៅពេលដែលខ្លួន «ឆ្លើយតបជាលក្ខណៈផ្ទាល់ខ្លួន» ចំពោះការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមដែលកើតឡើងនៅពេលអ្នកទាំងនោះសម្លាប់មនុស្ស ។ ការបង្កើតគោលគំនិតថ្មីពាក់ព័ន្ធដល់ការសង្កេតពិនិត្យមួយ ដែលក្នុងនោះ ដំណើរការសាំញ៉ាំមានទំនាក់ទំនងគ្នា ដើម្បីជំរុញឲ្យបុគ្គលនោះឃ្លាតចាកពី«អ្វីដែលមិនអាចញែកដាច់ពីគ្នាបាន» ។ ការបដិសេធនិងការបញ្ចុះតម្លៃទៅមនុស្សមួយក្រុម ធ្វើឲ្យមនុស្សនោះស្ថិតនៅក្រោមសង្គម ។ ការធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ធ្វើឲ្យការប៉ះពាល់ទៅលើមនុស្សប្រភេទនេះមានហេតុផលត្រឹមត្រូវតាមសីលធម៌ ។ ដោយប្រើពាក្យសម្រាលកុំឲ្យអាក្រក់ស្តាប់ពេក និងបង្វែរការទទួលខុសត្រូវទៅលើអ្នកមានអំណាចវិញ ការទទួលខុសត្រូវដែលនៅសល់ទាំងអម្បាលម៉ានអាចរលាយអស់ ។ ដោយសារមានមនុស្សទទួលរងនូវផលប៉ះពាល់ ជនដៃដល់មានភាពស៊ាំទៅនឹងអំពើឃោរឃៅ ។ ការធ្វើឲ្យអារម្មណ៍មិនរំភើបខ្លាំង នាំឲ្យការធ្វើឲ្យ

បាត់បង់តម្លៃជាមនុស្សទៅលើជនរងគ្រោះ ហាក់ដូចជាធម្មតាទៅហើយ ។

ខ្មែរក្រហមជាច្រើនអាចទទួលរងនូវការប៉ះពាល់អារម្មណ៍តាមចិត្តសាស្ត្រសង្គម នៅពេលដែលគេបញ្ជាឲ្យខ្លួនសម្លាប់មនុស្សដែលពីមុនធ្លាប់រស់នៅក្នុងសហគមន៍ជាមួយគ្នា (ឧទាហរណ៍ដូចជានៅពេលដែលសីលធម៌ហិង្សានិងសីលធម៌អហិង្សាប្រឆាំងគ្នា) ។ «ភ្នាក់ងាររផ្តាច់ព្រលឹង» ទាំងនេះកាត់បន្ថយការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមទៅតាមវិធីជាច្រើន ។ **ទីមួយ** អ្នកទាំងនោះបានផ្លាស់ប្តូរនូវគំរូវប្បធម៌ (ពោលគឺគេធ្វើយ៉ាងនេះក៏ដោយសាររបបកម្ពុជាប្រជាធិបតេយ្យលើកតម្កើងឬឲ្យតម្លៃទៅលើហិង្សា និងបំផ្លាញចោលនូវសីលធម៌អហិង្សានៅក្នុងការបង្កើត «វាលពិឃាត») ។ **ទីពីរ** អ្នកប្រព្រឹត្តទាំងនេះបានផ្លាស់ប្តូរអាកប្បកិរិយារបស់ខ្លួន (ពោលគឺពេលដែលគេសម្លាប់មនុស្សរួចហើយ អំពើឃោរឃៅបែបនេះក្លាយជាទម្លាប់ទៅហើយ) ។ **ទីបី** កម្មាភិបាលខ្មែរក្រហមប្រព្រឹត្តសកម្មភាពនៅក្នុងបរិយាកាសមួយដែលមានការផ្លាស់ប្តូរយ៉ាងខ្លាំង (ពោលគឺមនោគមវិជ្ជារបស់កម្ពុជាប្រជាធិបតេយ្យមិនត្រឹមតែធ្វើឲ្យសីលធម៌ហិង្សាមានលក្ខណៈស្របច្បាប់ទេ ថែមទាំងលើកតម្កើងសីលធម៌ហិង្សានេះផងនៅក្នុងទំនាក់ទំនងនៅតាមមូលដ្ឋាន) ។ ចំណុចចុងក្រោយ បុគ្គលទាំងនេះមានលទ្ធភាពអាចបន្ថែមនូវគម្រោងថ្មីក្នុងកម្រិតទាបជាងមុន ដែលធ្វើឲ្យគំរូវប្បធម៌ធំៗស៊ីគ្នា (ដូចជាតាមរយៈការធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ការប្រើពាក្យសម្រាលកុំឲ្យអាក្រក់ស្តាប់ ការឲ្យហេតុផលតាមផ្លូវសីលធម៌ និងការផ្ទេរការទទួលខុសត្រូវឲ្យអ្នកផ្សេង) ។ លទ្ធផលនៃដំណើរការរៀបចំការយល់ដឹងបែបនេះ គឺការបង្កើតនូវ «ភ្នាក់ងាររផ្តាច់ព្រលឹង» ដូចជាសមមិត្ត ចេវ ដែលអាចប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

### សេចក្តីសន្និដ្ឋាន

### គំនិតតាមបែបនរវិទ្យាលើបញ្ហាប្រល័យពូជសាសន៍

*«ព្រនង់ផ្តាច់ជីវិតមានទម្ងន់សែនធ្ងន់ដែលខ្ញុំមិនអាចប្រាប់បាន! ព្រនង់នេះហាក់ដូចជាកំហឹងរបស់ព្រះជាម្ចាស់...»*

*(កវី ស៊ីសា វ៉ាឡេប៊ូ)*

ខ្ញុំយល់ស្របតាមកវី ស៊ីសា ដែលថាវាជាការពិបាកក្នុងការស្វែងយល់ថាធ្វើដូចម្តេចបានជាមនុស្សម្នាក់ហ៊ានសម្លាប់មនុស្សម្នាក់ទៀតយ៉ាងងាយ ។ ប៉ុន្តែខ្ញុំយល់ថាយើងអាចយល់ដឹងបានតាមរយៈព្រឹត្តិការណ៍ប្រល័យពូជសាសន៍ក្នុងទ្រង់ទ្រាយធំ ។ នៅពេលប្រឈមមុខនឹងហេតុការណ៍ដ៏គួរឲ្យរន្ធត់នៃអំពើប្រល័យពូជសាសន៍ អ្នកសិក្សាជាន់ខ្ពស់ស្ទើរតែទាំងអស់សុទ្ធតែគ្រវីក្បាលដើរចេញ មិនគិតខំស្វែងរកដើមហេតុឫសគល់នៃអំពើឃោរឃៅនេះឡើយ ។ នរវិទូពីមុនក៏ដូចជាបច្ចុប្បន្នដែរ គឺតែងតែធ្វើព្រងើយកន្តើយចំពោះបញ្ហានេះ ។ ប្រហែលមកពីគំនិតរួមដែលជាប់ពាក់ព័ន្ធគ្នា ដែលឃ្លាំមើលវប្បធម៌នៃការសិក្សាស្រាវជ្រាវរបស់«យើង» ឃាត់យើងមិនឲ្យអះអាងឲ្យបានខ្លាំងទៅលើធម្មចរិយានៃព្រឹត្តិការណ៍ប្រល័យពូជសាសន៍ហើយមើលទៅ ។ ដូចអត្ថបទនេះបង្ហាញស្រាប់ហើយថា ខ្ញុំមិនគិតថានេះជាជំហរមួយដែលទទួលខុសត្រូវនោះទេ ។ ច្បាស់ណាស់គឺដោយសារនរវិទូអាចវិភាគទៅលើលក្ខខណ្ឌនានាដែលសម្រួលដល់អំពើប្រល័យពូជសាសន៍ក្នុងទ្រង់ទ្រាយធំនេះហើយ បានជាយើងត្រូវតែចាប់ផ្តើមពិនិត្យលើប្រធានបទនេះ ។

អត្ថបទនេះមានចេតនាចង់បង្កើតនូវការពិភាក្សាមួយដោយផ្អែកលើចិត្តវិទ្យានិងនរវិទ្យា ។ ខ្ញុំអះអាងថា មុនពេលច្រានចោលគំនិតចិត្តវិទ្យាលោកខាងលិច យើងត្រូវកំណត់ជាមុនក្រែងលោគំនិតទាំងនោះអាចអនុវត្តបានផ្ទៃផ្កាក្នុងលក្ខណៈអន្តរវប្បធម៌ ទោះបីជាក្នុងទម្រង់នៃការយល់ឃើញតាមចិត្តវិទ្យាមានការផ្លាស់ប្តូរមួយចំនួនក៏ដោយ ។ ធ្វើយ៉ាងនេះយើងអាចពិភាក្សាវែកញែកលើប្រធានបទប្រល័យពូជសាសន៍នេះតាមរបៀបសិក្សាពីរយ៉ាងផ្សេងគ្នាតែលើផ្លូវតែមួយ ។ ការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមបង្ហាញនូវគំនិតមួយដែលអាចផ្តល់ផ្ទៃផ្កាទាំងលំបាកចេញពីសំយោគរវាងការយល់ផ្ទុះជ្រៅតាមបែបចិត្តវិទ្យាសង្គមនិងនរវិទ្យា ហើយអាចជួយឲ្យយើងយល់អំពីព្រឹត្តិការណ៍ប្រល័យពូជសាសន៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងជាពិសេសនៅកន្លែងផ្សេងៗទៀត ។

អត្ថបទនេះមិនត្រឹមតែបង្ហាញពីវិធីនានាដែលជនដៃដល់ដែលប្រព្រឹត្តអំពើឃោរឃៅប៉ុនប៉ងកាត់បន្ថយការប៉ះពាល់

អារម្មណ៍ដោយចិត្តសាស្ត្រសង្គមនោះទេ ថែមទាំងបង្ហាញអំពីរបៀបដែលរបបប្រល័យពូជសាសន៍ខិតខំសម្របសម្រួលគំរូវប្បធម៌ដើម្បីប្រែក្លាយសតិអារម្មណ៍របស់ "ភ្នាក់ងារផ្តាច់ព្រលឹង" ទាំងនេះផង ។ ដោយសារវាអាចពន្យល់ទាំងកត្តាកម្រិតទាបនិងកត្តាកម្រិតខ្ពស់ គំរូនៃការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមដែលខ្ញុំលើកឡើង អាចផ្តល់នូវការពន្យល់កាន់តែលម្អិតជាជាងយកគំនិតមួយមកពន្យល់តែម្នាក់ឯង ។ ឧទាហរណ៍ៈ គំនិតមួយដែលនិយាយអំពីកម្រិតខ្ពស់ដែលសន្មតថាពេជ្ឈឃាតប្រល័យពូជសាសន៍សុទ្ធតែជាមនុស្សដែលធ្វើការដូចជាមនុស្សយន្តដែលដើរតាមគំនិតរបស់រដ្ឋនោះ មិនអាចពន្យល់អំពីភាពផ្សេងគ្នា នៅក្នុង"ការឆ្លើយតបជាលក្ខណៈបុគ្គល"នៃអ្នកប្រព្រឹត្តដែលមានលក្ខណៈខុសគ្នាស្រឡះទេ ។ ដូចគ្នានេះដែរ គម្រោងកម្រិតទាបដែលផ្តោតសំខាន់ទៅលើដំណើរការចិត្តសាស្ត្រសង្គមមានការលំបាកក្នុងការពន្យល់អំពីរបៀបនៃ "ការឆ្លើយតបជាលក្ខណៈរដ្ឋ" ក្នុងការបង្កើតបរិបទនានាដែលអំពើហិង្សាប្រល័យពូជសាសន៍កើតឡើង ។ ដោយសារតែទម្រង់នៃការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមនេះទាញយកគំនិតចេញពីការវិភាគតាមកម្រិតទាបនិងកម្រិតខ្ពស់ចូលគ្នា នៅក្នុងលក្ខណៈវប្បធម៌ ទម្រង់នេះបង្ហាញនូវការរួមចំណែកបែបនរវិទ្យាផ្សេងៗគ្នា ដល់ការយល់ឃើញរបស់យើងទៅលើដើមកំណើតនៃអំពើប្រល័យពូជសាសន៍ដែលមានទ្រង់ទ្រាយធំ ។ ដោយមានស្នាដៃស្រាប់លើបញ្ហាអំពើឃោរឃៅនិងប្រធានបទស្មុគស្មាញផ្សេងៗទៀត នរវិទូអាចបង្កើននូវការវិភាគកាន់តែស៊ីជម្រៅថែមទៀត ដែលធ្វើឲ្យការយល់ឃើញរបស់យើងកាន់តែកើនឡើងទៅលើអំពើប្រល័យពូជសាសន៍ដែលមានទ្រង់ទ្រាយធំ ។ ខ្ញុំបានជំរុញឲ្យអ្នកទាំងនោះធ្វើការនេះ ។

សេចក្តីសន្និដ្ឋានមួយក្នុងចំណោមសេចក្តីសន្និដ្ឋានដែលមានបញ្ហាកើតចេញពីការវិភាគនេះគឺថា អំពើប្រល័យពូសាសន៍មិនហាក់ដូចជារបស់ដែលត្រឹមតែជា "ពេជ្ឈឃាតដែលសម្លាប់មនុស្សទាំងសប្បាយ" នោះទេ ។ អស់រយៈពេលយូរមកហើយ អារ៉េន និយាយត្រូវដែលលើកឡើងថា ការសម្លាប់ក្លាយជាគ្មានន័យ សឹងតែមានន័យថាម្នាក់ៗសុទ្ធតែអាចធ្វើដូច្នេះបានទាំងអស់គ្នាប្រសិនបើមានការហ្វឹកហាត់ត្រឹមត្រូវ និង/ឬមានការផ្លាស់ប្តូរការយល់ឃើញរបស់ផងខ្លួន ។ ប្រសិនបើវាជាការពិតមែន តើយើងអាចទប់ស្កាត់អំពើប្រល័យពូជសាសន៍តាមវិធីណា? ដំបូងដូចដែលលើកឡើងខាងលើស្រាប់ហើយ គឺយើងអាចវិភាគទៅលើគំនិតដ៏ស្មុគ្រស្មាញដែលប្រឌិតឡើង ដែលផ្តល់នូវពត៌មានកាន់តែស៊ីជម្រៅថែមទៀតទៅលើបញ្ហាថាតើអំពើប្រល័យពូជសាសន៍កើតឡើងដោយរបៀបណា ហើយនៅពេលអំពើប្រល័យពូជសាសន៍កើតឡើង តើត្រូវបញ្ឈប់វាយ៉ាងដូចម្តេច ។ ឧទាហរណ៍ៈ សញ្ញាណនៃការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គម ជួយយើងឲ្យយល់ពីរបៀបដែលមនុស្សត្រូវបានបំប្លែងឲ្យទៅជា "ភ្នាក់ងារផ្តាច់ព្រលឹង" តាមរយៈបណ្តុំវាំងសតិអារម្មណ៍ វប្បធម៌សង្គម និងបម្លាស់ប្តូរការយល់ឃើញ ។ ដើម្បីដឹងពីអំពើប្រល័យពូជសាសន៍នៅជាក់ស្តែង យើងអាចពិនិត្យមើល "ការឆ្លើយតបជាលក្ខណៈរដ្ឋ" របស់សង្គមណាមួយដើម្បីឲ្យដឹងថាតើវាជាការបង្កើតនូវលក្ខខណ្ឌតម្រូវមុនចំពោះការកាត់បន្ថយការប៉ះពាល់អារម្មណ៍តាមចិត្តសាស្ត្រសង្គម (ដូចជាតាមរយៈការបំផ្លាញចោលនូវគំរូវប្បធម៌ដែលជំរុញអហិង្សា បង្កើនហិង្សាប្រឆាំងនឹងក្រុមដែលអស់តម្លៃជាមនុស្សតាមរយៈសតិអារម្មណ៍ បញ្ចេញនូវទម្រង់ពាក្យសម្រាលកុំឲ្យអាក្រក់ស្តាប់) ។ ស្រដៀងគ្នានេះដែរ នៅពេលអំពើឃោរឃៅប្រល័យពូជសាសន៍កើតឡើងហើយ យើងអាចព្យាយាមបង្អាក់ឬទប់ស្កាត់ "ការឆ្លើយតបជាលក្ខណៈបុគ្គល" ដែលធ្វើឲ្យមនុស្សក្លាយជា "ភ្នាក់ងារផ្តាច់ព្រលឹង" ។ ដោយសារការធ្វើឲ្យបាត់បង់តម្លៃជាមនុស្សមានសារសំខាន់នៅក្នុងដំណើរប្រែក្លាយមនុស្សបែបនេះ យើងអាចចាត់វិធានការនានាក្នុងការធ្វើឲ្យជនរងគ្រោះ "មានតម្លៃជាមនុស្សវិញ" ។ ជាក់ស្តែងករណីនីមួយៗត្រូវតែពិនិត្យជាក់ដោយឡែកពីគ្នា ដើម្បីកំណត់ឲ្យច្បាស់ថាធ្វើយ៉ាងដូចម្តេចទើបអាចទប់ស្កាត់ឬបញ្ឈប់ពេជ្ឈឃាតប្រល័យពូជសាសន៍បាន ។ យើងនៅតែយល់ស្របតាមសម្តីរបស់ រ៉ាឡេចូ ប៉ុន្តែយើងត្រូវព្យាយាមផ្តល់នូវការវិភាគដែលមានលក្ខណៈគួរឲ្យចាប់អារម្មណ៍បែបនេះទៅលើអំពើប្រល័យពូជសាសន៍ ។ យើងដែលជានរវិទូ អាចឆ្លើយបាន ។

**អាឡិច ហ៊ីនតុន**


សមមិត្ត អៀង សារី

# ហេតុអ្វីនៅតែពុំមានការកាត់ទោសមេដឹកនាំខ្មែរក្រហម?

មិត្តភក្តិជាច្រើនធ្លាប់សួរខ្ញុំថា តើអាចកាត់ទោសមេដឹកនាំខ្មែរក្រហមបានដែរឬអត់? ខ្ញុំមិនបានគិតថាខ្ញុំត្រូវឆ្លើយនឹងសំណួរនេះទេ ។ ខ្ញុំយល់ថា មិនត្រឹមតែមិត្តភក្តិរបស់ខ្ញុំប៉ុណ្ណោះទេ គឺប្រជាជនកម្ពុជាទាំងអស់ រួមទាំងអតីតខ្មែរក្រហម កំពុងតែចាប់អារម្មណ៍កាន់តែខ្លាំងលើបញ្ហានៃការចរចាដើម្បីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ភាពមិនទាន់ច្បាស់លាស់នៃលទ្ធផលដែលកើតចេញអំពីការចរចាររវាងភាគីកម្ពុជានិងអង្គការសហប្រជាជាតិ នៅក្នុងដំណើរការនៃការបង្កើតអង្គតុលាការចម្រុះមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម អំពីបទឧក្រិដ្ឋកម្មដែលបានធ្វើឲ្យបាត់បង់ជីវិតប្រជាជនកម្ពុជារាប់លាននាក់ នៅក្នុងអំឡុងពេលនៃការកាន់អំណាចរវាងឆ្នាំ១៩៧៥-៧៩ កំពុងតែបន្តនៅឡើយ ។ ផ្តើមចេញពីលិខិតស្នើសុំរបស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៩រហូតដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ ដំណើរការចរចាដើម្បីបង្កើតតុលាការត្រូវគាំងស្ទើរតែទាំងស្រុង ដោយសារអង្គការសហប្រជាជាតិប្រកាសដកខ្លួនឈប់ចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

ប្រជាជនកម្ពុជាដែលធ្លាប់មានកូនចៅបម្រើរបបកាប់សម្លាប់នៃកម្ពុជាប្រជាធិបតេយ្យ ហើយក្រោយមកបានស្លាប់បាត់បង់ជីវិត ឬបាត់ខ្លួនរហូតដល់សព្វថ្ងៃ ព្រមទាំងខ្មែរក្រហមដែលនៅរស់រានមានជីវិត សុទ្ធតែចង់ឲ្យមានតុលាការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ មិនតែប៉ុណ្ណោះ នៅក្នុងចំណោមអ្នកទាំងអស់នោះថែមទាំងអះអាងថា នឹងមិនមានការភ័យខ្លាចអ្វីឡើយ ប្រសិនបើតុលាការកោះហៅមកបំភ្លឺក្នុងករណីចាំបាច់ ។

សុក ផាត រស់នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ចង់ឲ្យមានតុលាការឆាប់ៗ ។ សុក ផាត ធ្លាប់បម្រើការជាយោធាខ្មែរក្រហម ក្រោយមកនៅអំឡុងឆ្នាំ១៩៧៨ បានមកជាប់ឃុំឃាំងនៅមន្ទីរស-២១ (ដែលស្គាល់ជាទូទៅថាគុកទួលស្លែង) ។ សុក


សុក ផាត

ផាត បាននិយាយថា «កាលណាកាត់ទោសភ្លាមៗទៅគឺថាផ្តល់អាជីវកម្មឲ្យប្រជាជនបានធូរធារដែរ... បើមិនអ៊ីចឹងទេនៅតែប្រឆាំងគ្រង់បក្ខពួកនិយម... មិនមែនបក្ខពួកដូចយើងឯណា បក្ខពួកខ្មែរក្រហមដោយឡែកទៅ វានៅតែខាងវាទៅ យើងនៅតែខាងយើងទៅ ម្ល៉ោះហើយអាហ្នឹងថាមានបក្ខពួក ។ កាលណាកាត់ទោសទៅវាផ្តាច់ៗអីចឹងទៅ វាគ្រាន់រំសាយចិត្តរៀងៗខ្លួនគ្រប់គ្នា ។ វាអត់ពិបាកអីប៉ុន្មាន ការរស់នៅតាំងពីមុនរហូតដល់ក្រោយហើយ ក្រោយពីវីខ្មែរក្រហមរហូតដល់ស្រុកសន្តិភាពក៏វានៅអាមេខ្លោងដឹកនាំរហូតមកដល់បច្ចុប្បន្នក៏វាអ៊ីចឹងដែរ ។ អាមេក្លោងដឹកនាំមូលហេតុអី មូលហេតុវានៅអំពាវនាវៗអ៊ីចឹងណា៎ ។ ម៉ោដល់អានេះអានោះក៏អ៊ីចុះទៅ វាទៅតាមលក្ខណៈរបស់វាអ៊ីចឹងទៅ ភារកិច្ចការកសាងកម្លាំងផ្លូវផងនឹតរបស់វាអ៊ីចឹងទៅ» ។

អុន នៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ បានរំឭកសម្តីធៀបរបស់

ខ្មែរក្រហមថា "កុំឲ្យតែបាត់ខ្មែរ បាត់គោបាត់ទៅចុះ" ។ គាត់បន្តទៀតថា "អាហ្នឹងយើងប្រៀបខ្លួនយើងទៅ ព្រោះអាខ្មែរបណ្តាញរបស់វាធំជាងគោ បើយើងមានខ្មែរ ដើរចាប់គោឯណាក៏បានដែរ" ។

ប៊ុល ដាន រស់នៅស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង បាននិយាយថា គាត់ចង់បានតុលាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមឆាប់ៗខាងមុខនេះ ។ ប្រសិនបើមានការអូសបន្លាយយូរៗទៅ តុលាការនឹងគ្មានជនល្មើសសម្រាប់ធ្វើការកាត់ទោសនៅក្នុងដំណាក់កាលចុងក្រោយ ។ ប៊ុល ដាន បាននិយាយថា "ចង់បាននេះចង់បាន ប៉ុន្តែស្តាប់តាមវិទ្យុរាល់ថ្ងៃឃើញដូចជាគ្មានបានលទ្ធផលអី ចេះតែទីទែៗ យូរទៅងាប់មួយ ពន្យារៗទៅងាប់មួយ ដល់យូរៗទៅមិនមានអ្នកណានឹងហៅយកមកកាត់ទោស" ។

ប៉ុល ពត ដែលល្បីថាជាជនកុម្មុយនិស្តដើរតាមលទ្ធិម៉ៅនិយម ជាលេខាបក្សកុម្មុយនិស្តកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យ បានស្លាប់នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៩៨ ។ ចំណែក កែ ពក មេបញ្ជាការយោធាខ្មែរក្រហមប្រចាំភូមិភាគបូព៌ានៅក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ស្លាប់នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០២ ។

ថ្មីៗនេះ សញ្ញាណទៅមុខនៃដំណើរការចរចាដើម្បីបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មានជាថ្មីឡើងវិញតាមរយៈការផ្លាស់ប្តូរលិខិតគ្នាទៅវិញទៅមករវាងរាជរដ្ឋាភិបាលកម្ពុជានិងអគ្គការសហប្រជាជាតិ ។ ឯកឧត្តម ហោ ណាំហុង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បាននិយាយថា លោក កូហ្វី អាណាន់ ចង់ឲ្យមានអាណត្តិដើម្បីចរចាគ្នា ហើយរាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញពីចេតនាយ៉ាងច្បាស់ក្រឡែតថាចង់ឲ្យមានតុលាការ ។

មេដឹកនាំខ្មែរក្រហមដូចជា នួន ជា (អាយុ៧៤ឆ្នាំ) អៀង សារី (អាយុ៧២ឆ្នាំ) ខៀវ សំផន (អាយុ៧៣ឆ្នាំ) កំពុងតែរស់នៅដោយសេរីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ មានតែប្រធានមន្ទីរ ស-២១ ឈ្មោះ ឌុច និងមេទ័ពល្បីឈ្មោះរន្ធឹងដែលនៅក្រោមមេឃមានតែឈ្មោះ ម៉ុក ប៉ុណ្ណោះ ដែលកំពុងជាប់នៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្នដើម្បីរង់ចាំការកាត់ទោស ។

**ខ៊ាន់ថាន់ ពៅដារ៉ា**

---

**(តមកពីទំព័រ៤៤)** យើងអត់បញ្ហាបានថាអំពើរបស់យើងវាត្រូវឲ្យផលជាអីចេះអីចុះ ឲ្យផលនៅពេលណាយើងអត់គ្រប់គ្រងបានទេ ។

***សួរៈ*** ព្រះតេជគុណមានពុទ្ធដីកាថាកម្មជាអំពើដោយចេតនា ។ ចុះអំពើដោយអចេតនាហៅថាកម្មដែរឬទេ?

***ព្រះភិក្ខុ យស ហ៊ុតៈ*** អំពើដោយអចេតនាមិនហៅថាកម្មទេ ។ អំពើអចេតនាបានន័យថាធ្វើដោយអត់ដឹងខ្លួន ។ ឧបមាថាកុំឲ្យសម្លាប់សូម្បីជីវិតសត្វជីវិតមនុស្ស ប៉ុន្តែបើយើងដើរទៅជាន់សត្វល្អិតអ្វីមួយងាប់ ប៉ុន្តែយើងអត់មានចេតនាសោះនឹងសម្លាប់ ។ ហ្នឹងអត់ទៅជាកម្ម-ផលទេ ព្រោះអត់មានចេតនានឹងធ្វើ ។

***សួរៈ*** សូមព្រះតេជគុណពន្យល់ពាក្យ "ការពិត" តើមានន័យដូចម្តេច?

***ព្រះភិក្ខុ យស ហ៊ុតៈ*** "ការពិត" គឺសច្ចធម៌ហ្នឹងឯង គឺតថភាពពិតយ៉ាងណាយើងមើលឃើញយ៉ាងនោះតាមការពិត ។ ឧទាហរណ៍ៈ ការយល់ថាអ្វីៗទាំងអស់ក្នុងលោកនេះគឺសង្ខារទាំងអស់មិនទៀង ។ ហ្នឹងហើយជាការពិត ។ មិនមែនគ្រាន់តែជាទ្រឹស្តី មិនមែនគ្រាន់តែជាជំនឿទេ គឺវាពិតអីចឹងមែន អ្វីទាំងអស់មិនទៀងមែន ។ ព្រះពុទ្ធសាសនាសម្តែងអំពីទុក្ខ អំពីហេតុនៃទុក្ខ អំពីការរំលត់ទុក្ខ អំពីផ្លូវប្រតិបត្តិដើម្បីរំលត់ទុក្ខ នោះជាសច្ចធម៌ដែលព្រះអង្គរកឃើញពេលបានត្រាស់ដឹង ។ ព្រះអង្គរកឃើញថាលោភៈ ទោសៈ មោហៈ ហ្នឹងឯង ជាឫសគល់នៃទុក្ខគ្រប់យ៉ាង ។ សង្គ្រាមក៏ដោយ ទុក្ខអន្តរាយ វិបត្តិតូចធំ វិបត្តិផ្ទាល់ខ្លួន គ្រួសារ សង្គម រហូតដល់សង្គ្រាមក្នុងប្រទេសឬក្នុងសកលលោកហេតុវាគឺលោភៈ ទោសៈ មោហៈ ។ សង្គ្រាមក៏ចាប់ផ្តើមពីចិត្តសន្តិភាពក៏ចាប់ផ្តើមពីចិត្តដែរ ។ ព្រះពុទ្ធសាសនាបង្រៀនឲ្យបន្ថយរហូតដល់រលត់អស់នូវលោភៈ ទោសៈ មោហៈ ។ បើកិលេសទាំងនេះថយចុះ សេចក្តីសុខនឹងកើនឡើង ហើយបើកិលេសទាំងនេះរលត់អស់ទៅបរមសុខក៏នឹងបានសម្រេចឡើង ។ **កល្យាណ និងកន្និដ្ឋា**

# មិនអាចកាត់ផ្តាច់ក្តីនឹករឭក


ខិន អឿន

ខិន អឿន អាយុ ៦០ឆ្នាំ មានស្រុកកំណើតនៅភូមិពោធិ៍ចិន្តាំ ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង។ គាត់មានឪពុកឈ្មោះ ដួង ខិន ស្លាប់នៅក្នុងរបបខ្មែរក្រហម ដោយសារជំងឺ និងម្តាយឈ្មោះ នុត អោ បច្ចុប្បន្នមានអាយុ៨១ឆ្នាំ ។

នៅឆ្នាំ១៩៧០ អឿន បានរៀបការជាមួយ ទេព យន់ ហៅ ដុយ ដែលជាជនជាតិវៀតណាម ។ ដុយ មានស្រុកកំណើតនៅស្រុកពាមរ ខេត្តព្រៃវែង ។ ឪពុកម្តាយរបស់ ដុយ ជាជនជាតិវៀតណាមដែលភៀសខ្លួនពីប្រទេសវៀតណាមមករស់នៅនិងរកស៊ីនៅស្រុកពាមរ (អ្នកលឿង) ខេត្តព្រៃវែង ។

នៅខណៈពេលដែលមានការទម្លាក់គ្រាប់បែកយ៉ាងខ្លាំងនៅស្រុកពាមរ ដុយ បានភៀសខ្លួនមកភូមិពោធិ៍ចិន្តាំ និងបានស្នាក់នៅជាបណ្តោះអាសន្ននៅផ្ទះរបស់ យាយលាង ដែលធ្លាប់ជាអ្នកជិតខាងរបស់ ដុយ ។ រយៈពេលដែលស្នាក់នៅភូមិពោធិ៍ចិន្តាំ ដុយ បានចាប់ចិត្តស្រលាញ់ អឿន ។ ដុយ បានពឹងពាក់ យាយលាង និងចាស់ៗពីរបីនាក់ ឲ្យចូលស្តីដណ្តឹង អឿន តាមប្រពៃណីខ្មែរ ។ ឪពុកម្តាយរបស់ អឿន យល់ព្រមរៀបការ អឿន ឲ្យ ដុយ ដោយបង្គាប់បណ្តាការជាប្រាក់ប្រាំរយរៀលនិងម្ហូបប្រាំតុ ។

ពិធីមង្គលការរវាង អឿន និង ដុយ ត្រូវបានបងប្អូនញាតិមិត្តអបអរសាទ ។ នៅមុនរបបខ្មែរក្រហម ការរៀបការជាមួយអាណិកជនវៀតណាមជារឿងធម្មតា ។

ក្រោយពេលរៀបការ ដុយ គឺជាមេគ្រួសារ ។ ដុយ មិនបានធ្វើស្រែចម្ការដូចអ្នកភូមិពោធិ៍ចិន្តាំដទៃទៀតទេ ។ ដុយ ប្រកបរបរជំនួញ ។ ដុយ រកស៊ីគ្រប់ប្រភេទតាំងពីលក់មាន់ទាត្រីសាច់ និងទំនិញផ្សេងៗ ។ ជួនកាល ដុយ ដើរជួញដូររហូតដល់ប្រទេសវៀតណាម ។ ចំណែក អឿន នៅផ្ទះមើលថែទាំផ្ទះសម្បែង ដាំបាយ ដាំទឹក ។

នៅចុងឆ្នាំ១៩៧២ អឿន ប្រសូតបានកូនស្រីម្នាក់ ។ ដុយ សប្បាយរីករាយណាស់នៅពេលដែលដឹងថាប្រពន្ធប្រសូតកូនស្រីបានសមតាមបំណងរបស់គាត់ ។ ដុយ ធ្លាប់បាននិយាយប្រាប់ប្រពន្ធថា គាត់ស្រឡាញ់កូនស្រីជាងកូនប្រុស ។ ដុយ មើលថែទាំប្រពន្ធនិងកូនសព្វបែបយ៉ាង ដូចជាបោកគក់ខោអាវប្រពន្ធកូន ដាំបាយ ដាំទឹក យោលកូន ។ ដុយ ដាក់ឈ្មោះឲ្យកូនស្រីថា គីមវ៉ា ។ ពេលចេញទៅរកស៊ីឯណាៗ គាត់មិនភ្លេចទិញរបស់ក្មេងលេងមកផ្ញើកូនឡើយ ។ ដុយ ធ្លាប់នាំប្រពន្ធកូនទៅលេងបងប្អូននៅព្រែកពោធិ៍និងនៅប្រទេសវៀតណាមដែរ ។ ចំណែកឪពុកម្តាយ ដុយ ស្លាប់តាំងពីមុនពេល ដុយ រត់មកនៅភូមិពោធិ៍ចិន្តាំមកម៉្លេះ ។ សាកសពរបស់គាត់បានបញ្ចុះនៅស្រុកពាមរ ខេត្តព្រៃវែង ។ នៅអំឡុងឆ្នាំ១៩៧៤ ដុយ បានរកស៊ីជួញដូរជាមួយជនជាតិវៀតណាម ដោយចូលទៅប្រទេសវៀតណាមទិញថ្នាំពេទ្យមកលក់នៅក្នុងតំបន់រំដោះខ្មែរក្រហមនៅព្រៃវែង ។ មានពេលខ្លះជនជាតិវៀតណាមឡើងមកប្រទេសកម្ពុជាទទួលទំនិញពី ដុយ យកទៅប្រទេសវៀតណាមវិញ ។ ការរស់នៅប្រកបដោយទៅសុភមង្គលរបស់ក្រុមគ្រួសារ ដុយ ត្រូវបានបញ្ចប់ទាំងស្រុងបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

កាលមុនឆ្នាំ១៩៧៥ បងប្អូនរបស់ ដុយ បានមកបបួល ដុយ ឲ្យភៀសខ្លួនទៅរស់នៅប្រទេសវៀតណាមមួយរយៈសិន

ពីព្រោះឃើញសភាពការណ៍នៅកម្ពុជាមានការច្របូកច្របល់ ។ ឆ្នាំ១៩៧០ រដ្ឋាភិបាលសាធារណរដ្ឋខ្មែរក៏ធ្លាប់ដេញនិងសម្លាប់អាណិកជនវៀតណាមដែលរស់នៅជ្រោយចង្វារនិងនៅទីក្រុងភ្នំពេញរួចម្តងហើយ ។ ចំណែក ខិន អឿន ក៏ធ្លាប់បានបបួល ជុយ ឲ្យផ្លាស់ទីលំនៅទៅប្រទេសវៀតណាមជាបណ្តោះអាសន្នដែរ ប៉ុន្តែត្រូវ ជុយ បដិសេធមិនព្រមទៅ ដោយនិយាយថា “សុខចិត្តស្លាប់រស់នៅស្រុកខ្មែរ” ។

នៅក្នុងរបបខ្មែរក្រហម ជុយ ត្រូវបានប្រធានសហករណ៍ឈ្មោះ ឆែម ចាត់តាំងឲ្យធ្វើការជាអ្នករែកអាចម៍គោក្របី រែកដីចាក់ក្នុងរណ្តៅ និងជីកស្រះជីកអាងនៅក្បែរៗភូមិពោធិ៍ចិន្តាំ ។ ជុយ មិនត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការឆ្ងាយៗឡើយ ។ កាលជំនាន់នោះ ជុយ មិនយកកូនទៅឲ្យម៉ែកុមារមើលទេ ពីព្រោះគាត់ព្រួយបារម្ភក្រែងម៉ែកុមារមើលកូនស្រីរបស់គាត់មិនបានដិតដល់ និងបញ្ចុកបាយឲ្យមិនឆ្អែត ។ ពេលទៅធ្វើការ ជុយ សុខចិត្តយកកូនស្រីរបស់គាត់ទៅតាម គឺរែកដីបណ្តើរដឹកដៃកូនស្រីបណ្តើរ ។ ម្តងម្កាល ខ្មែរក្រហមបានបញ្ជូនគាត់ឲ្យទៅជីកអាងជីកស្រះដែលអាចវិលត្រឡប់មកផ្ទះវិញនៅពេលល្ងាចបាន ជុយ ក៏ពរកូនស្រីយកទៅជាមួយដែរ ។ នៅពេលបាយម្តងៗ ជុយ តែងតែបញ្ចុកបាយរហូតដល់កូនឲ្យឆ្អែត ទើបបរិភោគខ្លួនឯង ថែមទាំងឆ្លៀតសុំបាយចុងភៅមួយដុំវេចនឹងជាយក្រមា បង្ការទុកក្រែងកូនឃ្លានពេលថ្ងៃឬពេលយប់ ។

ទោះបីជាធ្វើការយ៉ាប់យ៉ឺន ហូបចុកមិនបានគ្រប់គ្រាន់យ៉ាងណា ក៏ជុយ មិនដែលរអ៊ូរទាំថានឿយហត់ ឬប្រកែកមិនទៅធ្វើការឡើយ ។ ជុយ តែងតែធ្វើការងារបានរួចរាល់នូវផែនការដែលខ្មែរក្រហមបានចាត់តាំង ។

ប្រហែលក្នុងខែសីហា ឆ្នាំ១៩៧៧ ប្រធានសហករណ៍ឈ្មោះ ឆែម បានបញ្ជាឲ្យកងឈ្លបឃុំស្វាយអន្ទរ មកហៅ ជុយ ទៅជួបជុំគ្នានៅមន្ទីរឃុំ ដើម្បីចេញដំណើរទៅកាប់រពាក់ ។ មុនចេញដំណើរទៅ ជុយ បានស្រែកផ្តាំម្តាយក្មេកនិងប្រពន្ធថា “ជួយមើល គីមវ៉ា ឲ្យបានល្អផង ខ្ញុំទៅកាប់រពាក់តែបួនដប់ថ្ងៃត្រឡប់មកវិញហើយ” ។ តាំងពីថ្ងៃនោះមក ជុយ ទៅបាត់រហូតសូន្យឈឹងតែម្តង ។

នៅក្នុងរបបខ្មែរក្រហម អឿន មានអាយុជាង៣០ឆ្នាំ ស្ថិតនៅក្នុងកងនារីដែលពេញកម្លាំងពលកម្ម ។ អឿន ត្រូវបានគណៈកងចាត់តាំងឲ្យទៅដកស្ទូង ច្រូតកាត់ និងលើកដី គ្មានពេលទំនេរនៅឡើយ ។ ជួនកាល អឿន ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅលើកដីនៅកន្លែងឆ្ងាយៗដូចជានៅភូមិអំពិល ភូមិត្នោតដែលនៅជិតព្រំដែនប្រទេសវៀតណាម ។ ជួនកាលទៀតត្រូវបានបញ្ជូនឲ្យទៅដកស្ទូងច្រូតកាត់រហូតដល់កណ្តាលអាគ្រោត ហើយសម្រាកនៅការដ្ឋានតែម្តង ។ ជាទូទៅ នៅភូមិពោធិ៍ចិន្តាំ ខ្មែរក្រហមច្រើនតែចាត់តាំងស្ត្រីឲ្យទៅធ្វើការឆ្ងាយៗ ។ អឿន មិនសូវបាននៅជួបជុំគ្រួសារទេ ។ ទោះជាធ្វើការងារនៅជិតផ្ទះបានវិលមកសម្រាកនៅផ្ទះ ក៏អឿន មិនសូវបានមើលថែទាំកូនដែរ ព្រោះការងារមួយថ្ងៃៗតាំងពីព្រឹករហូតទល់ព្រលប់នៅកណ្តាលវាលស្រែ ធ្វើឲ្យ អឿន គ្មានកម្លាំងកំហែងនឹងនៅថ្នាក់ថ្នម បញ្ចុកបាយ ងូតទឹក បំពេរកូនឲ្យដេកដូច ជុយ ឡើយ ។ ទោះជាធ្វើការយ៉ាប់យ៉ឺនយ៉ាងនេះក្តី ក៏អង្គការខ្មែរក្រហមមើលមិនឃើញគុណសម្បត្តិដែរ ។ ខោអាវមួយចង្កេះរហែករយ៉ី អង្គការខ្មែរក្រហមមិនចែករបបខោអាវសម្រាប់ឲ្យផ្លាស់ប្តូរឡើយ ។

ថ្ងៃដែលកងឈ្លបហៅ ជុយ យកទៅ អឿន មិននៅផ្ទះទេ គឺទៅច្រូតស្រូវនៅវាលដុំឥដ្ឋខាងត្បូងភូមិពោធិ៍ចិន្តាំ ។ នៅពេលដែលកំពុងច្រូតស្រូវនៅវាលស្រែ ស្រាប់តែអ្នកធ្វើការជាមួយគ្នាបានប្រាប់គាត់ថា “ប្តីឯងគេយកទៅហើយ” ឮតែប៉ុណ្ណោះ អឿន ទម្លាក់កណ្តៀវហើយរត់ត្រឡប់មកផ្ទះភ្លាម ។ ពេលមកដល់ផ្ទះ អឿន ឃើញកងឈ្លបបំរុងនឹងនាំ ជុយ ទៅមែន ។ កងឈ្លបបានប្រាប់ អឿន ថា ប្រធានសហករណ៍ឲ្យ ជុយ ទៅជួបជុំនៅមន្ទីរឃុំដើម្បីចេញដំណើរទៅកាប់រពាក់ ។ ខណៈនោះ អឿន រៀបចំខោអាវឲ្យ ជុយ បណ្តើរ ផ្តាំផ្ញើរបណ្តើរថា “ឪគីមវ៉ាអើយ! បើគេឲ្យទៅកាប់រពាក់ប្រញាប់ត្រឡប់មកផ្ទះវិញផង” ។ អឿន មិនបានដឹងថាខ្មែរក្រហមយកប្តីទៅសម្លាប់ទេ

ស្មានថាឲ្យទៅកាប់រពាក់មែន ប៉ុន្តែតាំងពីយកទៅគឺបាត់រហូតតែម្តង ។

មួយសប្តាហ៍ក្រោយមកទើប អឿន មានការសង្ស័យថា «ប្តីទៅមិនវិលទេ» ព្រោះប្រពន្ធនិងកូនៗទាំងអស់របស់បងប្រុស អឿន ឈ្មោះ ឡាច នី ក៏ត្រូវកងឈ្លបខ្មែរក្រហមយករទេះសេះមកដឹកយកទៅដែរ ដោយប្រាប់ថា «យកទៅរៀនសូត្រ» ប៉ុន្តែបាត់ដំណឹងសូន្យឈឹងតែម្តង ។ ដូច្នេះទើប អឿន ដឹងច្បាស់ថាប្តីគាត់ពិតជាមិនបានវិលត្រឡប់មកវិញទេ ។ ទោះបីសង្ស័យថាខ្មែរក្រហមយកប្តីទៅសម្លាប់យ៉ាងណា ក៏អឿន មិនហ៊ានទៅសួរនាំឬប្រកែកតវ៉ាជាមួយ តាឆែម ដែលជាប្រធានសហករណ៍និងជាអ្នកបញ្ជាឲ្យកងឈ្លបមកហៅ ជុយ ទៅកាប់រពាក់ដែរ ពីព្រោះខ្លាចខ្មែរក្រហមយកគាត់និងកូនទៅសម្លាប់ទៀត ។ សូម្បីតែយំអាលោះអាល័យប្តីក៏មិនហ៊ានយំឲ្យនរណាឃើញដែរ សុខចិត្តលួចយំនៅកន្លែងស្ងាត់ៗ ដូចជាពេលយប់និងពេលសម្រាកនៅផ្ទះជាដើម ។

អឿន បានឲ្យដឹងថា «មូលហេតុដែលគេយកប្តីខ្ញុំទៅសម្លាប់តាមខ្ញុំយល់គឺគេចោទគាត់ថា យួន ព្រោះគេដឹងតាមស្ថិតិដែលភូមិនីមួយៗបានស្រង់ឡើង ហើយខ្ញុំក៏មិនដែលប្រាប់គេថាប្តីខ្ញុំជាយួនទេ តែគេដឹងដោយខ្លួនគេតែម្តង ហើយម្យ៉ាងទៀតដោយសារគាត់និយាយភាសាខ្មែរប៉ៃឡាំៗ» ។ ខ្មែរក្រហមចាប់ផ្តើមសម្លាប់អាណិកជនវៀតណាមបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យធ្វើសង្គ្រាមព្រំដែនជាទ្រង់ទ្រាយធំជាមួយប្រទេសវៀតណាមនាដើមឆ្នាំ១៩៧៧ ។ អឿន បានឲ្យដឹងទៀតថា គោលការណ៍របស់ខ្មែរក្រហមហ្នឹងគឺ«បើប្តីជាវៀតណាម ប្រពន្ធខ្មែរ ខ្មែរក្រហមយកតែប្តីជាវៀតណាមទៅសម្លាប់តែម្នាក់ប៉ុណ្ណោះ ចំណែកប្តីខ្មែរ ប្រពន្ធវៀតណាម ខ្មែរក្រហមយកទៅទាំងម្តាយទាំងកូនតែម្តង លើកលែងប្តីដែលជាជនជាតិខ្មែរ» ។

អ្នកដែលមកនាំ ជុយ យកទៅ គឺកងឈ្លបខ្មែរក្រហមដែលបានទទួលបញ្ជាពីប្រធានកងតូចឈ្មោះ ហួន និងប្រធានសហករណ៍ឈ្មោះ ឡឹក ឆែម ។ ទាំងពីរនាក់នេះត្រូវបានសម្លាប់បន្ទាប់ពីមានព្រឹត្តិការណ៍ សោ ភឹម ក្បត់ ។ ពេលដែលកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកគ្រប់គ្រងនៅភូមិភាគបូព៌ា អ្នកទាំងនោះបានសម្លាប់កម្មាភិបាលខាងភូមិភាគបូព៌ាចាប់តាំងពីថ្នាក់ភូមិភាគរហូតភូមិឃុំ ដោយចោទថាសមគំនិតជាមួយ សោ ភឹម ចូលដៃចូលជើងជាមួយវៀតណាមបម្រុងធ្វើរដ្ឋប្រហារដណ្តើមអំណាច ។

ក្រោយពេលខ្មែរក្រហមយក ជុយ ទៅសម្លាប់ អឿន មិនត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅនៅដីខ្លាញ់ដូចក្រុមគ្រួសារ ឡាច នី ទេ ។ អឿន រស់នៅតែពីរនាក់ម្តាយនិងកូនស្រី ។ អឿន ក៏ប្តូរឈ្មោះឲ្យកូនស្រីពី គីមវ៉ា មកជា សាមាន វិញ ពីព្រោះភ័យខ្លាចខ្មែរក្រហមយកកូនទៅសម្លាប់ដូចឪពុក ។

ពេលដែលខ្មែរក្រហមយកឪពុកទៅសម្លាប់ គីមវ៉ា ចេះនិយាយ និងដឹងក្តីខ្លះៗហើយ ។ គីមវ៉ា ធ្លាប់ត្រូវបានឪពុកស្រលាញ់ថ្នាក់ថ្នម បញ្ចុកបាយ ងូតទឹក រៀបចំឲ្យដេក ជាពិសេសគឺពេលវេលារស់នៅជាមួយឪពុកច្រើនជាងម្តាយ ដល់ពេលមិនឃើញឪពុក គីមវ៉ា មានការនឹករឭកដល់ឪពុកជាខ្លាំង តែងតែសួរម្តាយជារឿយៗថា «ម៉ែៗប៉ាទៅណា» ។ អឿន ឆ្លើយថា «គេយកទៅកាប់រពាក់បាត់ហើយ» ។ គីមវ៉ា ក៏សួរបន្តទៀតថា «ម៉ែអើយកាប់រពាក់ហ្នឹងឆាប់មកទេម៉ែ?» ។ អឿន ឆ្លើយថា «អើ! អញមិនដឹងថ្ងៃណាផង» ។ មួយរយៈពេលក្រោយមក គីមវ៉ា នៅតែសួរនាំម្តាយអំពីឪពុក អឿន ឆ្លើយដដែលទៀត «ទៅកាប់រពាក់ហ្នឹងណា បើមិនឃើញមកអញមិនដឹងដែរ» ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ គីមវ៉ា លែងសួរម្តាយទៀត ពីព្រោះបានដឹងថាខ្មែរក្រហមបានយកឪពុកទៅសម្លាប់ចោលបាត់ទៅហើយ ។

អឿន បានឲ្យដឹងថា កាលពីខ្មែរក្រហមយក ជុយ ទៅកាប់រពាក់ភ្លាមៗ គាត់ធ្លាប់សុបិនឃើញប្តីញឹកញាប់ណាស់ ។ មានម្តងនោះ អឿន បានសុបិន្តឃើញ ជុយ មកប្រាប់ថា «គេយកអញទៅវ៉ៃចោល» ។ ទោះបីជារឿងរ៉ាវកន្លងទៅយូរហើយ ក៏ប៉ុន្តែ អឿន នៅតែចាំមិនភ្លេច ។ «ខ្ញុំនៅតែនឹកឃើញអីចឹង បើឲ្យខ្ញុំ

បំភ្លេចឲ្យបាត់តែម្តងនោះ គឺខ្ញុំធ្វើមិនរួច ព្រោះវាចេះតែនឹកឃើញប្តី ។ គ្មាននរណាទៅសួរសោះនោះទេ ហើយបើបានគេសួរនាំអ៊ីចឹង ខ្ញុំប្រាប់គេក៏បានធូរចិត្តខ្លះដែរ» ។ អឿន បន្ថែមថា «បើខ្មែរក្រហមយកកូនខ្ញុំទៅទៀត ខ្ញុំក៏គ្មានរស់ដែរមិននៅទេ ទៅឲ្យវាអ្ហែងសម្លាប់អស់មួយពូជតែម្តង» ។

អ្វីដែលធ្វើឲ្យ អឿន បំភ្លេច ជុយ មិនបានគឺ ជុយ ជាមនុស្សចិត្តបានណាស់ ។ ជុយ ស្រឡាញ់ថ្នាក់ថ្នមប្រពន្ធកូន មិនឲ្យឃ្លើស ។

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនាថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩ អឿន និងកូន ត្រូវរកស៊ីចិញ្ចឹមជីវិតដោយខ្លួនឯង ។ ទាំងពីរនាក់ម្តាយនិងកូនពុំមានលទ្ធភាពធ្វើស្រែចម្ការដូចអ្នកភូមិពោធិ៍ចិន្តាំងទៃទៀតឡើយ ដោយសារខ្វះខាតទាំងគោក្របី គ្មានទាំងអ្នកភ្ជួររាស់ ។ បច្ចុប្បន្ន អឿន ប្រកបរបរលក់ដូរកំប៉ិកកំប៉ុក ប៉ុន្តែកម្រៃដែលបានមកពីការលក់ដូរមិនអាចផ្គត់ផ្គង់ជីវភាពបានគ្រប់គ្រាន់ឡើយ គឺរកមួយថ្ងៃហូបមួយថ្ងៃ ។ តាំងពីព្រលឹមទល់ព្រលប់ ទាំងពីរនាក់ម្តាយនិងកូនចេញរកស៊ីគ្មានពេលសម្រាក ។ នៅពេលដែលរំឭកដល់ ជុយ ម្តងៗ អឿន តែងតែបង្ហូរទឹកភ្នែក ។ អឿន ពោលថា «បើឪពុកវានៅរស់ កូនខ្ញុំគ្មានពិបាកទេ ច្បាស់ជាឪពុកមិនឲ្យធ្វើអីតែម្តង ។ គាត់មុខជាបណ្តុះបណ្តាលឲ្យកូនធ្វើការនឹងគេហើយ គាត់បន់ឲ្យតែកូនចេះ បន់ឲ្យតែកូនធំ ឆ្អាលដឹកនាំឲ្យធ្វើការ» ។ អឿន បន្តទៀតថា «ពេលឃើញមុខកូន ខ្ញុំតែងតែនឹកទៅដល់ប្តីខ្ញុំ ។ ប្អូនដប់ថ្ងៃកន្លះខែនឹកឃើញម្តង យូរៗនឹកឃើញម្តង» ។

ការភ័យខ្លាចដែលបន្សល់ពីរបបខ្មែរក្រហមនៅតែដិតជាប់ក្នុងអារម្មណ៍ អឿន ជានិច្ច ។ អឿន បានឲ្យដឹងថា «កូនស្រីខ្ញុំ ខ្ញុំមិនហ៊ានលើកឲ្យអ្នកដែលមានខ្សែលោហិតជាវៀតណាមទៀតទេ ខ្លាចជួបរឿងឪពុកវា» ។

នៅក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំប្រពៃណីខ្មែរ វៀតណាម ទោះបីខ្វះខាតប្រាក់កាក់យ៉ាងណា ក៏អឿន ខំប្រឹងសុះស្អែងធ្វើម្ហូបអាហារយកទៅវត្តប្រគេនព្រះសង្ឃ និងអុជទៀនធូបរំឭកដល់វិញ្ញាណក្ខ័ន្ធរបស់ ជុយ ។ តាំងពី ជុយ ស្លាប់ទៅ អឿន គ្មានលទ្ធភាពនឹងធ្វើបុណ្យអីឲ្យបានធំដុំបញ្ជូនមគ្គផលដល់ ជុយ ទេ ។ អឿន ធ្លាប់គិតថា ប្រសិនបើមានប្រាក់កាសគ្រប់គ្រាន់ គាត់នឹងធ្វើបុណ្យឧទ្ទិសកុសលដល់ ជុយ ។

អឿន បានបង្ហើបឲ្យដឹងថា «បើខ្ញុំមានឱកាស ហើយមានអ្នកជួយគាំទ្រការពារខ្ញុំ ខ្ញុំចង់ប្តឹងចំពោះអ្នកដែលចាប់ប្តីខ្ញុំយកទៅសម្លាប់ដែរ ប៉ុន្តែគ្មាននរណាគេអើពើ ហើយខ្ញុំម៉េចនឹងហ៊ានបើមានតែម្នាក់ឯងអ៊ីចឹង» ។

**ឡុង ដានី**

## ពាក្យស្លោកខ្មែរក្រហម

◆ គោរពនិងអនុវត្តលក្ខការណ៍សមូហភាពដឹកនាំ ហើយកម្ចាត់របៀបរបបដឹកនាំនិងធ្វើការងារស្អួនតួជាដាច់ខាត។

◆ គោរពនិងអនុវត្តលក្ខការណ៍ដឹកនាំនិងធ្វើការងារជាប់ជិតស្និទ្ធនឹងមូលដ្ឋាន ជាប់ប្រជាជន និងជាប់ចលនា ជាដាច់ខាត។

◆ គោរពនិងអនុវត្តលក្ខការណ៍ដឹកនាំធ្វើការងារដោយស្មារតីទទួលខុសត្រូវខ្ពស់ និងចាត់ចែងការងារដោយស្វាហាប់ ច្នៃប្រឌិតកសាងរស់រវើក ដើម្បីបម្រើចលនាឱ្យឆាប់និងល្អបំផុត។

◆ លើកកម្ពស់ស្មារតីទទួលខុសត្រូវខ្ពស់បំផុតក្នុងការគិតគូរដោះស្រាយជីវភាពប្រជាជនគ្រប់ផ្នែកឱ្យបានជាដាច់ខាតជាបន្តបន្ទាប់។

(សៀវភៅកំណត់ហេតុលេខ ១៣៥)

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមផ្ញើមក
**ទស្សនាវដ្តី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥)(២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥)(២៣) ២១០ ៣៥៨
Email: dccam@bigpond.com.kh
Home page: http://welcometo/dccam

# កូនស្រីដែលបាត់បង់នៅក្នុងបដិវត្តន៍ខ្មែរក្រហម

មុនឆ្នាំ១៩៧៥ នៅក្នុងឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល យុវនារីភាគច្រើនដែលមានអាយុចាប់ពី១៣ដល់១៨ឆ្នាំ ត្រូវបានប្រធានភូមិ-ឃុំជ្រើសរើសឲ្យចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ យុវនារីទាំងនោះមិនបានដឹងថាតើធ្វើបដិវត្តន៍ដើម្បីអ្វីទេ គ្រាន់តែបានឮតាមការឃោសនារបស់ប្រធានភូមិ-ឃុំថា "ចូលបម្រើបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិ" ។ យុវនារីមួយចំនួនក៏ចូលបម្រើបដិវត្តន៍ដោយស្ម័គ្រចិត្តដោយសារជឿតាមការឃោសនានេះ ។ រីឯមួយចំនួនទៀតចូលបម្រើបដិវត្តន៍ក្រោមការបង្ខិតបង្ខំ ។

អ៊ឹម ចន បានចូលបម្រើបដិវត្តន៍តាំងពីអាយុ១៦ឆ្នាំ តាមរយៈ ស តាំងយ៉េង និង ស្រ៊ី ដែលជាប្រធាននារីប្រចាំភូមិ ។ ចន បាននិយាយថា "បើមិនទៅទេ គណៈឃុំនឹងធ្វើទុក្ខបុកម្នេញ បង្ខំឲ្យធ្វើការមិនដឹងយប់ថ្ងៃ" ។ ណយ អ៊ិត ក៏ចូលក្នុងជួរបដិវត្តន៍តាំងពីអាយុ១៦ឆ្នាំដែរ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៤ អ៊ិត បានឮដំណឹងថាបងប្រុសរបស់គាត់ស្លាប់ដោយសារជំងឺ ។ អ៊ិត បានសុំការអនុញ្ញាតពីប្រធានកងត្រឡប់មកផ្ទះដើម្បីចូលរួមក្នុងពិធីបុណ្យសពបងប្រុស ប៉ុន្តែប្រធានកងមិនអនុញ្ញាតឲ្យគាត់មកទេ ផ្ទុយទៅវិញបញ្ជូនគាត់ឲ្យទៅសែងអ្នករបួសនៅសមរភូមិទួលក្រាំង ។

បណ្តាយុទ្ធនារីខ្មែរក្រហមត្រូវបានជំរុញឲ្យធ្វើការងារនៅសមរភូមិមុខ ដូចជា ជញ្ជូនគ្រាប់ទៅសមរភូមិ រែកបាយ សែងអ្នករបួស និងយាមសាកសព ។ ណាំ សុខា បាននិយាយថា "ស្រីៗក៏ត្រូវកាន់កាំភ្លើងដូចប្រុសដែរ" ។ យុទ្ធនារីដែលមានវ័យចំណាស់បន្តិច ត្រូវបានគណៈកងចាត់តាំងឲ្យទៅសមរភូមិមុខ ចំណែកកុមារីគឺជាអ្នករែកបាយពីកន្លែងសេដ្ឋកិច្ចយកទៅឲ្យកងទ័ពនៅតាមខ្សែត្រៀមនៅសមរភូមិមុខ ។

នៅឆ្នាំ១៩៧៥ ស តាំងយ៉េង ត្រូវបានប្រធានឃុំឈ្មោះ ប៉ិច ចាត់តាំងជាប្រធាននារីប្រចាំភូមិ ដែលត្រូវដឹកនាំនិងប្រមូលនារីយកទៅធ្វើកងទ័ព ។ ស្រេង ជាឪពុករបស់ តាំងយ៉េង បានឲ្យដឹងថា "បើកូនរបស់ខ្ញុំមិនព្រមចូលបម្រើបដិវត្តន៍ មិនអាចចៀសផុតពីការស្លាប់ឡើយ ។ ក្មេងស្រីៗនៅក្នុងភូមិនេះត្រូវគណៈភូមិបង្ខំឲ្យទៅសមរភូមិគ្រប់ៗគ្នា" ។ ពេលទៅដល់សមរភូមិមុខ តាំងយ៉េង បានទទួលភារៈជាអ្នកយាមសាកសព ។ ដោយសេចក្តីភ័យខ្លាច តាំងយ៉េង ក៏លួចរត់ត្រឡប់មកផ្ទះវិញ ។ តាំងយ៉េង មកដល់ផ្ទះបានពីរថ្ងៃ ប្រធាននារីប្រចាំភូមិឈ្មោះ ង៉ូវ បានមកបង្ខំឲ្យនាងត្រឡប់ទៅសមរភូមិវិញ ។ ស្រេង មិនហ៊ានឃាត់កូនស្រីរបស់គាត់ទេ ព្រោះគាត់ដឹងថាបើកូនរបស់គាត់នៅគឺត្រូវស្លាប់ ។ គាត់បានសម្រេចចិត្តឲ្យកូនរបស់គាត់ត្រឡប់ទៅវិញទាំងអាឡោះអាល័យ ។ ចាប់តាំងពីពេលនោះមក ស្រេង មិនបានទទួលដំណឹងអ្វីពីកូនស្រីគាត់ទាល់តែសោះ ។



ស្រេង កំពុងអានឯកសារប្រវត្តិរូបរបស់កូនស្រី

ឡូ ស៊ីម ត្រូវបាន ស្រ៊ី ប្រធានភូមិប្រធាគុ បង្ខិតបង្ខំឲ្យចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ ស្រ៊ី បានស្តីបន្ទោស ស៊ីម ថា "នៅធ្វើអីទៀត បើគេទៅអស់ហើយ" ។ ស៊ីម ត្រូវបានគណៈកងចាត់តាំងឲ្យដាំបាយនិងរែកយកទៅឲ្យកងទ័ពនៅសមរភូមិមុខ ។

មានពេលខ្លះ ស៊ីម វែកបាយទៅដល់ខ្សែត្រៀមត្រូវយន្តហោះទម្លាក់គ្រាប់បែកស្លាត់ស្ទើរស្លាប់ស្ទើររស់ ។ ដោយមិនអាចទ្រាំទ្រនឹងការងារទាំងអស់នេះបាន ស៊ីម សម្រេចចិត្តរត់ត្រឡប់មកផ្ទះវិញ ម្យ៉ាងទៀតព្រោះបានឮដំណឹងថាម្តាយរបស់គាត់ឈឺធ្ងន់ ។ ស៊ីម មកដល់ផ្ទះបានប្រហែលតែពីរឬបីម៉ោង គណៈកងបានមកតាមគាត់ឲ្យត្រឡប់ទៅសមរភូមិវិញ ។ ម្តាយរបស់ ស៊ីម យំរហូតដល់ដាច់ដង្ហើមស្លាប់ ព្រោះតែអាណិតកូន ។

ស្រ៊ិន ត្រូវជាឪពុករបស់ ជា អ៊ីម ។ គាត់ទាំងពីរនាក់ឪពុកនិងកូនបានបែកគ្នាតាំងពីឆ្នាំ១៩៧៣មកម្ល៉េះ ។ កាលនោះ អ៊ីម ទើបតែអាយុ១៣ឆ្នាំប៉ុណ្ណោះ ត្រូវប្រធានភូមិចុងព្រែកឈ្មោះ ចាន់ គៀន មកហៅឲ្យចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ ស្រ៊ិន និយាយថា អ៊ីម បានទទួលការចាត់តាំងឲ្យវែកបាយទៅសមរភូមិព្រែកតូច ។ ដោយសារតែមិនអាចទ្រាំទ្រនឹងការលំបាក អ៊ីម បានរត់មកផ្ទះ ប៉ុន្តែត្រូវមេកងមកតាមចាប់យកត្រឡប់ទៅវិញ ។ ស្រ៊ិន បានឮដំណឹងថា អ៊ីម ត្រូវគណៈកងដាក់បញ្ជាឲ្យគាស់គ្រាប់កាំភ្លើងស្អុយៗនៅក្រោយវត្តកំពង់សំបួរ ។ តាំងពីពេលនោះមក ស្រ៊ិន បាត់ដំណឹងកូនស្រីរបស់គាត់រហូតមិនដឹងថាស្លាប់ឬរស់ទេ ។ ក្រោយឆ្នាំ១៩៧៩ នៅពេលដែលបានជួបនារីៗដែលចេញពីភូមិជាមួយកូនគាត់ ហើយដែលបានត្រឡប់មកផ្ទះវិញ ស្រ៊ិន តែងតែសួររកកូនរបស់គាត់ជានិច្ច ប៉ុន្តែគាត់នៅតែមិនបានទទួលដំណឹងអ្វីដដែល ។ ស្រ៊ិន បានចាត់ទុកថាគាត់បាន“ចាញ់បោកនយោបាយខ្មែរក្រហម” ។

យុវនារីមួយចំនួន បន្ទាប់ពីចូលបម្រើបដិវត្តន៍ខ្មែរក្រហមអស់រយៈពេលជាច្រើនឆ្នាំ ទើបបានវិលត្រឡប់មកដល់ស្រុកកំណើតវិញ ប៉ុន្តែឪពុកម្តាយក៏បានស្លាប់ចោលអស់ ។ ទុយ សុន បានគេចចេញពីភូមិកំណើតរបស់គាត់ទៅបម្រើបដិវត្តន៍តាំងពីអាយុ១៨ឆ្នាំ ដោយសារតែឪពុកម្តាយរបស់គាត់បង្ខំឲ្យគាត់រៀបការជាមួយបុរសម្នាក់ដែលគាត់មិនពេញចិត្ត ។ សុន បានអះអាងថា ពេលនោះទោះបីចង់ទៅឬមិនចង់ទៅ យូរឬឆាប់ក៏គណៈកងហៅឲ្យចូលបម្រើបដិវត្តន៍ដដែល ។ នៅក្នុងជួរបដិវត្តន៍ សុន មាននាទីជាអ្នកសែងអ្នករបួស ។ មួយរយៈក្រោយមក សុន នឹករឭកម្តាយខ្លាំងពេក ក៏សម្រេចចិត្តវិលត្រឡប់មកផ្ទះ ប៉ុន្តែធ្វើដំណើរមិនទាន់ដល់ផ្ទះផង ត្រូវគណៈកងតាមចាប់យកទៅសមរភូមិវិញ ។ ក្រោយពេលដែលរបបខ្មែរក្រហមដួលរលំទើប សុន បានវិលត្រឡប់មកផ្ទះវិញ ប៉ុន្តែម្តាយរបស់គាត់បានស្លាប់បាត់បង់ជីវិតទៅហើយ ដោយសារនឹករឭកដល់រូបគាត់ គួបផ្សំនឹងជំងឺដែលគ្មានថ្នាំព្យាបាល ។ បុរសដដែលក៏បានមកស្តីដណ្តឹង សុន ម្តងទៀត ។ ដោយសេចក្តីអាណិតចំពោះឪពុក សុន ក៏យល់ព្រមរៀបការជាមួយបុរសនោះ ។

ប្រមាណពីរខែបន្ទាប់ពីរំដោះទីក្រុងភ្នំពេញ ខ្មែរក្រហមបានជ្រើសរើសនារីដែលមានជាប់និន្នាការ រួចបញ្ជូនឲ្យទៅធ្វើការនៅប៉ែកនិរតីទីក្រុងភ្នំពេញ ។ នៅទីនោះ អ្នកដែលប្រព្រឹត្តកំហុសដូចជាលួចរត់ត្រឡប់មកផ្ទះឬខុសសីលធម៌ ត្រូវបញ្ជូនឲ្យទៅធ្វើការនៅស្ទឹងបាគូ ។ វេង ផល បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍កាលពីអាយុ១៨ឆ្នាំ ក្រោយមកក៏រត់ត្រឡប់មកផ្ទះវិញដោយសារនឹកឪពុកម្តាយខ្លាំងពេកទ្រាំមិនបាន ។ ផល ត្រូវគណៈកងចាប់បញ្ជូនឲ្យទៅធ្វើការនៅស្ទឹងបាគូ ឲ្យលើកទំនប់ ជីកប្រឡាយ ធ្វើស្រែ ស្ទើរគ្មានពេលសម្រាក ។

នៅឆ្នាំ១៩៧៥ ប្រធានកងបានបញ្ជូន ឡេង ណាវ ទៅលើកទំនប់ ជីកប្រឡាយ ដកស្ទូង នៅស្ទឹងបាគូ ។ រហូតដល់ឆ្នាំ១៩៧៩ ខ្មែរក្រហមបានកៀរគាត់ឡើងលើភ្នំ ។ ណាវ មានបំណងរត់ទៅប្រទេសថៃ ប៉ុន្តែរត់ឆ្លងមិនផុតត្រូវកងទ័ពវៀតណាមចាប់បញ្ជូនមកស្រុកកំណើតវិញ ។ មកដល់ស្រុកកំណើតអ្វីៗបានប្រែប្រួលអស់ ឡេង ណាវ ក្លាយជាកូនកំព្រា ព្រោះឪពុកម្តាយរបស់គាត់បានស្លាប់ដោយសារធ្វើការងារហួសកម្លាំងនៅក្នុងរបបខ្មែរក្រហម ។

រហូតមកដល់បច្ចុប្បន្ននេះ ឪពុកម្តាយញាតិមិត្តក្រុមគ្រួសារមួយចំនួននៅតែទន្ទឹងមើលផ្លូវកូនរបស់ខ្លួននៅឡើយ ។ ការរង់ចាំនេះបានអូសបន្លាយពេលវេលាអស់ជាងម្ភៃឆ្នាំ រហូតដល់ឪពុកម្តាយមួយចំនួនស្ទើរតែភ្លេចថាគាត់បានបាត់កូននៅក្នុងរបបខ្មែរក្រហមទៅហើយ ។ ខ្មែរក្រហមមិនត្រឹមតែបានបំផ្លាញមូលដ្ឋានគ្រឹះនៃសង្គមគ្រួសារខ្មែរប៉ុណ្ណោះទេ ថែមទាំងបំផ្លាញផ្លូវចិត្តប្រជាជនខ្មែរឲ្យរងទុក្ខវេទនាដោយសារតែការព្រាត់ប្រាសគ្មានថ្ងៃជួបវិញ ។

**ប៉ាង ពីច័ន**

# តួនាទីយ៉ាងសំខាន់នៃទស្សនាវដ្ដី "ស្វែងរកការពិត"

ខ្ញុំនៅជាទារកនៅឡើយចំពេលដែលរបបអន្ដការមហាលោតផ្លោះមហាអស្ចារ្យបានចាប់ផ្ដើមគ្រប់ដណ្ដប់លើផ្ទៃប្រទេសកម្ពុជាទាំងមូលនៅថ្ងៃទី១៧ មេសា ១៩៧៥ ។ ទំហំនៃការសម្លាប់រង្គាល ការបង្ខំឲ្យធ្វើការហួសកម្លាំង ការបង្អត់អាហារ ការបណ្ដេញប្រជាជនចេញពីទីក្រុង អំពើព្រៃផ្សៃគ្មានសាសនាមកលើប្រជាពលរដ្ឋចាប់តាំងពីមនុស្សចាស់រហូតដល់ទារក បានកើតមានឡើងតាំងពីការចាប់ផ្ដើមរបស់របបកម្ពុជាប្រជាធិបតេយ្យនេះរហូតដល់កម្ពុជាត្រូវបានរំដោះនៅថ្ងៃទី៧ មករា ១៩៧៩ ។

ទាំងនេះខ្ញុំបានដឹងយ៉ាងពិស្ដារបំផុតក្រោយពីបានអានទស្សនាវដ្ដីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ វានៅតែជាភាពសំខាន់ក្នុងការដែលខ្ញុំត្រូវស្វែងយល់បន្ថែមទៀតតាមរយៈទស្សនាវដ្ដីនេះ អំពីរបបដ៏សាហាវយង់ឃ្នងនេះ ។ ទស្សនាវដ្ដីនេះមានភាពសំខាន់យ៉ាងពិតប្រាកដក្នុងការស្វែងរកការពិត ហើយដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ជាលទ្ធផលខ្ញុំមានជំនឿយ៉ាងមុតមាំថា តុលាការឯករាជ្យមួយនឹងត្រូវបង្កើតឡើងមួយផ្នែកក្រោមការខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។







**ឈុន ស៊ីថេត**

មន្ត្រីកម្មវិធី

មជ្ឈមណ្ឌលជប៉ុនដើម្បីរារាំងជម្លោះ (JCCP)

ភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០២

# មានអត្ថន័យធំធេងណាស់...

ខ្ញុំសូមសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកនាយក ដែលបានផ្ដល់នូវទស្សនាវដ្ដី ស្វែងរកការពិត មកខ្ញុំជារៀងរាល់លេខ ។ ចំពោះអារម្មណ៍ខ្ញុំផ្ទាល់ ទស្សនាវដ្ដីនេះមានអត្ថន័យធំធេងណាស់ ហើយក៏ជាការឆ្លុះបញ្ចាំងនូវជម្រៅនៃការពិតពីអតីតកាលដែលកន្លងនាពេលថ្មីៗនេះ ។ ខ្ញុំផ្ទាល់សូមធ្វើការកោតសរសើរចំពោះក្រុមការងារនៃទស្សនាវដ្ដីស្វែងរកការពិត ដែលបានព្យាយាមខិតខំពុះពារនូវរាល់ឧបសគ្គ ដើម្បីស្វែងរកពត៌មានដែលយើងគ្រប់គ្នាចង់ដឹង ចង់យល់ ថ្វីដ្បិតតែយើងបានរស់នៅក្នុងរបបនេះដែរ តែយើងពុំអាចដឹងបាននូវហេតុការណ៍ឲ្យគ្រប់ជ្រុងជ្រោយទាំងអស់នោះបានឡើយ ។

ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងនូវការអរគុណចំពោះលោកម្នាក់ ដែលលោកក៏ជាក្រុមការងារនៃទស្សនាវដ្ដីស្វែងរកការពិតដែរ (តែសូមទោសព្រោះខ្ញុំភ្លេចឈ្មោះលោក) គឺលោកនោះហើយដែលបានជួបខ្ញុំនៅការិយាល័យរបស់ខ្ញុំ ហើយក៏ជួយឲ្យខ្ញុំបាននូវទស្សនាវដ្ដីនេះជាបន្តបន្ទាប់មក ។ សូមលោកនាយកមេត្តាទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

ប្រធាននាយកដ្ឋានពត៌មាន

នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា

**កែម សុផុនណា**









ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនីងដាក់លក់នៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 33, September 2002.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance;
the Royal Danish Government; Swedish International Development Co-operation Agency (Sida);
and the Royal Netherlands Government, *The Hague*.